**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universite Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **រួន សុខច័ន្ទរើន**

កញ្ញា **ពៅ ដាលុច**

ណែនាំដោយ

លោកគ្រូ **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **រួន សុខច័ន្ទរ៉ើន**

កញ្ញា **ពៅ ដាលុច**

ណែនាំដោយ

លោកគ្រូ **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

` យើងខ្ញុំឈ្មោះ **រួន សុខច័ន្ទរ៉ើន** និងឈ្មោះ **ពៅ ដាលុច** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

**សូមគោរពប្រណិប័តន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក គ្រួច ណារ៉ុង** **លោកឪពុក ពៅ ណារិន**

**អ្នកម្តាយ ចាំ សុភាព** **អ្នកម្តាយ យិន សោភ័ណ្ឌា**

ដែលបានផ្តល់កំណើត ខិតខំចិញ្ចឹមបីបាច់ ថែរក្សាអប់រំទូន្មានប្រៀនប្រដៅដល់កូនឱ្យបានស្គាល់នូវអ្វីដែលជាផ្លូវល្អផ្លូវអាក្រក់សម្រាប់អនាគតរបស់កូន។ចំពោះមហាគុណរបស់លោកទាំងពីរកូនពុំអាចនឹងរកអ្វីយកមកប្រៀបស្មើទៅនឹងគុណរបស់លោកទាំងពីរនោះទេ ហើយកូនក៏មិនអាចបំភ្លេចបាននូវព្រះគុណដ៏បវរនេះបាននោះឡើយ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំង **សាកលវិទ្យាធិការរង គណៈកម្មការ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យ** ទាំងអស់ដែលបានខិតខំអស់កម្លាំងកាយកម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន និងណែនាំចំណេះដឹងល្អៗផ្សាភ្ជាប់នឹងសង្គមកម្ពុជាបច្ចុប្បន្ន។

ជាពិសេស **លោកគ្រូណែនាំ ហេង មូ៉រ៉ា** ដែលជាលោកគ្រូមួយរូបដែលប្រកបដោយគតិបណ្ឌិត ដែលបានផ្តល់កិត្តិយសណែនាំជួយជ្រោមជ្រែងផ្តល់នូវគំនិតយោបល់ជួយកែតម្រូវរាល់កំហុសឆ្គងក្នុងការសរសេរសារណានេះតាំងពីដំណាក់កាលដំបូងរហូតដល់ទទួលបានជោគជ័យលោកគ្រូគឺបានផ្តល់នូវគ្រឹះយ៉ាងសំខាន់ក្នុងការចងក្រងសារណាមួយនេះឡើង។

អ្នកនិពន្ធ ម្ចាស់ឯកសារ អ្នកសិក្សាស្រាវជ្រាវ និងម្ចាស់ស្នាដៃទាំងអស់ដែលបានចូលរួមជាជាលិការដ៏សំខាន់ដល់យើងខ្ញុំជាទុននៃការសិក្សា និងបំពេញភាពខ្វះចន្លោះនៃកិច្ចការស្រាវជ្រាវនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធិពរជ័យសិរីបវរជូនដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ឯកឧត្តមសាស្ត្រាចារ្យ សាស្ត្រាចារ្យ លោក លោកគ្រូ អ្នកគ្រូ** ទាំងអស់ សូមមានសុខភាពល្អ សុខសុវត្ថិភាពគ្រប់ទីកន្លែង និងទទួលបានសម្រេចរាល់ការងារភារកិច្ចទាំងពួង និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋមយើងខ្ញុំទាំងពីរឈ្មោះ **រួន សុខច័ន្ទរ៉ឺន** និងឈ្មោះ **ពៅ ដាលុច** សូមធ្វើការស្វាគមន៍ចំពោះប្រិយមិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស និស្សិតជាទីរាប់អាន និងសាស្ត្រាចារ្យជាទីគោរព។ ក្រោយពីបានឆ្លងកាត់ការសិក្សានិងក្រេបជញ្ជក់ចំណេះដឹងចាប់តាំងពីឆ្នាំទីមួយរហូតដល់បញ្ចប់ការសិក្សានៅ **"សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច"** យើងខ្ញុំពិតជាមានកិត្តិយសដ៏ក្រៃលែង ដែលសាកលវិទ្យាល័យបានផ្តល់នូវឱកាសដល់យើងខ្ញុំក្នុងការតាក់តែងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះក្នុងរយៈពេលបួនឆ្នាំនេះយើងខ្ញុំបានសិក្សាជាច្រើនមុខក្នុងនោះមុខវិជ្ជាដែលយើងខ្ញុំយកមកតាក់តែងសារណានោះ គឺមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ។ ដូចនេះយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទសារណាមួយស្តីពី "**ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**"។ ការជ្រើសរើសនេះ យើងបានឆ្លងកាត់នូវការពិភាក្សាពិគ្រោះនិងផ្តល់យោបល់ពីសំណាក់លោកសាស្ត្រចារ្យយ៉ាងហ្មត់ចត់និងយល់ឃើញថាការតម្កល់រឿងទុកឥតចាត់ការ ពិតជាមានប្រយោជន៍និងសារៈសំខាន់ណាស់ ចំពោះសិស្ស-និស្សិត ក៏ដូចជាអ្នកក្នុងវិស័យច្បាប់គួរតែយល់ដឹង និងម្យ៉ាងទៀតដោយពុំទាន់ឃើញមានការបកស្រាយយ៉ាងស៊ីជម្រៅអំពីប្រធានបទនេះដើម្បីទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗទៀតនៅឡើយ។

យើងខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំង ដែលបានតាក់តែងសារណាក្រោមប្រធានបទស្តីពី **"ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ"** ដែលមានលោកគ្រូណែនាំ៖ **ហេង មូរ៉ា** ដែលផ្តល់ជាជំនួយដល់យើងខ្ញុំទាំងពីររូបក្នុងការតាក់តែងសារណានេះយ៉ាងរលូនទាំងការផ្តល់យោបល់ណែនាំ និងផ្តល់ឯកសារពាក់ព័ន្ធ។ យើងខ្ញុំទាំងពីររូបសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សារណាមួយនេះនឹងក្លាយជាឯកសារចម្បងក្នុងការស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយៗ ដើម្បីជាជំនួយផ្នែកស្មារតី និងចំណេះដឹង។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ យើងខ្ញុំទាំងពីររូបប្តេជ្ញាថានឹងប្រើប្រាស់នូវចំណេះដឹងនេះឱ្យបានជាប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍ដល់សង្គមជាតិនាពេលអនាគត។

ទោះបីជាមានការខិតខំស្រាវជ្រាវ ការត្រួតពិនិត្យ និងការកែតម្រូវយ៉ាងណា ក៏សារណាមួយនេះនៅតែមានចំណុចដែលខ្វះខាតផ្នែកខ្លឹមសារ ឬកំហុសខុសឆ្គងផ្នែកខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន។ ដូច្នេះយើងខ្ញុំទាំងពីររូបធ្វើការលំអោនកាយសូមការអធ្យាស្រ័យ និងសូមអភ័យទោស ចំពោះកំហុសខុសឆ្គងទាំងឡាយ ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកអានគ្រប់មជ្ឈដ្ឋាន។ យើងខ្ញុំទាំងពីររូបរងចាំទទួលនូវការរិះគន់ និងកែតម្រូវក្នុងន័យស្ថាបនា ដើម្បីឱ្យសមិទ្ធផលមួយនេះកាន់តែប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**អង្គការអយ្យការ**

**ផ្នែកទី១៖ រចនាសម្ព័ន្ធនៃអង្គការអយ្យការ** ........ ៤

១.១ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........ ៥

១.២ មហាអយ្យការអមសាលាឧទ្ធរណ៍ ........ ៦

១.៣ មហាអយ្យការអមតុលាការកំពូល ........ ៨

**ផ្នែកទី២៖ គោលការណ៍នៃការរៀបចំអង្គការអយ្យការ** ........ ៩

២.១ គោលការណ៍ឯកភាព ........ ៩

២.២ គោលការណ៍អវិភាគ ........ ៩

២.៣ គោលការណ៍ឯករាជ្យ ........ ១០

២.៤ គោលការណ៍មិនទទួលខុសត្រូវ ..... ១១

២.៥ គោលការណ៍មិនប្តឹងផិតចិត្ត ..... ១១

**ផ្នែកទី៣៖ ការជ្រើសរើសព្រះរាជអាជ្ញា** ..... ១១

៣.១ ការចូលបម្រើការជាតំណាងអយ្យការ ..... ១២

៣.១.១ ការចុះកម្មសិក្សា និងការទទួលបានអត្ថប្រយោជន៍ ..... ១២

៣.១.២ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ..... ១៣

៣.២ ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ ..... ១៤

៣.២.១ កាតព្វកិច្ចត្រូវបំពេញ ..... ១៤

៣.២.២ ទណ្ឌកម្មផ្នែកវិន័យ ..... ១៥

**ផ្នែកទី៤៖ តួនាទី ភារកិច្ច សមត្ថកិច្ច និងសិទ្ធិអំណាចរបស់អង្គការអយ្យការ** ..... ១៧

៤.១ តួនាទី ភារកិច្ចរបស់ព្រះរាជអាជ្ញា ..... ១៧

៤.២ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ..... ១៧

៤.៣ សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ..... ១៨

## ជំពូកទី២

## ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ..... ២០

១.១ និយមន័យនៃការតម្កល់រឿងទុកឥតចាត់ការ ..... ២០

១.២ អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការ ..... ២១

**ផ្នែកទី២៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ** ..... ២១

២.១ ការតម្កល់រឿងទុកឥតចាត់ការលើអំពើដែលមិនមែនជាបទល្មើស ..... ២២

២.១.១ នត្ថិភាពនៃបទល្មើស ..................................................................................................... ២២

២.១.២ អវត្តមាននៃបទល្មើស ..................................................................................................... ២៣

២.១.៣ កង្វះធាតុផ្សំនៃបទល្មើស ..................................................................................................... ២៤

២.១.៣.១ ធាតុនីត្យានុកូល ឬធាតុច្បាប់ ..................................................................................... ២៤

២.១.៣.២ ធាតុសត្យានុម័ត ឬធាតុច្បាប់ ..................................................................................... ២៤

២.១.៣.៣ ធាតុអត្តនោម័ត ..................................................................................................... ២៥

២.២ ការតម្កល់រឿងទុកឥតចាត់ការនៅលើអំពើដែលជាបទល្មើស ..................................................... ២៥

២.២.១ កង្វះអត្តសញ្ញាណរបស់ជនល្មើស ..................................................................................... ២៦

២.២.២ បទល្មើសដែលមានព្យសនកម្មតិចតួច ..................................................................................... ២៧

២.២.៣ មូលហេតុគតិយុត្ត ..................................................................................................... ២៧

២.២.៣.១ អភ័យឯកសិទ្ធិ ..................................................................................................... ២៨

២.២.៣.២ អនិយ័តភាពនៃនីតិវិធី ..................................................................................................... ២៩

២.២.៣.៣ ការផុតរលត់នៃបណ្តឹងអាជ្ញា ..................................................................................... ២៩

២.២.៤ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ..................................................................................... ៣២

២.២.៤.១ ជនវិបល្លាសស្មារតី ..................................................................................................... ៣៣

២.២.៤.២ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ..................................................................................... ៣៣

២.២.៤.៣ ការការពារស្របច្បាប់ ..................................................................................................... ៣៣

២.២.៤.៤ សច្ចធារណ៍នៃការពារស្របច្បាប់ ..................................................................................... ៣៤

២.២.៤.៥ ស្ថានភាពចាំបាច់ ..................................................................................................... ៣៤

២.២.៤.៦ អានុភាពនៃកម្លាំង ឬការបង្ខំ ..................................................................................... ៣៥

២.២.៤.៧ អ្នកប្រព្រឹត្តជាអនីតិជន ..................................................................................................... ៣៥

២.៣ មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹង ..................... ៣៥
២.៣.១ ការសម្របសម្រួលជាមួយរដ្ឋ ..................... ៣៦
២.៣.២ ការដកពាក្យបណ្តឹងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ .. ៣៦
២.៣.៣ ការបង់ប្រាក់ពិន័យសរុបនិងប្រាក់ពិន័យសម្របសម្រួល .....................៣៧
២.៤ ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍..................... ៣៨
២.៤.១ កត្តាចំណាត់ការ ..................... ៣៨
២.៤.២ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង ..................... ៣៨
២.៤.៣ កត្តាចារី..................... ៣៩
២.៤.៤ ព្យសនកម្ម..................... ៣៩
២.៤.៥ អំពើល្មើសដែលបង្កព្យសនកម្មតិចតួច ..................... ៣៩
**ផ្នែកទី៣៖ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**.....................៤០
៣.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ .....................៤០
៣.១.១ ការទទួលពាក្យបណ្តឹង.....................៤០
៣.១.២ ការស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែម.....................៤១
៣.១.៣ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ .....................៤១
៣.១.៤ ការជូនដំណឹងទៅភាគីដើមបណ្តឹង ..................... ៤២
៣.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ..................... ៤២
៣.២.១ អានុភាពគ្មានអាជ្ញាអស់ជំនុំទៅលើបណ្តឹងអាជ្ញា ..................... ៤២
៣.២.២ ផ្តើមគិតថិរវេលាអាជ្ញាយុកាលនៃបទល្មើស..................... ៤៣
៣.២.៣ ការរួចផុតពីការចោទប្រកាន់ ..................... ៤៣
៣.២.៤ ការទាមទារវត្ថុដែលរឹបអូសមកវិញ ..................... ៤៣

**ផ្នែកទី៤៖ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ** ........ ៤៣
៤.១ ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ ........ ៤៤
៤.២ បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........ ៤៤
៤.២.១ បុគ្គលដែលអាចដាក់ពាក្យប្តឹង ........ ៤៥
៤.២.២ រយៈពេលនៃការប្តឹងតវ៉ា ........ ៤៥
៤.២.២.១ ការជូនដំណឹងទៅកាន់ជនរងគ្រោះ ........ ៤៥
៤.២.២.២ ការមិនបានទទួលដំណឹងពីការសម្រេចតម្កល់ ........ ៤៥
៤.២.៣ នីតិវិធីប្តឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញា ........ ៤៥
៤.២.៣.១ នីតិវិធីនៃការធ្វើបណ្តឹងតវ៉ា ........ ៤៥
៤.២.៣.២ ចំណាត់ការលើពាក្យបណ្តឹងតវ៉ា ........ ៤៥
៤.៣ អំណាចធ្វើអធិបញ្ជាតាមនាយឋានានុក្រមនៃអង្គការអយ្យការ ........ ៤៦
៤.៣.១ អាជ្ញាធរដែលមានសមត្ថកិច្ចធ្វើអធិបញ្ជា ........ ៤៧
៤.៣.១.១ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ........ ៤៧
៤.៣.១.២ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........ ៤៧
៤.៣.១.៣ ព្រះរាជអាជ្ញា ........ ៤៨
៤.៤ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ........ ៤៩
៤.៤.១ លក្ខខណ្ឌនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ........ ៥០
៤.៤.១.១ អ្នកប្តឹងត្រូវតែជាជនរងគ្រោះនៃបទល្មើស ........ ៥០
៤.៤.១.២ ការដាក់ពាក្យប្តឹង និងកម្មវត្ថុនៃពាក្យប្តឹង ........ ៥០
៤.៤.១.៣ អាជ្ញាធរដែលមានសមត្ថកិច្ចបើកការស៊ើបសួរ ........ ៥១
៤.៤.២ នីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ........ ៥២

៤.៤.៣ ចំណាត់ការលើពាក្យបណ្តឹងដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ........ ៥៣

## ជំពូកទី៣

## គុណសម្បត្តិ និងគុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ផ្នែកទី១៖ គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ........ ៥៤

១.១ ការទទួលបានផលប្រយោជន៍របស់ជនសង្ស័យពីការតម្កល់រឿងទុកឥតចាត់ការ ........ ៥៤

១.២ ការកាត់បន្ថយការកកស្ទះសំណុំរឿង ........ ៥៥

១.៣ ការកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ ........ ៥៥

១.៤ ការផ្តល់លទ្ធភាពដល់ជនដែលប្រព្រឹត្តកំហុសអាចកែប្រែខ្លួន និងកសាងសង្គមជាតិ ........ ៥៧

**ផ្នែកទី២៖ គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ........ ៥៨

២.១ ការខូចខាតផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ........ ៥៨

២.២ វប្បធម៌អន្តរាគមន៍ពីអ្នកមានអំណាច ........ ៥៩

២.៣ ការសម្រេចសេចក្តីដោយមិនទាន់មានការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយ ........ ៥៩

២.៤ ការសម្រេចសេចក្តីដោយលម្អៀង ........ ៦០

២.៥ មនុស្សក្នុងសង្គមអាចមើលស្រាលច្បាប់ ........ ៦០

**សេចក្តីសន្និដ្ឋាន** ........ ៦១

**អនុសាសន៍** ........ ៦៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ជាប្រទេសមួយដែលបានប្រកាន់យកបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ពោលគឺអំណាចរបស់រដ្ឋត្រូវបែងចែកជាបី រួមមាន៖ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ។ ហើយអំណាចនីមួយៗ មានការបែងចែកដាច់ពីគ្នាមិនមានអំណាចណាមួយជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងបានឡើយប៉ុន្តែអំណាចនីមួយៗមានការទំនាក់ទំនងគ្នាយ៉ាងល្អនៅក្នុងការកសាងជាតិតាមរយៈបទប្បញ្ញត្តិនានា។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងនៅក្នុងការបង្កើតច្បាប់ សម្រាប់ជាការការពារផលប្រយោជន៍សាធារណៈ រក្សាសន្តិសុខសង្គមតាមរយៈការបង្កើតឱ្យមាន ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលបំណងដាក់ទោសដល់ជនដែលបានប្រព្រឹត្តខុសច្បាប់ ឬបទល្មើសច្បាប់ដែលមានចែងជាធរមាន និងដើម្បីថែរក្សាស្ថេរភាពរបស់សង្គមឱ្យមានភាពសុខសន្តិភាព នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយដើម្បីចូលរួមបង្ការ ទប់ស្កាត់ នូវបទល្មើសដែលកើតមានឡើងរាជរដ្ឋាភិបាល ក្រើនរំឭកដល់មន្ត្រីអនុវត្តច្បាប់ត្រូវរឹតបន្តឹងក្នុងការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងម៉ត់ចត់បំផុត។

ជាមួយគ្នានេះដែរនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានគោលការណ៍នៃការចោទប្រកាន់ ២ ( ពីរ ) គឺគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

ដោយគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ត្រូវបានយកមកប្រើប្រាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ នៅពេលដែលមានបទល្មើសកើតឡើងព្រះរាជអាជ្ញាត្រូវតែធ្វើការប្តឹងចោទប្រកាន់ដោយមិនគិតថាជារឿងតូចតាច ឬមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមតិចតួចនោះទេឱ្យតែមានបទល្មើសកើតឡើងព្រះរាជអាជ្ញាត្រូវធ្វើការប្តឹងចោទប្រកាន់ទាំងអស់។ ហើយព្រះរាជអាជ្ញាគ្មានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការនោះទេ។ គោលការណ៍នេះគឺគ្មានការរំលោភបំពានច្បាប់ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននោះទេ ដោយសារព្រះរាជអាជ្ញាប្រកាន់យកគោលការណ៍អព្យាក្រឹត្យ និងឯករាជ្យដោយមិនរណបទៅនឹងអង្គការណាមួយឡើយ។ ក៏ប៉ុន្តែគោលការណ៍នេះមិនផ្តល់ពេលគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាង និងធ្វើឱ្យមានភាពយឺតយ៉ាវដោយសារមានការកកស្ទះសំណុំរឿង មូលហេតុបែបនេះទើបបានជានាំឱ្យមានគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

ចំពោះគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញត្រូវបានយកមកប្រើប្រាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌសម័យបច្ចុប្បន្ន ហើយព្រះរាជអាជ្ញាមានសិទ្ធិពិចារណាក្នុងការសម្រេចថាគួរធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ដោយអំណាចឆន្ទានុសិទ្ធិរបស់តំណាងអយ្យការ ទើបមិនមានការកកស្ទះសំណុំរឿងនៅក្នុងតុលាការ តែក៏អាចមានការរំលោភអំណាចក្នុងការប្រើប្រាស់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរទៅ

លើការតម្កល់រឿងទុកឥតចាត់ការ។ ដោយសារតែមានគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះហើយ ទើបបណ្តាលឱ្យតំណាងអយ្យការមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការថ្លឹងថ្លែងទៅលើសំណុំរឿងដើម្បីសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។ ដូច្នេះហើយដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីវិសាលភាពនៃនីតិវិធីនេះ ព្រមទាំងអំពីគោលការណ៍ តួនាទី សិទ្ធិអំណាច មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលស្តីអំពី "**ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**" មកធ្វើការសិក្សាស្រាវជ្រាវ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមការសិក្សា និងស្រាវជ្រាវកន្លងមក ដើម្បីឱ្យយល់កាន់តែច្បាស់ទាក់ទងទៅនឹងការតម្កល់រឿងទុកឥតចាត់ការដែលជានីតិវិធីយ៉ាងសំខាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌនោះ យើងខ្ញុំបានកំណត់ចេញជាបញ្ហាគតិយុត្តមួយចំនួនៈ

- តើអង្គការអយ្យការជាអ្វី? ហើយអង្គការអយ្យការមានតួនាទី និងភារកិច្ចអ្វីខ្លះ?
- តើអ្វីទៅជាការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ? ហើយការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះមានមូលហេតុបែបណា និងត្រូវធ្វើឡើងដោយនីតិវិធីអ្វីខ្លះ? និងមានអានុភាពបែបណា?
- តើការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការបកស្រាយពាក់ព័ន្ធប្រធានបទខាងលើត្រូវបានលើកឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់បន្ថែមពាក់ព័ន្ធអំពីភាពមិនច្បាស់លាស់ និងចម្ងល់មួយចំនួនក៏ដូចជាចង់ស្រាយបំភ្លឺអំពីបញ្ហាគតិយុត្តដូចដែលបានលើកឡើងខាងលើក៏ដូចជាពង្រឹង និងពង្រីកនូវសមត្ថភាពចំណេះដឹងផ្ទាល់ខ្លួនបន្ថែមទៀតដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌផងដែរ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ គឺមានវិសាលភាពគ្របដណ្តប់លើទ្រឹស្តី និងទិដ្ឋភាពជាក់ស្តែងនូវតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលបានអនុវត្តចាត់តាំងពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៤។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទនេះត្រូវបានចងក្រងឡើងមានសារៈប្រយោជន៍ និងក្លាយជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកអានគ្រប់រូប ព្រមទាំងទុកដើម្បីជាឯកសារដល់សិស្សនិស្សិតជំនាន់ក្រោយៗបានយល់ដឹងកាន់តែច្បាស់អំពី ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទនេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់នូវវិធីសាស្ត្របែបវិភាគទ្រឹស្តី និងអនុវត្តជាក់ស្តែង។ ជាពិសេសផ្តោតលើការវិភាគទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវប្រធានបទនេះ យើងខ្ញុំបានធ្វើការដកស្រង់ចេញពីប្រភពសៀវភៅគេហទំព័រផ្លូវការ ទាំងប្រភពច្បាប់សំខាន់ៗ និងលិខិតបទដ្ឋានគតិយុត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឯកសារពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យបានយល់ស៊ីជម្រៅ និងមានភាពងាយស្រួលយើងខ្ញុំនឹងធ្វើការបែងចែកជាផ្នែកសំខាន់ៗចំនួនបីដែលនឹងត្រូវធ្វើការបែងចែកចេញជាជំពូកដូចជា៖

ជំពូកទី១៖ អង្គការអយ្យការ

ជំពូកទី២៖ ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ជំពូកទី៣៖ គុណសម្បត្តិ និងគុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

# ជំពូកទី១

# អត្ថការអេយ្យការ

# ជំពូកទី១

# អង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការបណ្ដឹងសាធារណៈ ឬបណ្ដឹងព្រហ្មទណ្ឌ។[1] ពាក្យថា "អយ្យការ" គឺជាស្ថាប័នមួយ ដូចនេះពាក្យថា "អង្គការអយ្យការ" គឺជាស្ថាប័នអយ្យការទាំងឡាយដែលត្រូវបានដាក់ពង្រាយឱ្យអមនៅតាមសាលាជម្រះក្ដីនីមួយៗគ្រប់ជាន់ថ្នាក់។ អង្គការអយ្យការគឺជាស្ថាប័នមួយតំណាងឱ្យស្ថាប័ននីតិប្បញ្ញត្តិដែលនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ហើយមានតួនាទីថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ។ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។[2] អង្គការអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[3] មានន័យថាអង្គការអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើសទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍របស់សង្គមជាតិ ឬសាធារណៈផងដែរ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌជាពិសេសធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនតំណាងអយ្យការ មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន។ អង្គការអយ្យការត្រូវមានវត្តមាននៅក្នុងពេលសវនាការរឿងក្ដីព្រហ្មទណ្ឌ។[4]

អង្គការអយ្យការ គឺជាស្ថាប័នឯករាជ្យដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្ដីដែលខ្លួននៅអមនោះទេហើយសាលាជម្រះក្ដីទៀតសោតគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងាររបស់ខ្លួនក៏ដោយ សាលាជម្រះក្ដីមិនត្រូវចុះក្នុងសេចក្ដីសម្រេចរបស់ខ្លួន និងមិនអាចស្ដីបន្ទោសអ្វីដល់ព្រះរាជអាជ្ញាឡើយ។ ចំពោះការហាមឃាត់នេះទាំងក្នុងរឿងក្ដីព្រហ្មទណ្ឌ និងរឿងក្ដីផ្សេងៗ។

## ផ្នែកទី១៖ រចនាសម្ព័ន្ធនៃអង្គការអយ្យការ

ស្ថាប័នអយ្យការមាន ៣ (បី) ថ្នាក់ ដែលថ្នាក់នីមួយៗស្ថិតទៅតាមតុលាការទាំងបីដូចគ្នា។ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលតំណាងដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។ មហាអយ្យការអមសាលាឧទ្ធរណ៍ តំណាងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា

[1] សូមមើល កុយ នាម និងឡុង បញ្ញាវុឌ្ឍ, អង្គការអយ្យការ (ប្រវត្តិ និងការសិក្សាប្រៀបធៀប) បោះពុម្ពលើកទី១,ឆ្នាំ២០០៦ ទំព័រទី៤៥

[2] មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញ

[3] មាត្រា៤ កថាខណ្ឌ២ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[4] មាត្រា២៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អមសាលាឧទ្ធរណ៍។ មហាអយ្យការអមតុលាការកំពូលតំណាងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល និងព្រះរាជអាជ្ញាអមតុលាការកំពូល។[5]

## ១.១. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាតំណាងស្ថាប័នអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។[6] ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិអំណាចក្នុងការដឹកនាំ និងសម្របសម្រួលដល់សកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីខ្លួន អាចធ្វើអធិការកិច្ចបានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយអាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។[7] ព្រះរាជអាជ្ញារងស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងការប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[8]

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ដោយផ្អែកលើសេចក្តីសម្រេចដែលមានសំអាងហេតុ និងសំអាងច្បាប់ សេចក្តីសម្រេចនៃការតម្កល់រឿងទុកឥតចាត់ការមិនមានអាជ្ញាអស់ជំនុំទេ គឺជៀសមិនផុតពីការប្តឹងតវ៉ាឡើយ។ ដូចនេះស្ថាប័នអយ្យការដែលមានតំណាងអយ្យការជាព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងមានសិទ្ធិអំណាចសើរើសំណុំរឿងឡើងវិញដរាបណាអាជ្ញាយុកាលនៃបណ្តឹងមិនទាន់រលត់ បន្ទាប់ពីទទួលបណ្តឹងតវ៉ាពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ដែលជាតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំរឿងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

ផ្អែកតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការបានកំណត់ថា អយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសមាសភាពដូចជា៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[9]

[5] មាត្រា២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[6] មាត្រា៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[7] មាត្រា៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[8] មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[9] មាត្រា ២៩ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤ ។

## ១.២. មហាអយ្យការអមសាលាឧទ្ធរណ៍

តំណាងអយ្យការអមសាលាឧទ្ធរណ៍ គឺមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា[10] នៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ហើយសាលាឧទ្ធរណ៍ជាសាលាជម្រះក្តីថ្នាក់ទីពីរ រួមមានសាលាឧទ្ធរណ៍រាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ថ្នាក់តំបន់។[11] បច្ចុប្បន្ននេះសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។ ដោយផ្អែកតាមព្រះរាជក្រឹត្យលេខ នស/រកត/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីដាក់ដំណើរការសាលាដំបូងភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីដាក់ដំណើរការសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីដាក់ដំណើរការសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីដាក់ដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់។

- **សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ:** មានសមត្ថកិច្ចជំនុំជម្រះក្តីដែលនៅក្នុងសមត្ថកិច្ចដែនដីគ្របដណ្តប់លើរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីដែលមិនស្ថិតក្រោមសមត្ថកិច្ចឧទ្ធរណ៍តំបន់ លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។[12]
- **សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ:** ត្រូវទទួលបន្ទុកដោះស្រាយបណ្តឹងសាលាឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់សាលាដំបូងកំពង់ចាម និងអយ្យការអមសាលាដំបូងកំពង់ចាម សាលាដំបូងកំពង់ធំ និងអយ្យការអមសាលាដំបូងកំពង់ធំ សាលាដំបូងព្រះវិហារ និងអយ្យការអមសាលាដំបូងព្រះវិហារ សាលាដំបូងរតនគិរី និងអយ្យការអមសាលាដំបូងរតនគិរី សាលាដំបូងមណ្ឌលគិរី និងអយ្យការអមសាលាដំបូងមណ្ឌលគិរី សាលាដំបូងស្វាយរៀង និង

[10] មាត្រា ៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[11] មាត្រា ៣៥ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

[12] មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

អយ្យការអមសាលាដំបូងស្វាយរៀង និងចុងក្រោយសាលាដំបូងត្បូងឃ្មុំ និងអយ្យការអមសាលាដំបូងត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពុលបង្វិលមកវិញ។[13]

- **សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង:** មានទីតាំងនៅខេត្តបាត់ដំបង និងមានដែនសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីដែលស្ថិតក្នុងដែនសមត្ថកិច្ចដែនដីគ្របដណ្ដប់លើខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប លើកលែងតែរឿងក្ដីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។[14]
- **សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ:** មានទីតាំងនៅខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្ដប់លើខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប លើកលែងតែរឿងក្ដីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។[15]

បើយោងទៅតាមមាត្រា ៣៤ និងមាត្រា ៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់ត្រួតពិនិត្យនៅក្នុងសមត្ថកិច្ចដែនដី នៃសាលាឧទ្ធរណ៍របស់ខ្លួន ដូចជាមន្ត្រីនគរបាលយុត្តិធម៌ជាដើម អគ្គព្រះរាជអាជ្ញាអាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ឱ្យមកពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនេះ។ អគ្គព្រះរាជអាជ្ញាមានសិទ្ធិប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ឱ្យបំពេញភារកិច្ចទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌ និងធ្វើអធិការកិច្ចគ្រប់ពេលទៅលើអង្គភាពនគរបាលយុត្តិធម៌។ សាលាឧទ្ធរណ៍ជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងជំទាស់កើតទុក្ខមិនសុខចិត្តលើសេចក្ដីសម្រេចរបស់តុលាការជាន់ទាបដែលជាសាលាដំបូងរាជធានី-ខេត្ត មហាអយ្យការអមសាលាឧទ្ធរណ៍អាចទទួលសំណុំរឿងក្ដីព្រហ្មទណ្ឌណាមួយមកចាត់ការ លុះត្រាតែអយ្យការអមសាលាដំបូងរាជធានី-ខេត្តសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ បើមានបណ្ដឹងឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនោះទើបអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ធ្វើការបញ្ជូនមកមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យចាត់ការបន្ត។

យោងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការមហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចជាៈ

[13] ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩
[14] ព្រះរាជក្រឹត្យលេខ នស/រកត/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩
[15] ព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាឧទ្ធរណ៍។[16]

## ១.៣. មហាអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃមហាអយ្យការអមតុលាការកំពូល[17] ដែលតុលាការមានតែមួយគត់នៅរាជធានីភ្នំពេញ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់ នៅពេលដែលមានបណ្ដឹងសាទុក្ខ បណ្ដឹងសើរើ និងបណ្ដឹងតវ៉ាផ្សេងៗទៀត ដែលដាក់ទៅតុលាការកំពូលដើម្បីពិនិត្យ[18] និងចូលរួមដឹកនាំដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលផងដែរ។ បើយោងទៅតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា៧០ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលទទួលសេចក្ដីសន្និដ្ឋានពីអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យមុនពេលសវនាការ។ នៅពេលដែលអគ្គព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញា ហើយមហាអយ្យការអមតុលាការកំពូលមិនយល់ព្រមធ្វើតាម។ អគ្គព្រះរាជអាជ្ញាអាចមានសិទ្ធិក្នុងការចាត់តាំងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ឬចាត់តាំងខ្លួនឯងផ្ទាល់ធ្វើជាតំណាងអយ្យការនៅក្នុងពេលសវនការ។

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលជាអ្នកធ្វើសេចក្ដីសន្និដ្ឋានទៅ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងធ្វើការកត់សម្គាល់ដោយសេរីភាពតាមសម្បជញ្ញៈរបស់ខ្លួនដោយគ្មានការចោទប្រកាន់ខាងវិន័យណាមួយ នៅពេលដែលធ្វើជាតំណាងមហាអយ្យការដោយមានការចាត់តាំងដោយអគ្គព្រះរាជអាជ្ញា ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលត្រូវទទួលការពិនិត្យពីអគ្គព្រះរាជអាជ្ញាដោយផ្ទាល់។

នៅតុលាការកំពូល គឺជាសាលាជម្រះក្ដីជាន់ខ្ពស់ និងចុងក្រោយបង្អស់ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ាមានលក្ខណៈស្ថាពរ។ យោងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៅមហាអយ្យការអមតុលាការកំពូលមានសមាសភាព ដូចជា៖

[16] មាត្រា ៤៩ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

[17] មាត្រា ៣១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[18] មាត្រា ៣២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមតុលាការកំពូល ។[19]

## ផ្នែកទី២៖ គោលការណ៍នៃការរៀបចំអង្គការអយ្យការ

ស្របតាមស្មារតីនៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានចែងច្បាស់អំពីគោលការណ៍សំខាន់ៗនៃអង្គការអយ្យការដែលមានដូចខាងក្រោម៖

### ២.១ គោលការណ៍ឯកភាព

អង្គការអយ្យការ គឺជាអង្គការឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។[20] តួនាទី និងភារកិច្ចនៅតាមបណ្តាសាលាជម្រះក្តីនីមួយៗត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យពីសំណាក់ថ្នាក់លើរបស់ខ្លួនតាមលំដាប់ឋានានុក្រមរបស់អង្គការអយ្យការ។ លើសពីនេះទៅទៀត សូម្បីតែវឌ្ឍភាពនៃការងាររបស់ខ្លួនក៏តំណាងអយ្យការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំរបស់ខ្លួនដែរ។ ជាគោលការណ៍រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជានាយឋានានុក្រមដែលមានលំដាប់ខ្ពស់ជាងគេអាចប្តឹងបរិហារពីបទល្មើសដែលខ្លួនបានដឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងបាន ហើយក៏អាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅកាន់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានណាមួយពីបទល្មើសទៅតាមអ្វីដែលខ្លួនយល់ឃើញថាជាការគួរ។

ការគោរពតាមនាយឋានានុក្រមនៃអង្គការអយ្យការដែលបានធ្វើអធិបញ្ជា គឺជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញា ប៉ុន្តែគួរកត់សម្គាល់ថានៅក្នុងដំណើរការសវនាការនៃរឿងក្តីព្រហ្មទណ្ឌ ចៅក្រមអយ្យការអាចធ្វើកំណត់សម្គាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របតាមសម្បជញ្ញៈរបស់ខ្លួន។

[19] មាត្រា៦៨ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ ២០១៤

[20] មាត្រា៧៥ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

## ២.២ គោលការណ៍អវិភាគ

អង្គការអយ្យការ គឺជាអង្គអវិភាគដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។[21] គោលការណ៍នេះអនុញ្ញាតឱ្យតំណាងអយ្យការច្រើនរូបអាចសហការគ្នា ចំពោះបទល្មើសតែមួយបានក្នុងនាមជាអ្នកតំណាងរបស់រដ្ឋសម្រាប់ដំណើរការ ឬធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដើម្បីការពារផលប្រយោជន៍របៀបរៀបរយសង្គមរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ គោលការណ៍នេះមានន័យថានៅពេលដែលព្រះរាជអាជ្ញាទទួលបន្ទុកសំណុំរឿងណាម្នាក់អវត្តមាន ដោយសារតែមូលហេតុផ្សេងទាំងដែលសំណុំរឿងមិនទាន់បានបញ្ចប់នៅឡើយ នោះព្រះរាជអាជ្ញាម្នាក់ផ្សេងទៀតដែលបំពេញមុខងារនៅក្នុងសាលាជម្រះក្តីជាមួយគ្នាអាចជំនួសរាល់ការងារបានតាមការចាត់តាំងរបស់នាយឋានានុក្រម។

សញ្ញាណនៃគោលការណ៍អវិភាគនេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តំណាងអយ្យការ ព្រោះដោយហេតុថាប្រសិនបើគ្មានគោលការណ៍នេះទេ នោះនឹងនាំឱ្យមានការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តីនីមួយៗជាមិនខាន។

## ២.៣ គោលការណ៍ឯករាជ្យ

អង្គការអយ្យការ គឺជាអង្គការឯករាជ្យដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមឡើយ។[22] បានសេចក្តីថាអង្គការអយ្យការ និងសាលាជម្រះក្តីនីមួយៗមានភាពដាច់ដោយឡែកពីគ្នារាល់ការងាររបស់អយ្យការពុំត្រូវបានស្ថិតក្រោមការត្រួតពិនិត្យរបស់ប្រធានសាលាជម្រះក្តីឡើយ។ គោលការណ៍នេះនាំឱ្យមានការផ្ទុយគ្នារវាងឋានានុក្រមនៃសាលាជម្រះក្តី និងឋានានុក្រមនៃអង្គការអយ្យការ។ ការចាត់ទុកថាវាមានភាពផ្ទុយគ្នានេះ គឺដោយសារតែអង្គការអយ្យការស្ថិតអមសាលាជម្រះក្តីក៏ពិតមែន ប៉ុន្តែមិនស្ថិតក្រោមការត្រួតពិនិត្យ ឬអំណាចរបស់សាលាជម្រះក្តីទេ បែរជាត្រូវស្ថិតនៅក្រោមឋានានុក្រមនៃអង្គការអយ្យការទៅវិញ។ ម៉្យាងវិញទៀតនោះទោះបីអង្គការអយ្យការស្ថិតនៅអមនឹងសាលាជម្រះក្តីក៏ដោយ ក៏សាលាជម្រះក្តីពុំមានសិទ្ធិអំណាចណាមួយសម្រាប់ត្រួតពិនិត្យចំពោះការបំពេញកាតព្វកិច្ច និងកិច្ចដំណើរការជាប្រក្រតីរបស់អយ្យការឡើយ។ ក្នុងករណីដែលព្រះរាជអាជ្ញាប្រព្រឹត្តកំហុសក្នុងមុខងាររបស់ខ្លួនសាលាជម្រះក្តី ឬស្ថាប័នតុលាការដែលព្រះរាជអាជ្ញានៅអមនោះមិនអាចធ្វើការស្តីបន្ទោស ឬដាក់វិន័យណាមួយទៅលើកំហុសឆ្គងបានឡើយ។ សាលាជម្រះក្តីមិនអាចសរសេររិះគន់ចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាបាននោះទេ ទោះបីជាការសម្រេចនោះមានភាពមិនប្រក្រតីក៏ដោយ ប៉ុន្តែចៅក្រមនៃសាលាជម្រះក្តីអាចជូនព័ត៌មានពីសេចក្តីសម្រេចនោះទៅនាយឋានានុក្រមរបស់

[21] មាត្រា៧៥ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[22] មាត្រា៧៥ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ព្រះរាជអាជ្ញាបាន។ លើសពីនេះរាល់សំណុំរឿងដែលព្រះរាជអាជ្ញាបានទទួលថៅក្រមនៃសាលាជម្រះក្តីក៏ពុំអាចធ្វើសេចក្តីណែនាំ ឬបង្គាប់បញ្ជាឱ្យព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋាន ឬធ្វើការចោទប្រកាន់បទល្មើសឡើយ។

## ២.៤ គោលការណ៍មិនទទួលខុសត្រូវ

ជាគោលការណ៍ ព្រះរាជអាជ្ញាមិនទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយចំពោះការសម្រេចដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាព្រះរាជអាជ្ញាឡើយ។[23] ប្រសិនបើតំណាងអយ្យការចោទប្រកាន់បទល្មើសចំពោះជនណាម្នាក់ដោយមានសំអាងហេតុច្បាស់លាស់ថាជននោះបានប្រព្រឹត្តបទល្មើសពិតប្រាកដ ហើយការចោទប្រកាន់ត្រូវបានច្រានចោលដោយចៅក្រមស៊ើបសួរជាពិសេសការសម្រេចលើកលែងដោយចៅក្រមជំនុំជម្រះ ក្នុងដំណាក់កាលជំនុំជម្រះ តំណាងអយ្យការមិនទទួលខុសត្រូវចំពោះព្យសនកម្ម ចំពោះភាគីនៃរឿងក្តីឡើយ។ គួរបញ្ជាក់ផងដែរថាសូមកុំមានការយល់ច្រឡំថាគោលការណ៍មិនទទួលខុសត្រូវនេះអាចអនុវត្តទាំងបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តដោយតំណាងអយ្យការអាចត្រូវបានធ្វើការចោទប្រកាន់តាមផ្លូវតុលាការ នេះបើយោងតាមមាត្រា ៥៧ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

## ២.៤ គោលការណ៍មិនប្តឹងជិតចិត្ត

តំណាងអយ្យការមិនត្រូវបានធ្វើបណ្តឹងជិតចិត្តចំពោះសមាសភាពរបស់ខ្លួនឡើយ ទោះបីជាតំណាងអយ្យការនោះមានទំនាក់ទំនងផលប្រយោជន៍ក្នុងរឿងក្តីក៏ដោយ។ ការដែរយល់ដូចនេះគឺជារឿងត្រឹមត្រូវដោយហេតុថា ការអនុវត្តតួនាទីភារកិច្ចរបស់ព្រះរាជអាជ្ញា គឺក្នុងនាមតំណាងឱ្យផលប្រយោជន៍រដ្ឋ និងសង្គមមិនមែនបុគ្គលឡើយ។ ម៉្យាងវិញទៀតមិនមែនចៅក្រមអយ្យការ ឬតំណាងអយ្យការមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យពីទោសកំហុសរបស់បុគ្គលណាឡើយ ហើយក៏មិនមែនគ្រប់ការចោទប្រកាន់របស់តំណាងអយ្យការសុទ្ធតែត្រូវបានផ្តន្ទាទោសនោះទេ។ លើសពីនេះដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រង់មាត្រា ៥៥៦ បានចែងថា "បណ្តឹងជិតចិត្តអាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ"។[24] ការចាត់ទុកថាអយ្យការមិនត្រូវបានអនុញ្ញាតឱ្យមានការធ្វើបណ្តឹងជិតចិត្តនេះ ក៏ដោយសារអយ្យការ គឺម្ចាស់បណ្តឹងអាជ្ញាឬអាចនិយាយម៉្យាងទៀតថាជាភាគីនៃរឿងក្តីព្រហ្មទណ្ឌ ជារឿងដែលមិនអាចទៅរួចសោះឡើយ ដែលភាគីម្ខាងនៃរឿងក្តីអាចធ្វើបណ្តឹងជិតចិត្តចំពោះភាគីម្ខាងទៀតបានក្នុងដំណើរការនៃរឿង។

[23] មាត្រា៦ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[24] មាត្រា៥៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី៣៖ ការជ្រើសរើសព្រះរាជអាជ្ញា

តំណាងអយ្យការ គឺជាមន្រ្តីដែលបម្រើការនៅតាមស្ថាប័នអយ្យការនីមួយៗ ហើយតំណាងអយ្យការជាបុគ្គលមានតួនាទីសំខាន់បំផុតនៅក្នុងស្ថាប័នរបស់ខ្លួន។

### ៣.១ ការចូលបម្រើការជាតំណាងអយ្យការ

មុននឹងឈានដល់ការបម្រើការងារជាតំណាងអយ្យការ ព្រះរាជអាជ្ញាត្រូវធ្វើការចុះកម្មសិក្សា និងទទួលបានអត្ថប្រយោជន៍ពីការចុះកម្មសិក្សា បន្ទាប់មកទៀតទើបឈានទៅដល់ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ។

#### ៣.១.១ ការចុះកម្មសិក្សា និងការទទួលបានអត្ថប្រយោជន៍

បន្ទាប់ពីធ្វើការប្រឡងប្រជែងជ្រើសរើស និងទទួលបានការបណ្តុះបណ្តាលនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការហើយ “ សិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាព្រះរាជអាជ្ញាកម្មសិក្សាក្នុងឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេលមួយឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង”។[25]

“ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សាមានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ”។[26] ចំណែកឯអត្ថប្រយោជន៍ដែលទទួលបានវិញនោះគឺ បន្ទាប់ពីបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។[27] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើរថ្វាយព្រះមហាក្សត្រអំពីការតែងតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើរដ្ឋមន្រ្តីក្រសួងយុត្តិធម៌។ ប៉ុន្តែចំពោះព្រះរាជអាជ្ញាកម្មសិក្សា ដែលធ្វើកម្មសិក្សាពុំទាន់បានជោគជ័យ ឬដោយមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពីចំនួន ៣០ថ្ងៃ នោះរដ្ឋមន្រ្តីក្រសួងយុត្តិធម៌អាចសម្រេចឱ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សារយៈពេល០១ឆ្នាំបន្ថែមទៀត។ ម្យ៉ាងវិញទៀត “ប្រសិនបើព្រះរាជអាជ្ញាកម្មសិក្សាឈប់ដោយគ្មានការអនុញ្ញាតច្បាប់លើសពី៣០ថ្ងៃ ឬមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែមត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា”[28] ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៨៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។[29]

[25] មាត្រា៨៣ កថាខណ្ឌទី១ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[26] មាត្រា៨៣ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[27] មាត្រា៨៤ កថាខណ្ឌទី១ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[28] មាត្រា៨៤ កថាខណ្ឌទី៣ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[29] មាត្រា៨៥ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

អនុលោមតាមបទប្បញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ព្រះរាជអាជ្ញាកម្មសិក្សាដែលពុំមានសម្បទារគ្រប់គ្រាន់ ឬសុខភាពមិនគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារដោយមិនមានភាពពេញលេញនោះអាចនិងត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបានគ្រប់ពេលវេលា។[30] “ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញាត្រូវធ្វើឡើងក្នុងរយៈពេល ០៣ខែយ៉ាងយូរ ក្រោយពីបញ្ចប់ការសិក្សា”។[31]

### ៣.១.២ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ

បន្ទាប់ពីព្រះរាជអាជ្ញាធ្វើការចុះកម្មសិក្សាតាមរយៈពេលដែលត្រូវបានកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ “ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាពស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ”។[32] ដើម្បីអាចចុះឈ្មោះក្នុងតារាងដំឡើងបានចៅក្រម ឬព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចចំនួន០២ គឺ ទី១ គាត់ត្រូវបម្រើការងារក្រោយបានទទួលការតាំងស៊ប់ក្នុងក្របខណ្ឌ និងទី២ គឺគាត់ត្រូវស្ថិតក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិចពីរឆ្នាំ។ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋានដូចជា៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អមិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយស នៃអង្គចៅក្រមឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។[33]

គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឯកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងផ្តល់យោបល់។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវរៀបចំតារាងចុះឈ្មោះព្រះរាជអាជ្ញាដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ។[34]

---

[30] មាត្រា៨៥ កថាខណ្ឌទី១ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
[31] មាត្រា៨៥ កថាខណ្ឌទី២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
[32] មាត្រា២៧ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
[33] មាត្រា២៨ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
[34] មាត្រា៤៨ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

## ៣.២ ភាពទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ

ក្នុងនាមជាតំណាងអយ្យការ "ព្រះរាជអាជ្ញាត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងគោរពឱ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន"។[35] មានន័យថាព្រះរាជអាជ្ញាត្រូវតែអនុវត្តកិច្ចការទាំងឡាយដែលខ្លួនត្រូវបំពេញ ដោយមានទំនួលខុសត្រូវខ្ពស់ចំពោះកិច្ចការទាំងនោះ។

### ៣.២.១ ភាតព្វកិច្ចត្រូវបំពេញ

ព្រះរាជអាជ្ញាត្រូវបំពេញតួនាទី ក៏ដូចជាភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវនិងម៉ឺងម៉ាត់ និងមានភាពឆាប់រហ័សដោយស្របទៅតាមច្បាប់កំណត់ និងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដូចជាការលើកកម្ពស់សិទ្ធិមនុស្សដោយរួមជាវិភាគក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ។ ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ៖[36]

- អនុវត្តតួនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយឡើយ។
- ការពារផលប្រយោជន៍សាធារណៈយកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះ។
- មិនលំអៀង និងត្រូវមានការប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតប្រយោជន៍ដល់ជនសង្ស័យក៏ដោយ។
- រក្សារឿងក្តីជាសម្ងាត់លើកលែងតែក្នុងករណីត្រូវបំពេញភារកិច្ច ឬករណីដើម្បីស្វែងរកយុត្តិធម៌។
- ពិនិត្យមើលពីទិដ្ឋភាពទូទៅនិងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដើម្បីឱ្យស្របតាមសេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងការរំលោភអំណាច។

លើសពីនេះទៅទៀតក្នុងនាមជាតំណាងអយ្យការ ព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរដូចជា "មិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឱ្យអាប់ឱន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គការអយ្យការឡើយ"។[37] ជាងនេះទៅទៀតព្រះរាជអាជ្ញាដែលកំពុងតែបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ដែលមានបំណងផ្សព្វផ្សាយនូវអត្ថបទ ឬការសរសេរសំណៅឯកសារក៏ដូចជាមតិផ្សេងៗដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ នោះត្រូវតែសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយ ចំពោះការធ្វើសេចក្តី

[35] មាត្រា៩៦ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[36] គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា,អនុម័តដោយសមាជអង្គការប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើសនាទីក្រុងហាវ៉ាណា ប្រទេសគុយបា,នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០,ចំណុចទី១៣

[37] មាត្រា៩៦ កថាខណ្ឌទី២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ថ្លែងការជាសាធារណៈរបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។[38] ក្នុងករណីព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវឥរិយាបទអព្យាក្រឹតក្នុងវិស័យនយោបាយ។

ព្រះរាជអាជ្ញាទាំងអស់មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ។ ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើសំណើរសុំអនុញ្ញាតអវត្តមានជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការសម្រេចអំពីការស្នើសុំនេះ។

ក្រៅពីនេះក្នុងវិជ្ជាជីវៈព្រះរាជអាជ្ញាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈដូចជា មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិកា មុខងារទទួលអាណត្តិដោយបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រមជាដើម។ បន្ថែមពីលើនេះ ព្រះរាជអាជ្ញា មិនអាចបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ឬប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម។

ចំពោះព្រះរាជអាជ្ញាដែលត្រូវបានអនុញ្ញាតឱ្យនៅទំនេរហើយមានបំណងចង់ប្រកបការងារឯកជននោះត្រូវធ្វើការជូនដំណឹងទៅដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីធ្វើការថ្លឹងថ្លែងថាគួរអនុញ្ញាតឱ្យឬយ៉ាងណាក្នុងករណីនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើការជំទាស់ទៅនឹងការមិនឱ្យប្រកបការងារបាន ប្រសិនបើគាត់យល់ឃើញថាសកម្មភាពនៃការប្រកបការងារនេះមានលក្ខណៈផ្ទុយនិងកិត្តិយស ឬសេចក្ដីទៀងត្រង់ ឬធ្វើឱ្យខូចកិត្យានុភាពនៃមុខងារព្រះរាជអាជ្ញា។

ក្នុងករណីដែលមានការបំពាននូវកាតព្វកិច្ចវិជ្ជាជីវៈណាមួយ ព្រះរាជអាជ្ញានឹងទទួលទណ្ឌកម្មវិន័យដែលសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

### ៣.២.២ ទណ្ឌកម្មផ្នែកវិន័យ

យោងតាមច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានៅពេលដែលព្រះរាជអាជ្ញាបានប្រព្រឹត្តអំពើដែលផ្ទុយពីកាតព្វកិច្ចវិជ្ជាជីវៈ ព្រះរាជអាជ្ញាត្រូវតែទទួលទណ្ឌកម្មផ្នែកវិន័យដូចនឹងចៅក្រមដែរ។[39] យោងតាមមាត្រា ៥៤ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិថា "កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីល

[38]មាត្រា៩៦ កថាខណ្ឌទី៣ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[39]មាត្រា៩៩ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ធម៌របស់ចៅក្រម និងព្រះរាជអាជ្ញានាំឱ្យមានទណ្ឌកម្មខាងវិន័យតាមបទប្បញ្ញត្តិនៃច្បាប់នេះ ប៉ុន្តែការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ"។[40]

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានកំណត់ថា"ទណ្ឌកម្មវិន័យមិនមែនឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្ត"[41] ក្នុងន័យនេះប្រសិនបើអំពើដែលព្រះរាជអាជ្ញាបានប្រព្រឹត្តនោះ គឺជាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌហើយក៏ជាអំពើដែលផ្ទុយប្រាសចាកនឹងកាតព្វកិច្ចវិជ្ជាជីវៈ នោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចធ្វើការដាក់ទណ្ឌកម្មវិន័យទៅលើព្រះរាជអាជ្ញានោះបាន ប៉ុន្តែការដាក់ទណ្ឌកម្មវិន័យនេះមិនបានធ្វើឱ្យបណ្តឹងអាជ្ញារលត់ឡើយ គឺព្រះរាជអាជ្ញានៅតែទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ចំពោះការទទួលទណ្ឌកម្មវិន័យវិញ ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពេលដំណើរការនីតិវិធីវិន័យបានចាប់ផ្តើម។

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៥៥ បានកំណត់អំពីទណ្ឌកម្មវិន័យដែលត្រូវបានបែងចែកជា ២ ថ្នាក់ មានដូចតទៅ៖

**១-ទណ្ឌកម្មថ្នាក់ទី១**

- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២ ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ និងឋានន្តរស័ក្តិក្នុងករណីដែលមានចុះឈ្មោះរួចហើយ។

**២-ទណ្ឌកម្មថ្នាក់ទី២**

- ការផ្លាស់ដោយបង្ខំអាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឱ្យមានបៀវត្សក្នុងរយៈពេលមិនឱ្យលើសពី ០១ឆ្នាំ
- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ
- ការបញ្ឈប់ពីមុខងារដោយបង្ខំ
- ការបណ្តេញចេញពីក្របខណ្ឌ។

[40] មាត្រា៥៤ កថាខណ្ឌទី១ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[41] មាត្រា៥៤ កថាខណ្ឌទី២ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ចំពោះទណ្ឌកម្មទី២នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ចៅក្រមអាចត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងករណីដែលចៅក្រមណាមួយរូប កំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[42]

## ផ្នែកទី៤៖ តួនាទី ភារកិច្ច សមត្ថកិច្ច និងសិទ្ធិអំណាចរបស់អង្គការអយ្យការ

### ៤.១ តួនាទី ភារកិច្ចរបស់ព្រះរាជអាជ្ញា

តួនាទី ភារកិច្ចរបស់ព្រះរាជអាជ្ញា គឺធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានសំណុំរឿងតាមរយៈការអនុវត្តបណ្តឹងអាជ្ញា។ បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។[43] បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិសាសន៍ ឋានៈ សង្គមធនធាន ឬស្ថានភាពឯទៀតឡើយ។[44] ចំពោះការធ្វើបណ្តឹងអាជ្ញាមានតែអង្គការអយ្យការមួយប៉ុណ្ណោះ ដែលមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការចោទប្រកាន់បានសេចក្តីថាអង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ក្រៅពីនេះគឺពុំមានបុគ្គល ឬស្ថាប័នណាអាចធ្វើបណ្តឹងអាជ្ញាបានឡើយទោះបីជាបុគ្គល ឬស្ថាប័ននោះមានវិជ្ជាជីវៈផ្នែកច្បាប់ក៏ដោយ។ ស្របតាមមាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញបានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"។ ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌរួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តក្នុងការស៊ើបអង្កេតបទល្មើសពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលកាអនុវត្តសាលក្រម និងការបំពេញតួនាទីផ្សេងៗទៀតដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។[45]

### ៤.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

នៅពេលដែលមានបទល្មើសមួយកើតឡើង ព្រះរាជអាជ្ញា និងធ្វើការស្រាវជ្រាវពីបទល្មើស។ ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងកំណត់ពីអត្តសញ្ញាណរបស់បុគ្គលដែលបានប្រព្រឹត្តជាពិសេសទីតាំងដែលជនល្មើសបានប្រព្រឹត្តបទល្មើស និងទីតាំងដែលសមត្ថកិច្ចបានចាប់ជនល្មើស។ ពាក់ព័ន្ធនិងទីតាំងនេះដែរ

[42] មាត្រា៥៤ កថាខណ្ឌទី៣ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
[43] មាត្រា២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[44] មាត្រា៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[45] គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា,អនុម័តដោយសមាជអង្គការប្រជាជាតិលើកទី៧ ប្រទេសគុយបា,នៅថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០,ចំណុចទី១១

គឺដើម្បីកំណត់បានពីសមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា ថាតើព្រះរាជអាជ្ញា ឬតំណាងអយ្យការដែលបំពេញមុខងារនៅសាលាជម្រះក្ដីណាមួយដែលមានសមត្ថកិច្ចដោះស្រាយលើរឿងក្ដីនោះ។ ហេតុនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បញ្ញត្តិពីសមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា ដើម្បីបង្កភាពងាយស្រួលក្នុងការអនុវត្តដែលមានដូចខាងក្រោម៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។[46]

## ៤.៣ សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាមានសិទ្ធិប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនស្របទៅតាមច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន។ នីតិវិធីព្រហ្មទណ្ឌបានផ្ដល់អំណាចជូនដល់ព្រះរាជអាជ្ញានៅក្នុងដំណាក់កាលនៃការចោទប្រកាន់ដែលជាដំណាក់កាលមួយដែលព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកលើការផ្ដល់ចំណាត់ការក្នុងការដោះស្រាយរឿងក្ដីព្រហ្មទណ្ឌ។ ដែលជាគោលការណ៍ក្នុងការទទួលបានគ្រប់ព័ត៌មានទាំងអស់ដែលជាប្រយោជន៍ក្នុងបណ្ដឹង និងទៅតាមច្បាប់ដែលបានកំណត់។ ព្រះរាជអាជ្ញាក្នុងដំណាក់កាលចោទប្រកាន់សិទ្ធិអំណាចអាចធ្វើការបែងចែកជា ៣ គឺ៖ អំណាចលើមន្ត្រីនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

- **អំណាចលើមន្ត្រីនគរបាលយុត្តិធម៌**

ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[47] នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស នោះមន្ត្រីនគរបាលយុត្តិធម៌នឹងត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចធ្វើការចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

ក្នុងករណីចាំបាច់ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ហើយរៀបចំជំនួសសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី ដើម្បីធ្វើការ

[46] មាត្រា៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[47] មាត្រា៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស៊ើបអង្កេតជំនួស។ ជាមួយគ្នានេះផងដែរ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចទៅកាន់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីត្រួតពិនិត្យពីកិច្ចដំណើរការលើសំណុំរឿង។[48]

- **អំណាចក្នុងការស៊ើបអង្កេត**

ដើម្បីធ្វើការចោទប្រកាន់ថាជាបទល្មើសចំពោះអំពើណាមួយបាន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេត ដោយពិនិត្យមើលទៅលើអង្គហេតុដែលបានកើតឡើង និងត្រូវកំណត់ច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌ និងមាន ធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់។

នៅក្នុងការស៊ើបអង្កេត ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឱ្យ មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់នៅក្នុងការស៊ើបអង្កេត។[49] ព្រះរាជអាជ្ញា មានសិទ្ធិអំណាចក្នុងការបើកការស៊ើប អង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋមមានជាអាទិ៍ដូចជា៖ ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការធ្វើកំណត់ហេតុ ការធ្វើកោសល្យវិច្ច័យ និងការស្តាប់ការសន្ទនាជាដើម។

- **អំណាចក្នុងការចោទប្រកាន់**

ក្នុងដំណាក់កាលចោទប្រកាន់ គឺជាអំណាចចម្បងមួយ និងសំខាន់បំផុតរបស់ព្រះរាជអាជ្ញាប្រើប្រាស់ ដើម្បីអោយសំណុំរឿងព្រហ្មទណ្ឌមួយអាចដំណើរការទៅដំណាក់កាលបន្ទាប់ទៀតបាន។ ព្រះរាជអាជ្ញាមាន សមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿងដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់រឿង ទុកឥតចាត់ការ ដោយមិនធ្វើការចោទប្រកាន់បើទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬក៏ធ្វើការចោទ ប្រកាន់ដែលហៅថា **គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬ ជម្រើសនៃការចោទប្រកាន់។**

ព្រះរាជអាជ្ញា ក៏អាចធ្វើការចោទប្រកាន់បានផងដែលក្នុងរូបភាពនៃការចោទប្រកាន់ ដែលមានលក្ខណៈ វិនិច្ឆ័យជាបីសណ្ឋាន៖ គឺការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលខ្លួនបង្ហាញ ភ្លាម។[50] នៅក្នុងនោះផងដែរ ព្រះរាជអាជ្ញាមានសិទ្ធិនៅក្នុងការបង្ខំរូបរាងកាយ ការលើកលែងទោស ការត្រួតពិនិត្យ ការព្យួរទោស និងការអនុវត្តទោសបានផងដែរ។

---

[48] មាត្រា ៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ។

[49] មាត្រា ៣៧ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[50] មាត្រា ៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# ជំពូកទី២

# ការតម្កល់រឿងទុកឥតចាត់ការ
# នៅអយ្យការអមសាលាដំបូង
# រាជធានីភ្នំពេញ

# ជំពូកទី២

# ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ការតម្កល់រឿងទុកឥតចាត់ការ អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ហើយសិទ្ធិអំណាចរបស់តំណាងអយ្យការជារបស់ព្រះរាជអាជ្ញាក្នុងការធ្វើចំណាត់ការលើបណ្តឹងអាជ្ញាដែលជាជម្រើសនៃការចោទប្រកាន់កើតចេញពីគោលការណ៍នៃការចោទប្រកាន់តាមបែបកាលានុវត្តភាពដែលជាការផ្តល់ជម្រើសដល់ព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ដោយការពិចារណា។ ក្រោយពីបានបោះបង់គោលការណ៍ចោទប្រកាន់តាមបែបនីត្យានុកូលភាពដែលជាគោលការណ៍ឱ្យតែមានបទល្មើសត្រូវតែធ្វើការចោទប្រកាន់ទាំងអស់។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺដើម្បីឱ្យព្រះរាជអាជ្ញាអាចថ្លឹងថ្លែងអំពីចំណាត់ការពាក្យបណ្តឹងដែលទទួលបានដោយផ្ទាល់ ឬពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ដោយសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។[51] ប៉ុន្តែចំពោះការសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាទៅលើរឿងក្តី មានន័យថារឿងក្តីនោះត្រូវបានបញ្ចប់នោះទេ ព្រោះតែការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំឡើយ[52] ដូចនេះស្ថាប័នអយ្យការមានសិទ្ធិកែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញក្នុងខណៈដែល បណ្តឹងអាជ្ញាមិនទាន់រលត់នៅឡើយ[53] ដោយសេចក្តីសម្រេចនៃការតម្កល់រឿងទុកឥតចាត់ការនេះត្រូវតែធ្វើឡើងដោយផ្អែកលើសំអាងហេតុ និងសំអាងច្បាប់។[54]

### ១.១ និយមន័យនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជាជម្រើសមួយរបស់ព្រះរាជអាជ្ញាសម្រេចអំពីការមិនធ្វើបណ្តឹងអាជ្ញាឱ្យមានចលនា មានន័យថាបណ្តឹងអាជ្ញា ឬបណ្តឹងរដ្ឋប្បវេណី នោះព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកដោយមិនបន្តចំណាត់ការនីតិវិធីទៅមុខទៀតឡើយ លុះត្រាតែមានការប្តឹងតវ៉ា និងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬមានអធិបញ្ជាឱ្យបើកការចោទប្រកាន់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

---

51 មាត្រា៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

52 មាត្រា៤១ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

53 មាត្រា៤១ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

54 មាត្រា៤១ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ១.២ អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការ

ស្របតាមនីតិវិធីនៃដំណើរការរឿងក្តីព្រហ្មទណ្ឌត្រូវបានបែងចែកចេញជា ០៤ ដំណាក់កាលធំៗរួមមានៈ ដំណាក់កាលស៊ើបអង្កេត ធ្វើឡើងដោយនគរបាលយុត្តិធម៌, ដំណាក់កាលចោទប្រកាន់ធ្វើឡើងដោយតំណាងអយ្យការ, ដំណាក់កាលស៊ើបសួរ ធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ គឺជាតួនាទីរបស់ចៅក្រមជំនុំជម្រះ។ នៅក្នុងដំណាក់កាលទាំងបួននេះការតម្កល់រឿងទុកឥតចាត់ការគឺធ្វើឡើងនៅដំណាក់កាលអយ្យការ។ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រង់មាត្រា៤ វាក្យខណ្ឌ២ បានចែងថា អយ្យការធ្វើការចោទប្រកាន់បទព្រហ្មទណ្ឌ។[55]

ដោយហេតុថាមានបញ្ញត្តិនៅមាត្រាខាងលើនេះ យើងអាចទាញជារួមបានថា អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការគឺៈ

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង

បានជាគេចាត់ទុកថា ព្រះរាជអាជ្ញាមានសមត្ថកិច្ចក្នុងការតម្កល់រឿងទុកឥតចាត់ការគឺដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា ៣៨ បានចែងថា ព្រះរាជអាជ្ញារងដែលស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[56] នេះជាគោលការណ៍ឯករាជ្យរបស់ស្ថាប័នអយ្យការដែលព្រះរាជអាជ្ញារងស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា។

## ផ្នែកទី២ៈ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

មានមូលហេតុមួយចំនួនដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកដែលជាហេតុនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ ប៉ុន្តែមូលហេតុទាំងនោះមិនបានចែងដោយត្រង់ថា គឺជាមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការឡើយ។ ការតម្កល់រឿងទុកឥតចាត់ការអាចបណ្តាលមកពីអវត្តមាននៃអត្តសញ្ញាណរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាពជាដើម។ លើសពីនេះអវត្តមាននៃបទល្មើស ឬអត្តសញ្ញាណនៃជនល្មើសមិនត្រូវបានគេស្គាល់ ក៏ជាហេតុនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការនេះដែរ។[57] ក្រៅពីនេះនៅមានមូលហេតុគតិយុត្តមួយចំនួនដូចខាងក្រោមទៀតដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ មិនមែនគ្រប់សំណុំរឿងទាំងអស់ដែលព្រះរាជអាជ្ញាទទួលបានសុទ្ធតែត្រូវបានចោទប្រកាន់នោះទេពោលគឺប្រសិនបើខ្លួនយល់ឃើញថាសំណុំរឿងណាមួយមិនមានមូលហេតុគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ឬការចោទប្រកាន់

[55] មាត្រា៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[56] មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] ទំព័រទី១៨ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នោះមិនទទួលបានផលប្រយោជន៍ ឬអំពើដែលមិនមែនជាបទល្មើសជាដើម ព្រះរាជអាជ្ញាអាចសម្រេចថាមិនចោទប្រកាន់បានដោយតម្កល់រឿងទុកឥតចាត់ការ។ ការតម្កល់រឿងទុកឥតចាត់ការអាចបណ្តាលមកពីមូលហេតុផ្សេងៗដូចខាងក្រោម៖

## ២.១ ការតម្កល់រឿងទុកឥតចាត់ការលើអំពើដែលមិនមែនជាបទល្មើស

បទល្មើសព្រហ្មទណ្ឌត្រូវមានធាតុផ្សំបីគឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ យោងតាមគោលការណ៍នីត្យានុកូលភាពអំពើដែលជាបទល្មើស គឺជាអំពើទាំងឡាយណាដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន ហើយអាចប្រកាសបាននៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត និងចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌចូលជាធរមាន។[58] ចំពោះអំពើដែលមិនមានចែង មានន័យថាមិនមានបទល្មើសឡើយ ហើយមិនត្រូវបានផ្តន្ទាទោសនោះទេ នៅពេលដែលបទល្មើសមួយមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់រួមទាំងច្បាប់មិនមានចែងទុកជាមុន នោះតំណាងអយ្យការមានសិទ្ធិសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។ ដូចនេះអំពើដែលមិនមែនជាបទល្មើស ជាអំពើទាំងឡាយណាដែលច្បាប់មានចែងជាធរមាន ដោយសារតែអវត្តមាននៃបទល្មើស និងកង្វះធាតុផ្សំនៃបទល្មើស។

### ២.១.១. នត្ថិភាពនៃបទល្មើស

ច្បាប់បានបញ្ញត្តិថាអំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។[59] បទល្មើស សំដៅដល់អំពើ ឬបាតុភាពអសកម្មផ្សេងៗនៅក្នុងជីវភាពរស់នៅដោយបានបំពានធ្ងន់ធ្ងរដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម។ អំពើទាំងឡាយណាដែលបានបំពានដល់ច្បាប់ដែលមានជាធរមាន ឬអំពើនោះបានប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើសព្រហ្មទណ្ឌ។ ការចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ គឺមានគោលការណ៍ដាក់ទណ្ឌកម្មឱ្យជនដែលបានប្រព្រឹត្តកំហុសមានការរាងចាលលែងហ៊ានប្រព្រឹត្តម្តងទៀត ដើម្បីបញ្ចៀសហានិភ័យដែលនឹងអាចកើតមានឡើងនៅក្នុងសង្គម។

គោលការណ៍នីត្យានុកូលភាព គឺជាគោលការណ៍ដ៏សំខាន់មួយរបស់នីតិព្រហ្មទណ្ឌ ដោយគោលការណ៍នេះ បានចាត់ទុកថាមានតែអំពើដែលបង្កើតបានជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។[60] ម្យ៉ាងវិញទៀតប្រសិនបើគ្មានច្បាប់ចែងទុកមុនថាជាបទល្មើសទេ គឺគ្មានទោសឡើយទោះបីជាអំពើនោះបានប្រព្រឹត្តខុសទៅនឹងសីលធម៌សង្គមក៏ដោយ។

[58] មាត្រា៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[59] មាត្រា២ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[60] មាត្រា៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ២.១.២ អវត្តមាននៃបទល្មើស

បទល្មើស គឺជាអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលបង្កភាពចលាចលដល់សង្គម[61]ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ប៉ុន្តែក្នុងករណីដែលតំណាងអយ្យការបានធ្វើការថ្លឹងថ្លែងទៅលើបណ្តឹងដែលទទួលបានមកពីមន្ត្រីនគរបាល ឬទទួលបានដោយផ្ទាល់ក្តី និងបានធ្វើការស៊ើបអង្កេតស្រាវជ្រាវបានបង្ហាញថាអំពើនោះមិនមានកំណត់ដោយបទបញ្ញត្តិច្បាប់ជាធរមាន ឬមិនមានជាប្រភេទរឿងក្តីព្រហ្មទណ្ឌទេ តំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន ទោះបីជាអំពើខ្លះបានធ្វើឱ្យមានផលប៉ះពាល់ប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈក្តី ក៏មិនអាចចោទប្រកាន់បានឡើយ ព្រោះតែមិនមានបញ្ញត្តិច្បាប់បានចែងពីអំពើល្មើសនោះ។ ប្រសិនបើបទល្មើសខ្លះមិនមានច្បាប់ចែងតែបង្កនូវព្យសនកម្មធ្ងន់ធ្ងរដល់សង្គមនោះ សិទ្ធិអំណាចរបស់តុលាការជាអ្នកសម្រេចលើករណីនេះ។ ហេតុដូចនេះ អវត្តមាននៃបទល្មើសសំដៅដល់សំណុំរឿងដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ចំពោះសំណុំរឿងដែលមិនមែនជាបទល្មើសសំដៅលើកំហុសរដ្ឋប្បវេណីជាដើម កង្វះធាតុផ្សំនៃបទល្មើស និងសំណុំរឿងដែលតំណាងអយ្យការមិនធ្វើចំណាត់ការ។

ជាក់ស្តែងដូចក្នុងករណីនេះ បុគ្គល **ក** បានទៅបញ្ចុះបញ្ចូលបុគ្គល **ខ** ដើម្បីទិញតូបផ្សាររបស់ខ្លួនមួយកន្លែងដោយមានការជឿទុកចិត្តបុគ្គល **ខ** ក៏បានយល់ព្រមទិញតូបផ្សារនោះក្នុងតម្លៃ ៥,០០០$(ប្រាំពាន់ដុល្លារអាមេរិក)ដោយបានធ្វើកិច្ចសន្យាទិញ-លក់តូបផ្សារ ពីបុគ្គល **ក** បន្ទាប់មកបុគ្គល **ក** ក៏បានឱ្យមីងរបស់ខ្លួនដែលជាបុគ្គល **គ** ធ្វើជាទៅជួលតូបពីបុគ្គល **ខ** ក្នុងតម្លៃមួយខែ ១៥០$(មួយរយហាសិបដុល្លារ) ប៉ុន្តែការជួលនោះបុគ្គល **គ** មិនបានបង់ប្រាក់ថ្លៃជួលតូបទៅឱ្យបុគ្គល **ខ** នោះទេ បន្ទាប់មកបុគ្គល **ក** និងបុគ្គល **គ** បានបន្តហៅបុគ្គល **ខ** លេងតុងទីន ដល់ពេលលេងបានមួយរយៈបុគ្គល **ខ** បានដេញតុងទីននោះ ប៉ុន្តែបុគ្គល **ក** និងបុគ្គល **គ** ពុំបានប្រគល់ប្រាក់ទៅឱ្យបុគ្គល **ខ** នោះឡើយ។ បានមួយរយៈពេលក្រោយមកស្រាប់តែម្ចាស់ផ្សារបានជូនដំណឹងទៅបុគ្គល **ខ** ថាតូបផ្សារនោះជារបស់ម្ចាស់ផ្សារមិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់ឡើយ ហើយម្ចាស់ផ្សារក៏បានបន្តប្រាប់ទៅបុគ្គល **ខ** ថាតូបនោះខ្លួនពុំលក់ដូរបានទេ។ ក្រោយមកបុគ្គល **ខ** បានទំនាក់ទំនងទៅបុគ្គល **ក** និងបុគ្គល **គ** ប៉ុន្តែពួកគេបានគេចវេសមិនព្រមដោះស្រាយជាមួយខ្លួនឡើយ ទើបខ្លួនបានដឹងថាបុគ្គលទាំង២ខាងលើគឺបានឆបោកនិងរំលោភលើទំនុកចិត្តខ្លួន។

តាមរយៈអង្គហេតុខាងលើនេះតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ទៅលើបុគ្គល **ក** និង បុគ្គល **គ** បាននោះទេ ដោយសារអង្គហេតុនេះគឺជារឿងវិវាទរដ្ឋប្បវេណីដែលផ្តើមចេញពីការធ្វើកិច្ចសន្យា និងការលេងតុងទីន។

[61] មាត្រា២ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ២.១.៣. កង្វះធាតុផ្សំនៃបទល្មើស

យោងតាមគោលការណ៍ដើម្បីចោទប្រកាន់ទៅលើអំពើល្មើសណាមួយបាន លុះត្រាតែមាននូវធាតុផ្សំនៃបទល្មើសចំនួនបីមានដូចជា ធាតុនីត្យានុកូល ឬធាតុច្បាប់, ធាតុសត្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត។ អំពើល្មើសដែលបានប្រព្រឹត្តរួចហើយ ប៉ុន្តែមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដូចបានរៀបរាប់ទាំងបីខាងលើ មិនអាចសម្រេចធ្វើការចោទប្រកាន់ទេ ដោយធាតុផ្សំនៃបទល្មើសនេះផងដែរជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងគោលការណ៍ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើស និងមូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាផងដែរ។ តំណាងអយ្យការមិនអាចសម្រេចធ្វើការចោទប្រកាន់បានទេ ប្រសិនបើខ្វះធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបី ទោះបីជាអំពើនោះជាបទល្មើសដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ពិសេស។

ឧទាហរណ៍ជាក់ស្តែង៖ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ លោក **ក** បានលក់រថយន្តមួយគ្រឿងម៉ាក LEXUS RX៣00 ពណ៌ខ្មៅ ទៅឱ្យលោក **ខ** ក្នុងតម្លៃ១០,000$ ពេលនោះលោក **ខ** បានយល់ព្រមទិញរថយន្តពីលោក **ក** ហើយបានធ្វើកិច្ចសន្យាទិញ-លក់រថយន្ត ដោយបានកក់ប្រាក់ចំនួន ៥,000$។ បន្ទាប់ពីបានព្រមព្រៀងក្នុងការទិញនិងកក់ប្រាក់រួចរាល់លោក **ក** បានរកលេសថាខ្លួនយករថយន្តនេះទៅជួសជុលឱ្យបានស្អាតសិនទើបប្រគល់ឱ្យទៅលោក **ខ** យកទៅប្រើប្រាស់ ប៉ុន្តែដោយសារលោក **ខ** រង់ចាំលោក **ក** យករថយន្តទៅជួសជុលយូរថ្ងៃពេក ទើបបានទំនាក់ទំនងទៅលើក **ក** តែលោក **ក** បាននិយាយរកលេសដោះសារជារឿយៗរាល់ពេលលោក **ខ** ខលទៅសាកសួរ ហេតុដូច្នេះទើបលោក **ខ** បានដឹងខ្លួនថាលោក **ក** បានឆបោកខ្លួន។

តាមរយៈអង្គហេតុខាងលើនេះ គឺមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់សម្រាប់ឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើលោក **ក** ពីបទឆបោកបាននោះទេ ដោយមូលហេតុលោក **ក** បានលក់រថយន្តទៅឱ្យលោក **ខ** និងដោយបានធ្វើកិច្ចសន្យាទិញលក់-រថយន្ត ដោយត្រឹមតែកក់ប្រាក់តែប៉ុណ្ណោះ គឺលោក **ខ** ពុំទាន់បានបង់ប្រាក់ផ្តាច់ទៅឱ្យលោក **ក** ដើម្បីយករថយន្តមកប្រើប្រាស់នោះទេ។

#### ២.១.៣.១ ធាតុនីត្យានុកូល ឬធាតុច្បាប់

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើណាមួយដែលប្រព្រឹត្តដោយចារីផ្ទាល់ សហចារី ឬជនសមគំនិត ហើយត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ប្រសិនបើច្បាប់មិនមានចែងអំពើនោះជាបទល្មើសទេ នោះមិនត្រូវបានគេចាត់ទុកថាជាបទល្មើសបានទេ ហើយអាចប្រកាសទោសបានលុះត្រាតែបទល្មើសត្រូវបានប្រព្រឹត្ត និងមានបញ្ញត្តិព្រហ្មទណ្ឌជាធរមាន។[62] ដូចនេះគ្មានអំពើណាមួយដែលអាចកំណត់បទល្មើសដោយគ្មានច្បាប់ចែងទេ។

[62] មាត្រា៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

**២.១.៣.២ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ**

ធាតុសត្យានុម័ត ឬធាតុសម្ភារៈ សំដៅដល់សកម្មភាពនៃការប្រព្រឹត្តបទល្មើសពិតប្រាកដ ឬជាការប៉ុនប៉ងដែលជាការកំណត់ទៅលើបទល្មើសមួយដោយស្តែងចេញពីសកម្មភាពរបស់ជនល្មើសទីកន្លែងនៃការប្រព្រឹត្តបទល្មើស ហេតុផលដែលបណ្តាលឱ្យមានការប្រព្រឹត្តបទល្មើស ឧបករណ៍ ឬវត្ថុដែលទទួលបានមកពីការប្រព្រឹត្តបទល្មើសនោះ ឬផលប៉ះពាល់ដោយសារតែអំពើដែលបានប្រព្រឹត្តល្មើសទៅលើទ្រព្យសម្បត្តិរដ្ឋ ឬទ្រព្យសម្បត្តិឯកជន បូរណភាពរបស់បុគ្គល និងសិទ្ធិសេរីភាពជាដើម។

**២.១.៣.៣ ធាតុអត្តនោម័ត**

ធាតុអត្តនោម័ត សំដៅដល់អចេតនា ឬកំហុសរបស់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើស។ ជនល្មើសមានចេតនា និងបំណងក្នុងការបង្កជាភាពចលាចលដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈសុខសុវត្ថិភាពសង្គមក្នុងឆន្ទៈបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ ជាគោលការណ៍មិនមានបទល្មើសកើតឡើងទេប្រសិនបើគ្មានឆន្ទៈ ឬគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសលើកលែងទៅលើបទល្មើសដែលកើតឡើងដោយការធ្វេសប្រហែស ហេតុនេះហើយអំពើប្រព្រឹត្តដែលកើតចេញពីជនដែលមិនមានឆន្ទៈក្នុងការប្រព្រឹត្ត ឬគ្មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តទេ មិនអាចធ្វើការចោទប្រកាន់បានទេលើកលែងតែមានករណីដែលច្បាប់បានចែងអំពីកំហុសដោយចេតនាក្នុងការប្រព្រឹត្តប៉ុណ្ណោះ ទើបត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

ជារួមមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ទៅលើអំពើដែលបានប្រព្រឹត្តណាមួយថាបទល្មើសលុះត្រាតែបានបំពេញលក្ខខណ្ឌទាំងបីខាងលើរបស់ធាតុផ្សំនៃបទល្មើស ដែលមានដូចជា ធាតុនីត្យាកូល ឬធាតុច្បាប់ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត។ នៅពេលដែលខ្វះធាតុផ្សំនៃបទល្មើសណាមួយ តំណាងអយ្យការដែលជាព្រះរាជអាជ្ញាធ្វេសប្រហែស ការខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬការមិនគោរពកាតព្វកិច្ចក្នុងករណីច្បាប់បានបញ្ញត្តិទុកជាមុន។[63]

## ២.២ ការតម្កល់រឿងទុកឥតចាត់ការនៅលើអំពើដែលជាបទល្មើស

ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បាន កាលណាអំពើល្មើសមួយមានគ្រប់លក្ខខណ្ឌទាំងអស់របស់ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌដោយមានច្បាស់លាស់។ ដោយអាស្រ័យទៅលើគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់បានទៅលើអំពើល្មើសណាមួយដែលជាបទល្មើសព្រហ្មទណ្ឌ។ ថ្វីត្បិតតែច្បាប់មានចែងអំពីបទល្មើសក៏ពិតមែន ប៉ុន្តែក៏មានករណីខ្លះដែលមិនត្រូវបានចោទប្រកាន់ផងដែរ ដូចជាកាលៈទេសៈនៃការប្រព្រឹត្ត។ ហេតុដែលបណ្តាលឱ្យមាន

[63] មាត្រា៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ការប្រព្រឹត្តផលដែលទាក់ទងនឹងបទល្មើសមិនបង្កព្យសនកម្មធ្ងន់ធ្ងរនិងភាពចលាចលដល់សង្គមនោះទេ។ ហេតុដូចនេះហើយបើព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ក៏មិនបានផ្តល់ផលប្រយោជន៍អ្វីដល់សង្គមដែលនាំឱ្យកើតមានឡើងនូវការតម្កល់រឿងទុកឥតចាត់ការ ដោយសារតែព្រះរាជអាជ្ញាបានធ្វើការស៊ើបអង្កេតបន្ថែមតែមិនអាចដឹងពីអត្តសញ្ញាណរបស់ជនល្មើស ឬបទល្មើសដែលបានបង្កនោះមានព្យសនកម្មតិចតួច ឬបណ្តាលមកពីមូលហេតុគតិយុត្តផងដែរ។

### ២.២.១ កង្វះអត្តសញ្ញាណរបស់ជនល្មើស

កង្វះអត្តសញ្ញាណរបស់ជនល្មើសក៏ជាមូលហេតុដែលបណ្តាលឱ្យតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការបានដែរនៅពេលដែលអត្តសញ្ញាណរបស់ជនល្មើសមិនអាចកំណត់បានដោយគ្មានសាវតារជាតិរបស់ជនល្មើសនៅក្នុងបទល្មើសមួយដែលបានកើតឡើងទេ។ តំណាងអយ្យការអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបានដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្រោយពីបានទទួលការស៊ើបអង្កេតបឋម ឬការស្រាវជ្រាវបន្ថែមដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតនៅក្រោមការដឹកនាំនិងសម្របសម្រួលរបស់ព្រះរាជអាជ្ញា។[64] បន្ទាប់ពីការស៊ើបអង្កេតមិនបានស្គាល់ពីអត្តសញ្ញាណរបស់ជនល្មើស ជាហេតុមិនអាចបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះដោយផ្ទាល់បាន និងនាំឱ្យខាតបង់ផលប្រយោជន៍ផងនោះព្រះរាជអាជ្ញាអាចសម្រេចបានថាគួរតម្កល់រឿងទុកឥតចាត់ការឬក៏ចោទប្រកាន់។

ជាក់ស្តែងដូចជាករណីមានអំពើហិង្សាមួយកើតឡើងក្នុងអំឡុងពេលរាំផុងបាស់នាពេលរាត្រីក្នុងភូមិមួយ។ ពេលមន្ត្រីនគរបាលយុត្តិធម៌បានចុះមកផ្ទាល់ធ្វើការស៊ើបអង្កេតបឋមក្រោយពីបានសាកសួរក្នុងកន្លែងកើតហេតុជនបង្កគឺមិនមែនជាអ្នកក្នុងភូមិនោះទេ ដោយសារតែពេលកើតហេតុជាពេលយប់ផងនោះទើបបានជាមិនស្គាល់ពីជនសង្ស័យព្រមទាំងព័ត៌មានមកពីណាស្នាក់នៅកន្លែងណាគឺមិនមានតម្រុយអ្វីទាក់ទងនឹងជនសង្ស័យឡើយ។ ករណីនេះ ប្រសិនមន្ត្រីនគរបាលយុត្តិធម៌រកមិនឃើញអត្តសញ្ញាណរបស់ជនល្មើសព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបានស្របទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

ចៅក្រមស៊ើបសួរអាចធ្វើការបញ្ជូនដីកាដំណោះស្រាយទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់បានក្នុងករណីដែលចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់បានមានដូចជាៈ[65]

- អំពើប្រព្រឹត្តនោះមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ
- មិនស្គាល់ជនដែលប្រព្រឹត្តអំពើល្មើស
- គ្មានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកទៅលើជនត្រូវចោទ។

[64] មាត្រា៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[65] មាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.២.២ បទល្មើសដែលមានព្យសនកម្មតិចតួច

តំណាងអយ្យការ អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ក្រោយពីបានធ្វើការស្រាវជ្រាវឃើញអំពីស្ថានការណ៍ដែលបណ្តាលឱ្យមានបទល្មើសកើតឡើងកាលៈទេសៈនៃការប្រព្រឹត្តដែលចារីបានប្រព្រឹត្តផ្ទុយពីកិរិយាមាយាទ ឆន្ទៈរបស់ខ្លួនក្នុងស្ថានភាពចាំបាច់ណាមួយ និងទទួលស្គាល់ពីអំពើល្មើសរបស់ខ្លួនហើយមិនបានបង្កព្យសនកម្មធ្ងន់ធ្ងរ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមសាធារណៈធ្ងន់ធ្ងរ។ ទោះបីជាបទល្មើសនោះមានគ្រប់ធាតុផ្សំដែលបង្ហាញថាជាបទល្មើសព្រហ្មទណ្ឌក្តី ក៏តំណាងអយ្យការអាចធ្វើការសម្រេចចោទប្រកាន់ទៅលើរឿងនោះបានដែរ។ ទោះបីជាតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនល្មើសក៏មិនទទួលបានផលប្រយោជន៍អ្វីដល់សង្គមជាតិដែរ។

ជាក់ស្តែង បុរសក្រីក្រម្នាក់បានទៅលួចបាយគេមួយប្រអប់ដើម្បីឱ្យកូនរបស់គាត់បានហូប។ ដោយគាត់ជាបុរសពោះម៉ាយមានជម្ងឺប្រចាំកាយ និងទទួលបន្ទុកកូន២នាក់ ដោយសារតែជីវភាពគាត់ខ្វះខាតផង។ តាមរយៈការសិក្សាពីអង្គហេតុខាងលើ បុរសពោះម៉ាយបានប្រព្រឹត្តបទល្មើសលួច។ បើយោងតាមមាត្រា៣៥៣នៃក្រមព្រហ្មទណ្ឌ បានចែងអំពីនិយមន័យនៃអំពើលួច និងមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌដែលចែងអំពីទោស។ ដោយការប្រព្រឹត្តល្មើសខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ ប៉ុន្តែប្រសិនបើយើងក្រឡេកទៅមើលលើមូលហេតុនិងផលប្រយោជន៍ ដែលគាត់ទទួលបានពីការប្រព្រឹត្តបទល្មើសនោះវិញគឺមានព្យសនកម្មតិចតួច និងដោយសារតែកត្តាជីវភាពរបស់គាត់រួមជាមួយភាពស្រេកឃ្លាន ដើម្បីបានអាហារផ្តល់ឱ្យកូនៗរបស់គាត់បានហូបផង។ ហេតុនេះហើយតំណាងអយ្យការ អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។ ទោះបីជាធ្វើការចោទប្រកាន់ក៏មិនទទួលបានផលប្រយោជន៍អ្វីឡើយ មានតែធ្វើឱ្យកូនៗរបស់គាត់គ្មានអាណាព្យាបាលក្លាយជាកូនកំព្រាមិនមានអ្នកចាំទំនុកបម្រុងគ្រួសារធ្វើឱ្យតុលាការមានបន្ទុកកាន់តែច្រើនក្នុងការដោះស្រាយ។

### ២.២.៣ មូលហេតុគតិយុត្ត

យោងទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មិនមានការអះអាងអំពីមូលហេតុច្បាស់លាស់ក្នុងការតម្កល់រឿងទុកឥតចាត់ការនោះទេដោយមានតែនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ។ ជាហេតុនាំឱ្យព្រះរាជអាជ្ញា ប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីការមិនចោទប្រកាន់ទៅលើបុគ្គលដែលមានអភ័យឯកសិទ្ធិរួមទាំងមាត្រា៧ ចែងអំពីការរលត់នៃបណ្តឹងអាជ្ញា និងមាត្រា៨ចែងអំពីមូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញានៅក្រមនីតិវិធីព្រហ្មទណ្ឌ។ តួយ៉ាងនៅក្នុង មាត្រា ២៧ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងអំពីការតម្កល់រឿងទុកឥតចាត់ការទៅលើអនីតិជនក្រោមអាយុ១៨ឆ្នាំ។ ដោយនេះជាមូលហេតុគតិយុត្តដែលមានចែងក្នុងច្បាប់សម្រាប់ឱ្យតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់។

**២.២.៣.១ អភ័យឯកសិទ្ធិ**

អភ័យឯកសិទ្ធិ សំដៅលើការពារទៅលើបុគ្គលដែលមានលក្ខណៈពិសេសក្នុងការរួចផុតពីការចោទប្រកាន់។ តំណាងរាស្ត្រមានអភ័យឯកសិទ្ធិមិនត្រូវបានធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយសារតែការបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនទេ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬឃុំខ្លួន សមាជិករដ្ឋសភាណាមួយអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬគណៈកម្មាធិកាអចិន្ត្រៃយ៍រដ្ឋសភាក្នុងចន្លោះពេលប្រជុំសភា លើកលែងករណីដែលមានបទល្មើសព្រហ្មទណ្ឌជាក់ស្តែងបានកើតឡើង។[66] អភ័យឯកសិទ្ធិរដ្ឋសភា អភ័យឯកសិទ្ធិព្រឹទ្ធសភា អភ័យឯកសិទ្ធិការទូត បុគ្គលទាំងនេះត្រូវបានការពារដោយច្បាប់ចំពោះមុខងាររបស់ខ្លួន ក្នុងការបំពេញតួនាទីរបស់ខ្លួនទោះបីជារកឃើញថាជាបទល្មើសក៏ដោយតែមិនអាចធ្វើការចោទប្រកាន់បានឡើយ។

លើសពីនេះ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងអំពីអភ័យឯកសិទ្ធិដល់បុគ្គលដែលមិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌផងដែរ គឺអភ័យឯកសិទ្ធិគ្រួសារដែលមានចែងក្នុងមាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌ អភ័យឯកសិទ្ធិគ្រួសារ សំដៅទៅលើភាពមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបានចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច (អំពើលួចទ្រព្យសម្បត្តិ) បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិសហព័ទ្ធរបស់ខ្លួន។[67] នៅក្នុងសន្ទានុក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានពន្យល់ពាក្យ "បុព្វញាតិ" ថាជាជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន ពោលគឺ ជីដូនជីតា ឪពុកម្តាយ មាមីង ឬន័យសាមញ្ញហៅថាអ្នកជំនាន់មុន។ ចំណែកឯពាក្យថា "បច្ឆាញាតិ" ជាជន ឬពួកជន ដែលកើតពីជនមួយពួកទៀត ពោលគឺ កូន ចៅ ទួយ ឬហៅថាអ្នកជំនាន់ក្រោយ។ រីឯពាក្យ "សហព័ទ្ធ" គឺសំដៅទៅលើប្តី ឬប្រពន្ធ ឬទាំងប្តីទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះ ក្រោយពីបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

ក្នុងន័យនេះបើមានករណីលួចទ្រព្យសម្បត្តិនៅក្នុងសង្គមគ្រួសារ ដែលប្រព្រឹត្តដោយបុព្វញាតិ ឬបច្ឆាញាតិក៏ដូចជាសហព័ទ្ធពិតមែន នោះមាត្រា៣៥៥ នៃក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ចំពោះករណីនេះដែលអាចឱ្យអ្នកប្រព្រឹត្តនោះ រួចផុតពីការផ្តន្ទាទោសចំពោះបទល្មើសលួចទ្រព្យសម្បត្តិឡើយ។ អភ័យឯកសិទ្ធិគ្រួសារមានបំណងបញ្ចៀសនូវរាល់ផលវិបាកទាំងឡាយដែលអាចកើតចេញពីរឿងក្តីព្រហ្មទណ្ឌនៅក្នុងរង្វង់គ្រួសារ។ គួរបញ្ជាក់ផងដែរថាអភ័យឯកសិទ្ធិគ្រួសារនេះអាចអនុវត្តបានចំពោះតែបទល្មើសលួចតែប៉ុណ្ណោះដោយមិនគ្របដណ្តប់លើស្ថានទម្ងន់ទោសឡើយ។

[66] មាត្រា៨០ ច្បាប់ស្តីពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[67] មាត្រា៣៥៥ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាក់ស្តែងក្នុងករណីដែលកូនប្រុសម្នាក់ បានលួចយកម៉ូតូរបស់ឪពុកម្តាយបង្កើតរបស់ខ្លួនទៅលក់ដើម្បីយកលុយទៅលេងល្បែង។ ចំពោះករណីនេះតុលាការមិនអាចផ្តន្ទាទោសកូនប្រុសនោះបានឡើយ ពីព្រោះកូនប្រុសនោះត្រូវជាបច្ឆាញាតិរបស់ឪពុកម្តាយបង្កើត ដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិតាមរយៈមាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។

**២.២.៣.២ អនិយ័តភាពនៃនីតិវិធី**

អនិយ័តភាពនៃនីតិវិធី សំដៅដល់ការអនុវត្តនៅដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌មិនត្រឹមត្រូវតាមច្បាប់កំណត់នាំឱ្យព្រះរាជអាជ្ញាធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើអំណាចឆន្ទានុសិទ្ធិ។ ដោយមន្ត្រីនគរបាលយុត្តិធម៌ជាជំនួយរបស់អំណាចតុលាការ គឺជាជំនួយរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរមានភារកិច្ចក្នុងការត្រួតពិនិត្យទៅលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដោយកំណត់ពីអត្តសញ្ញាណ និងចាប់ជនល្មើសរួមជាមួយនឹងការប្រមូលភស្តុតាងផងដែរ។[68] ឧទាហរណ៍ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនជនល្មើសខុសអត្តសញ្ញាណ ក្នុងដំណាក់កាលស៊ើបអង្កេតបឋមដែលអ្នកប្រព្រឹត្តពិតប្រាកដគឺបុគ្គល **ក** ប៉ុន្តែគាត់បែរជាឃាត់ខ្លួនបុគ្គល **ខ** ហើយធ្វើកំណត់ហេតុបញ្ជូនខុសសាវតាររបស់ជនល្មើសបញ្ជូនទៅព្រះរាជអាជ្ញា។ យោងទៅតាមមោឃភាពនៃការមិនគោរពតាមវិធាន និងទម្រង់នៃកំណត់ហេតុស្តីពីការឃាត់ខ្លួន ដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។[69]

**២.២.៣.៣ ការផុតរលត់នៃបណ្តឹងអាជ្ញា**

ការផុតរលត់នៃបណ្តឹងអាជ្ញាអាចបណ្តាលមកពីការផុតអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា មរណភាពនៃជនល្មើស ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ។[70] ទាំងនេះជាមូលហេតុដែលព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន កាលណាបណ្តឹងអាជ្ញាបានរលត់ ឬអស់អានុភាព។

**ក.មរណភាពនៃជនល្មើស**

បណ្តឹងអាជ្ញាត្រូវបានរលត់នៅពេលដែលជនជាប់ចោទទទួលមរណភាព ក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការស្នើសុំសំណងរដ្ឋប្បវេណីបានជាមួយសន្តតិជនរបស់ជនល្មើសក្នុងការជួសជុលការខូចខាតពីសិទ្ធិវន្តរបស់ជនជាប់ចោទបាន ហើយតុលាការព្រហ្មទណ្ឌនៅតែមានសិទ្ធិសម្រេចក្នុងបណ្តឹងរដ្ឋប្បវេណីដើម្បីប្រឆាំងនឹងសិទ្ធិវន្តនោះ។[71]

---

[68] មាត្រា៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[69] មាត្រា១០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[70] មាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[71] មាត្រា២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ឧទាហរណ៍ជាក់ស្តែង មានបុរសម្នាក់បានជិះម៉ូតូមួយគ្រឿងក្នុងល្បឿនលឿន លុះដល់ចំណុចដែលបុរសនោះត្រូវបត់ឆ្លងផ្លូវ ក៏បានបត់ភ្លាមៗដោយពុំបានស៊ីញ៉ូ ឬឈប់ដើម្បីមើលឆ្វេងស្តាំថាមានរថយន្តមកពីក្រោយឬពីមុខម៉ូតូខ្លួននោះទេពេលបុរសនោះបត់ម៉ូតូឆ្លងផ្លូវភ្លាមក៏ស្រាប់តែទៅបុកនិងរថយន្តមួយគ្រឿងដែលគេកំពុងធ្វើដំណើរតាមផ្លូវបណ្តាលឱ្យបុរសនោះស្លាប់ភ្លាមនៅកន្លែងកើតហេតុតែម្តង។

ក្នុងអង្គហេតុនេះ តំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ទៅលើអ្នកបើកបររថយន្តបាននោះទេពីព្រោះបុរសដែលជាអ្នកជិះម៉ូតូ គឺបានធ្វេសប្រហែស ហើយបណ្តាលឱ្យស្លាប់ដោយខ្លួនឯង។

**ខ.ការផុតរលត់បណ្តឹងអាជ្ញា**

បណ្តឹងអាជ្ញាត្រូវបានរលត់ កាលណាអាជ្ញាយុកាលនៃបទល្មើសត្រូវបានរលត់ ហើយថិរវេលាគិតចាប់ពីពេលប្រព្រឹត្តបទល្មើស។ ប្រសិនបើបទល្មើសនោះបានកើតឡើងហើយតែមិនមានការបើកការស៊ើបសួរ ឬការដាក់ពាក្យបណ្តឹងចោទប្រកាន់ពីជនរងគ្រោះទេ នោះអាជ្ញាយុកាលរាប់ចាប់ពីថ្ងៃដែលកើតហេតុរហូតដល់ពេលបានកំណត់[72]។ ចំពោះបទល្មើសត្រូវបានចាប់ផ្តើមការស៊ើបសួរ ឬចោទប្រកាន់នោះអាជ្ញាយុកាលនៃបទល្មើសនឹងចាប់ផ្តើមពីពេលនៃការបើកការស៊ើបសួរពីព្រះរាជអាជ្ញា ឬពេលដាក់ពាក្យបណ្តឹងពីជនរងគ្រោះរហូតដល់ពេលថិរវេលានៃអាជ្ញាយុកាលនីមួយៗ ដែលស្ថិតទៅលើប្រភេទនៃបទល្មើសដោយថិរវេលានៃអាយុកាលរបស់បណ្តឹងអាជ្ញាមានរយៈពេល ១៥(ដប់ប្រាំ)ឆ្នាំ ចំពោះបទឧក្រិដ្ឋ ហើយរយៈពេល ០៥ (ប្រាំ)ឆ្នាំ ចំពោះបទមជ្ឈិម និងរយៈពេល ០១(មួយ)ឆ្នាំ ចំពោះបទលហុ។[73] ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនិងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចរួចផុតអាជ្ញាយុកាលបានទេ។[74]

ឧទាហរណ៍ទី១៖ កញ្ញា **ក** ត្រូវបានគេរំលោភនៅកំឡុង ឆ្នាំ២០០០ ដោយមិនមានតម្រុយអ្វីអំពីជនសង្ស័យទាល់តែសោះ។ រហូតមកដល់ឆ្នាំ ២០១៨ មានសាក្សីបានចូលរួមមកបំភ្លឺពីជនសង្ស័យ។ បន្ទាប់មកទើបមានការស៊ើបអង្កេត និងឈានទៅដល់ការចាប់ខ្លួនជនសង្ស័យ។ បទរំលោភសេពសន្ថវៈ ជាបទឧក្រិដ្ឋបើយោងទៅតាមក្រមព្រហ្មទណ្ឌ មាត្រា២៣៩ កថាខណ្ឌទី២ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ។ ដោយអាជ្ញាយុកាលនៃបទឧក្រិដ្ឋមានរយៈពេល ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីពេលប្រព្រឹត្តបទល្មើស។

---

[72] មាត្រា១១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[73] មាត្រា១០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[74] មាត្រា៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ករណីខាងលើនេះ ត្រូវបានចាប់ខ្លួន ជនសង្ស័យនៅឆ្នាំ២០១៨ ដែលបានកើតហេតុកាលពីឆ្នាំ២០០០ ដែលមានរយៈពេលកន្លងផុតទៅអស់ ១៨(ដប់ប្រាំបី)ឆ្នាំ ទៅហើយ។ ដូចនេះមិនអាចធ្វើការដាក់ទោសជនល្មើស បានឡើយដោយសារតែអាជ្ញាយុកាលនៃទោសត្រូវបានរលត់។

ឧទាហរណ៍ទី២៖ កញ្ញា ខ ត្រូវបានគេរំលោភនៅកំឡុង ឆ្នាំ២០០០ ដោយមិនមានតម្រុយអំពីជនសង្ស័យទាល់តែសោះ។ បន្ទាប់មកនៅក្នុង ឆ្នាំ២០០៦ ត្រូវបានបើកការស៊ើបអង្កេតឡើងវិញម្តងទៀត ដោយមានអ្នកបានដឹងពីតម្រុយរបស់ជនសង្ស័យ ប៉ុន្តែមិនមានរកឃើញអ្វីទាក់ទងនឹងរឿងក្តីឡើយ។ ក្រោយមកទៀតនៅឆ្នាំ២០១៦ ក៏មានសាក្សីបង្ហាញពីជនសង្ស័យ ទើបបើកការស៊ើបអង្កេតម្តងទៀត និងចាប់បានជនសង្ស័យ។

ករណីនេះ បើគិតពីពេលប្រព្រឹត្តបទល្មើស មកដល់ពេលចាប់ខ្លួនជនល្មើសមានរយៈពេល១៦ឆ្នាំ កន្លងផុតទៅហើយ។ ប៉ុន្តែគេអាចដាក់ទោសទៅលើជនល្មើសបានដោយសារតែនៅឆ្នាំ២០០៦ មានការបើកការស៊ើបអង្កេតម្តងហើយ ទើបអាជ្ញាយុកាលនៃទោសបានគិតចាប់ពីពេល នៃការបើកការស៊ើបអង្កេតពីឆ្នាំ២០០៦ មកទល់នឹង ឆ្នាំ២០១៦ មានរយៈពេល ១០(ដប់)ឆ្នាំ នៅសល់រយៈពេល ៥(ប្រាំ)ឆ្នាំ ទៀតទើបអាជ្ញាយុកាល នៃទោសត្រូវបានរលត់។ ករណីនេះជនល្មើសត្រូវតែទទួលទោសតាមច្បាប់ ដោយសារតែអាជ្ញាយុកាលនៃទោសមិនទាន់រលត់ ដោយសារតែមានការស៊ើបអង្កេតម្តងទៀតនៅពេលដែលមានតម្រុយអំពីជនល្មើស ដូចនេះអាជ្ញាយុកាលនៃទោសត្រូវចាប់ផ្តើមសារជាថ្មី ដោយគិតចាប់ពីពេលបើកការស៊ើបសួរម្តងទៀត។

### គ. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ គឺជាបទប្បញ្ញត្តិច្បាប់ដែលមានអានុភាពទៅលើការរលត់បណ្តឹងអាជ្ញាទៅលើសកម្មភាពដែលបានប្រព្រឹត្តណាមួយ។ ការលើកលែងទោសជាទូទៅជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតក្នុងការរលត់នៃបណ្តឹងអាជ្ញាបើយោងទៅតាមមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌទី១ ចំណុចទី៣។ ការលើកលែងទោសជាទូទៅស្ថិតនៅក្រោមអំណាចរបស់នីតិប្បញ្ញត្តិដែលជ្រើសយកមតិភាគច្រើនរបស់រដ្ឋសភាជាអ្នកអនុម័ត។[75] អាចធ្វើការលើកលែងទោសជាទូទៅបានដោយផ្អែកទៅលើទោសប្រកាសដែលត្រូវបានលើកលែងគុណសម្បត្តិរបស់ជនល្មើសប្រភេទនៃបទល្មើសដែលត្រូវបានទទួលការលើកលែងទោស។

ទោសប្រកាសដែលត្រូវបានលើកលែង អាចជាទោសដែលតុលាការបានប្រកាសពី ៣(បី)ខែ ដល់ ៣ (បី)ឆ្នាំ។

គុណសម្បត្តិរបស់ជនល្មើសដែលមានអាយុក្រោម ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចធ្វើការស្នើសុំថ្វាយព្រះមហាក្សត្របានព្រះរាជក្រឹត្យធ្វើការលើកលែង នឹងសម្រេចនៅពេលដែលទទួលបានការសិក្សាអំពីករណីរបស់

[75] មាត្រា៩០(ថ្មី) នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ចារីនៃបទល្មើសនោះ។ ប្រភេទបទល្មើស ដែលទទួលបានការលើកលែងទោស នៅពេលដែលបណ្តឹងអាជ្ញាបាន រលត់នោះតុលាការមិនអាចសម្រេចផ្តន្ទាទោសបានទេ។ ចៅក្រមត្រូវធ្វើការប្រកាសទោសជាមុនទើបអាចបញ្ជាក់ ពីអត្រានៃទោសដែលអាចលើកលែងបានឬអត់។

**ឃ. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

កាលណាច្បាប់ត្រូវបានប្រកាសនិរាករណ៍ហើយនោះ មានន័យថាបណ្តឹងអាជ្ញាក៏ត្រូវបានរលត់ដែរ ប្រសិនបើមានបញ្ញត្តិចាស់ដែលមានចែងចំពោះបទល្មើសនោះថាត្រូវបាននិរាករណ៍។ ចំពោះច្បាប់ថ្មីដែលបាន ចូលជាធរមានក្រោយពីបទល្មើសដែលបានប្រព្រឹត្តនោះមិនទទួលបានការចោទប្រកាន់ឡើយ។[76]

**ង. អាជ្ញាអស់ជំនុំ**

គោលការណ៍អាជ្ញាអស់ជំនុំត្រូវបានអនុវត្តទៅលើជនល្មើសដែលតុលាការបានសម្រេចឱ្យរួចខ្លួនហើយ មិនត្រូវបានធ្វើការចោទប្រកាន់ទៀតទេ ទោះបីជាមានការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។[77] គោល ការណ៍អាជ្ញាអស់ជំនុំ ជាគោលការណ៍ដែលរារាំងការដំណើរការទៅលើនីតិវិធីថ្មីចំពោះអំពើដូចគ្នា។ ការទាមទារ ការចោទប្រកាន់ដែលបានចោទត្រូវតែដូចគ្នាទៅនិងបទល្មើសបានសម្រេចឱ្យជាប់ទោស ឬការរួចផុតពីការចោទ ប្រកាន់។ ម៉្យាងទៀតគោលការណ៍នេះអាចហៅបានថាជាគោលការណ៍គ្មានការកាត់ទោសទៅលើបទល្មើស តែមួយ ដោយផ្អែកទៅលើគោលការណ៍នេះមិនមានជនណាម្នាក់ត្រូវបានកាត់ទោសទៅលើបទល្មើសណា មួយដែលខ្លួនបានជាប់ទោស ឬរួចផុតពីបទដែលបានចោទរួចហើយនោះទេ។

**២.២.៤ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ**

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ អំពើដែលខ្លួនបានធ្វើ។[78] មិនអាចមានជនណាម្នាក់មកទទួលខុសត្រូវទោសកំហុសជំនួសអំពើល្មើសរបស់អ្នកដ៏ ទៃបានឡើយ។ ច្បាប់ក៏មានអញ្ញត្តិកម្មដែលនាំឱ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដោយមាន មូលហេតុមួយចំនួនដូចជា វិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍ នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬការបង្ខំ និងអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ។

[76] មាត្រា៩ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[77] មាត្រា១២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[78] មាត្រា២៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ២.២.៤.១ ជនវិបល្លាសស្មារតី

ជនដែលមានវិបល្លាសស្មារតីគឺជាបុគ្គលដែលបាត់បង់សមត្ថភាពក្នុងការទទួលដឹងខុសត្រូវទាំងស្រុង។ ដោយសារតែបុគ្គលដែលមានវិបល្លាសស្មារតីមិនអាចបែងចែកពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនោះថាត្រូវ ឬខុសនោះទេ ទើបច្បាប់កំណត់ថាជនដែលបាត់បង់ការទទួលខុសត្រូវរបស់ខ្លួន គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ប៉ុន្តែចំពោះជនដែលមានវិបល្លាសស្មារតីដែលនាំឱ្យមានការកាត់បន្ថយការយល់ដឹងរបស់ខ្លួនបុគ្គលនោះនៅតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែទទួលបានការបន្ធូរបន្ថយទោសប៉ុណ្ណោះ ហើយត្រូវមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ពីក្រុមគ្រូពេទ្យជំនាញ ដើម្បីឱ្យតុលាការធ្វើការពិនិត្យពិចារណាទៅលើសេចក្តីសម្រេចក្នុងការកំណត់ទោស។ ចំពោះបុគ្គលមួយចំនួនផ្សេងទៀតដែលជាបុគ្គលវិបល្លាសស្មារតី ដោយសារតែសារធាតុញៀន សារធាតុស្រវឹង ឬសារធាតុផ្សេងៗដែលច្បាប់បានហាមឃាត់ គឺមិនត្រូវទទួលបានការលើកលែងទោសនោះបានទេ ឬមិនអាចចាត់ថាមិនមែនជាបទល្មើសនោះទេ។[79]

### ២.២.៤.២ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលដែលប្រព្រឹត្តអំពើដែលច្បាប់បានកំណត់ ឬតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់មិនចាត់ទុកជាការប្រព្រឹត្តបទល្មើសទេ ទោះបីជាអំពើនោះជាបទល្មើសក៏ដោយក៏មិនអាចចោទជាបទល្មើសដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរ លើកលែងតែការប្រព្រឹត្តនោះជាអំពើដែលផ្ទុយពីច្បាប់ដែលបានកំណត់ទុក ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម ជាបទល្មើសដែលមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាននោះទេ។ ទោះបីជាជននោះបានប្រព្រឹត្តអំពើដែលច្បាប់មិនបានហាមឃាត់ ឬអំពើដែលប្រព្រឹត្តតាមការបញ្ជារបស់អាជ្ញាធរដែលស្របច្បាប់ក៏ដោយ។[80]

### ២.២.៤.៣ ការការពារស្របច្បាប់

បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយមានការចាំបាច់ដើម្បីការពារខ្លួន គឺការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិដែលប្រឈមមុខនឹងការឃ្លានពានមួយមិនត្រឹមត្រូវជាការការពារដែលស្ថិត នៅក្នុងស្ថានភាពចាំបាច់ ព្រោះតែបុគ្គលមួយចំនួនដែលបានទទួលរងនូវអំពើឈ្លានពានមិនត្រឹមត្រូវ ដែលអាចបណ្តាលឱ្យមាននូវព្យសនកម្មបាត់បង់ជីវិតប៉ះពាល់ដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ ឬប្រទេសជាតិជាដើម។ បើសិនជាមិនមានការពារស្របច្បាប់ ការខូចខាតនោះមិនអាចកែប្រែឱ្យវិលមករកសភាពដើមវិញបានឡើយ។ ទោះបីជាអំពើដែលបានប្រព្រឹត្តទៅលើបុគ្គលណាម្នាក់នោះមិនមែនជាអំពើដែលជាបទល្មើសដែលច្បាប់បានកំណត់ ឬការប្រព្រឹត្តនៃអំពើនោះដោយអនីតិជន ឬជនដែលមានវិបល្លាសស្មារតីក៏ដោយ ក៏បុគ្គលនោះមានសិទ្ធិក្នុងការការពារស្រប

[79] មាត្រា៣១ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[80] មាត្រា៣១ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ច្បាប់ដែរ។ បទល្មើសនិងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នាដោយអំពើល្មើសត្រូវតែកើតឡើងមុនការការពារស្របច្បាប់បើសិនមិនមានការប្រព្រឹត្តអំពើល្មើសមុនទេនោះមិនមានការពារស្របច្បាប់ដែរ។ ប្រសិនជាបុគ្គលនោះសំអាងថាការការពារបានកើតមុនអំពើល្មើស គឺជាការបំពានដែលច្បាប់បានកំណត់ត្រូវទទួលទោសព្រោះមិនមែនជាការការពារដែលស្របច្បាប់។ ប្រសិនបើការការពារនោះមានរយៈពេលមិនសមាមាត្រគ្នាដោយគម្លាតរយៈពេលនៃការប្រព្រឹត្តបទល្មើសដែលបានកើតឡើងបានបញ្ចប់ហើយទើបមានការការពារ នោះមិនមែនជាការការពារស្របច្បាប់នោះទេតែជាការសងសឹកទៅវិញបុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ការការពារស្របច្បាប់ត្រូវតែគ្មានវិសមាមាត្រគ្នារវាងមធ្យោបាយការពារដែលប្រើប្រាស់ដើម្បីតបតនិងទម្ងន់នៃការឈ្លានពាន។ ការការពារនោះផងដែរអាចធ្វើការតបតដោយសមត្ថភាពផ្ទាល់ ដូចជាតបតដោយប្រើប្រាស់ដៃជើង ឬការការពារដោយប្រើប្រាស់អាវុធដូចជា វត្ថុ សត្វ ឬឧបករណ៍ ដើម្បីបង្កជារបួសស្នាម ឬសម្លាប់ ទៅតាមទំហំនៃការឈ្លានពាននោះឬការប្រើប្រាស់អាវុធរបស់ជនល្មើស។ ការការពារស្របច្បាប់ទាំងនេះច្បាប់បានអនុញ្ញាតឱ្យបុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[81]

### ២.២.៤.៤ សច្ចធារណ៍នៃការការពារស្របច្បាប់

សច្ចធារណ៍ គឺជាការសន្មត់នៃការការពារស្របច្បាប់ ដែលមាននៅក្នុងករណីបទល្មើសដែលបានប្រព្រឹត្តនោះកើតឡើងដោយហិង្សាកាប់គាស់ទម្លុះទម្លាយឬប្រើប្រាស់ល្បិចនៅទីកន្លែងដែលមានមនុស្សនៅដើម្បីប្រព្រឹត្តបទល្មើស ឬការការពារខ្លួនដើម្បីប្រឆាំងទៅនឹងបទល្មើសលួច ឬប្លន់ដោយការប្រើហិង្សា។ ប៉ុន្តែសច្ចធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតនោះទេ មានន័យថាសច្ចធារណ៍នេះអាចត្រូវរំលាយទៅវិញប្រសិនបើមានភស្តុតាងផ្ទុយ ដោយបញ្ជាក់ថាការតបតនោះមិនមែនជាការការពារខ្លួនទៅវិញ។[82]

### ២.២.៤.៥ ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងស្ថានភាពមួយ ដែលចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ បើសិនជាការប្រព្រឹត្តនោះស្ថិតនៅក្នុងកាលៈទេសៈមួយដែលត្រូវការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ការការពារដើម្បីប្រឆាំងទៅនឹងស្ថានភាពដែលកំពុងគ្រោះថ្នាក់ ឬស្ថានភាពគ្រោះថ្នាក់ដែលនឹងកើតឡើងនាពេលខាងមុខ។ ចំពោះការការពារនោះដែរត្រូវតែ គ្មានវិសមាមាត្ររវាងមធ្យោបាយការការពារនឹងទំហំនៃគ្រោះថ្នាក់នោះទេ។[83] មូលហេតុស្ថានភាពចាំបាច់ស្រដៀងនឹងការការពារស្របច្បាប់ដែរ គ្រាន់តែមិនមានអំពើឈ្លានពានស្ថិតក្នុងស្ថានភាពនេះទេ គឺអ្នកប្រព្រឹត្តប្រឈមនឹងស្ថានភាពធម្មជាតិ ឬហេតុការណ៍ណាមួយ។

[81] មាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[82] មាត្រា៣៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[83] មាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

#### ២.២.៤.៦ អានុភាពនៃកម្លាំង ឬការបង្ខំ

ការប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំងណាមួយ ឬក្រោមការបង្ខំពីអ្នកដទៃដោយការបង្ខំមិនអាចមើលដឹងមុន និងមិនអាចជៀសផុតបាន។[84] ដូចជាក្នុងករណីគេចាប់ប្អូនគម្រាមនឹងកាំបិតដើម្បីបង្ខំឱ្យបងទៅឆបោកអ្នកដទៃ ទង្វើនេះជាបទល្មើសព្រហ្មទណ្ឌតែមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះទង្វើល្មើសនេះទេ ដោយសារតែអ្នកប្រព្រឹត្តស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែងពីអ្នកដទៃដើម្បីឱ្យខ្លួនប្រព្រឹត្តបទល្មើសដោយបង្ខំ។

#### ២.២.៤.៧ អ្នកប្រព្រឹត្តជាអនីតិជន

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ។[85] ជនល្មើសមានអាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅទើបតុលាការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបានដោយទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ក៏ប៉ុន្តែមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ បានចែងថាអនីតិជនមានអាយុចន្លោះពី ១៤(ដប់បួន)ឆ្នាំ ទៅដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ តុលាការអាចវិនិច្ឆ័យទោសទៅតាមកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន។ ក្នុងករណីដែលចៅក្រមសម្រេចចោទប្រកាន់ក្រមព្រហ្មទណ្ឌ មាត្រា១៦០ បានកំណត់ថាទោសដែលត្រូវចោទប្រកាន់ទៅលើបទល្មើសនោះត្រូវកាត់បន្ថយពាក់កណ្តាលពីទោសធម្មតា ឬអប្បបរមានៃទោសនោះលើសពី ១(មួយ)ឆ្នាំ។ បើអប្បបរមានៃទោសនោះត្រូវដាក់ពន្ធនាគារអស់មួយជីវិត ត្រូវកាត់បន្ថយមកត្រឹម ២០(ម្ភៃ)ឆ្នាំ។

បើយោងទៅតាមគោលការណ៍ អនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ឡើងទៅត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[86] ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន និងប្រគល់អនីតិជនឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលអនីតិជននោះមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតត្រឹមថ្ងៃជនសង្ស័យចូលរួមប្រព្រឹត្តបទល្មើស។[87] ទោះបីជាព្រះរាជអាជ្ញារកឃើញពីអត្ថិភាពនៃបទល្មើសនោះក៏ដោយ។

### ២.៣ មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹង

ការតម្កល់រឿងទុកឥតចាត់ការអាចធ្វើបាន ដោយផ្អែកទៅលើមូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាដែរមូលហេតុនេះផងដែរត្រូវបានដោះស្រាយតាមបែបផ្សេងទៀត។ លក្ខខណ្ឌដែលអាចឱ្យបណ្តឹងអាជ្ញាអាចរលត់ផុតបានកាលណាច្បាប់ដោយឡែក បានចែងជាក់លាក់ដោយមានការសម្របសម្រួលជាមួយរដ្ឋ

---

[84] មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[85] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[86] មាត្រា១៦០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[87] មាត្រា២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដោយការដកពាក្យប្តឹងនៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។[88]

### ២.៣.១ ការសម្របសម្រួលជាមួយរដ្ឋ

នៅពេលដែលជនល្មើសដឹងពីកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ហើយអំពើល្មើសនោះមិនបានផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរ ដល់សណ្តាប់ធ្នាប់សង្គមសាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍របស់រដ្ឋ។ ជននោះអាចធ្វើការសម្របសម្រួលជាមួយរដ្ឋបានដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីជាសំអាងហេតុពីកំហុសរបស់ខ្លួន និងសម្រាប់ជាការសន្យាចំពោះរដ្ឋដើម្បីទទួលបានការលើកលែងទោសពីរដ្ឋដោយបំពេញនូវលក្ខខណ្ឌដែលរដ្ឋបានដាក់ឱ្យ។ ជាពិសេសករណីបទល្មើសពន្ធគយ។

ដូចជាករណី ក្រុមហ៊ុន **ក** បាននាំទិញទំនិញគ្រឿងសំអាងថែរក្សាសម្រស់ពីបរទេសតែបានលួចបន្ថែមគេចពន្ធសម្លៀកបំពាក់ នៅពេលដែលរដ្ឋរកឃើញថាមានទំនិញផ្សេងទៀតដែលក្រុមហ៊ុន **ក** បាននាំចូលខុសច្បាប់នោះរដ្ឋតម្រូវឱ្យ ក្រុមហ៊ុន **ក** បង់ពន្ធជូនរដ្ឋនូវទំនិញដែលមិនទាន់បានបង់ ដើម្បីឱ្យរលត់នូវបណ្តឹងអាជ្ញា។

### ២.៣.២ ការដកពាក្យបណ្តឹងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់

តាមគោលការណ៍បទល្មើសព្រហ្មទណ្ឌទោះបីជាជនរងគ្រោះដកពាក្យបណ្តឹងក៏មិនអាចរលត់បណ្តឹងអាជ្ញាបាននោះដែរ ទោះបីជាជនរងគ្រោះព្រមដកពាក្យបណ្តឹង ឬព្រមទទួលសំណងនៃការខូចខាតក៏ដោយព្រះរាជអាជ្ញានៅតែមានសិទ្ធិសម្រេចអាចចោទប្រកាន់ទៅលើបទល្មើសនោះដដែល។ប៉ុន្តែមានបទល្មើសមួយចំនួនដែលរឿងក្តីព្រហ្មទណ្ឌ ឬបណ្តឹងអាជ្ញាមិនអាចដំណើរការបាន ប្រសិនជាជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងទៅវិញ។ បទល្មើសមួយចំនួនដែលត្រូវបានច្បាប់កំណត់ថាបើជនរងគ្រោះបានដកពាក្យបណ្តឹងនោះបណ្តឹងអាជ្ញានឹងត្រូវរលត់។ យោងទៅតាមច្បាប់ឯកព័ន្ធភាព (ផិតក្បត់) បុរស ឬស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ទៅតាមច្បាប់ពីមុនមិនទាន់រលាយ ហើយលួចទៅមានទំនាក់ទំនងជាមួយបុរស ឬស្ត្រី ដទៃទៀតចាត់ទុកថាជាបទផិត។[89] ក្នុងករណីនេះផងដែរព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើសហព័ទ្ធបានដាក់ពាក្យបណ្តឹងស្នើសុំ ដើម្បីកុំឱ្យធ្វើការចោទប្រកាន់ទៅលើសហព័ទ្ធម្ខាងទៀតបាន។[90] រួមទាំងការជេរប្រមាថ ឬបរិហារកេរ្តិ៍ មិនអាចចោទប្រកាន់បានទេ បើសិនជាគ្មានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ

[88] មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[89] មាត្រា៧ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[90] មាត្រា៨ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

ប្រសិនបើពាក្យបណ្តឹងដែលបានដាក់ហើយត្រូវបានដកទៅវិញដោយជនរងគ្រោះនោះបណ្តឹងអាជ្ញានឹងត្រូវរលត់ដូចគ្នា។

ចំពោះករណីហិង្សាក្នុងគ្រួសារវិញ ក៏ដូចគ្នាដែររាល់ការដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងគឺអាស្រ័យទៅលើជនរងគ្រោះជានីតិជន ចំពោះតែអំពើដែលមានលក្ខណៈជា បទលហុ ឬបទមជ្ឈិមស្រាលប៉ុណ្ណោះ។[91] ដោយឡែកបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរ ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់បានទោះបីជាមិនមានបណ្តឹងក៏ដោយ។[92] ចំពោះតែករណីដែលនគរបាលយុត្តិធម៌បានទទួលបណ្តឹងជាលើកទីមួយប៉ុណ្ណោះ ប្រសិនបើមានករណីដដែលនេះទទួលបណ្តឹងជាលើកទីពីរ មិនមានការលើកលែងសម្របសម្រួលទៀតនោះទេ។ អំពើហិង្សាក្នុងគ្រួសារមិនសំដៅតែអំពើទៅលើសហព័ទ្ធតែមួយនោះទេ រួមទាំងកូនក្នុងបន្ទុក ជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងនៅក្នុងបន្ទុកគ្រួសារផងដែរ។[93]

### ២.៣.៣ ការបង់ប្រាក់ពិន័យសរុបនិងប្រាក់ពិន័យសម្របសម្រួល

តាមគោលការណ៍បទល្មើសព្រហ្មទណ្ឌមិនអាចទទួលសំណងហើយរួចផុតពីការទទួលខុសត្រូវបាននោះទេ ប៉ុន្តែមានបទល្មើសមួយចំនួនមិនអាចធ្វើការចោទប្រកាន់បានទេដោយគ្រាន់តែទទួលការសម្របសម្រួលដោយការពិន័យ ដូចជាបទល្មើសចរាចរណ៍ផ្លូវគោក ទៅលើជនដែលបានប្រព្រឹត្តល្មើសច្បាប់ចរាចរណ៍ផ្លូវគោកត្រូវពិន័យជាប្រាក់ដើម្បីឱ្យបណ្តឹងអាជ្ញារលត់។[94]

តំណាងអយ្យការមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសនេះទេ ទោះបីជាអំពើនោះជាអំពើល្មើសក៏ដោយតំណាងអយ្យការមានសិទ្ធិក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ផ្អែកលើការពិចារណាទៅលើសំអាងច្បាប់ និងសំអាងហេតុ។

បទល្មើសដែលបង្កឡើងដោយគ្រោះថ្នាក់ចរាចរណ៍ក៏អាចជាបទល្មើសព្រហ្មទណ្ឌដែរ ប្រសិនបើបទល្មើសនោះបង្កនូវព្យសនកម្មធ្ងន់ធ្ងរ បណ្តាលឱ្យបាត់បង់ជីវិតជាដើម មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងទុកឥតចាត់ការបានទេ ទោះជាមានការសម្របសម្រួលគ្នារវាងជនល្មើសនិងជនរងគ្រោះ ឬមានការដកពាក្យបណ្តឹងក៏ដោយ[95] ក៏តំណាងអយ្យការមានសិទ្ធិទៅលើរឿងក្តីព្រហ្មទណ្ឌដែរ។ ប៉ុន្តែប្រសិនបើគ្រោះថ្នាក់ត្រឹមតែធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃទេមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកអាចសម្របសម្រួល ដោយការសងសំណង

[91] មាត្រា៣៦ ច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[92] មាត្រា១៩ ច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[93] មាត្រា២ ច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[94] មាត្រា៨៧ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[95] មាត្រា៧៥ ច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៃការខូចខាតបាន[96] ឬភាគីទាំងសងខាងអាចសម្រុះសម្រួលគ្នាបានដោយមិនចាំបាច់មានការអន្តរាគមន៍ពីមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកក៏បាន។[97]

នៅក្នុងករណីបទល្មើសព្រៃឈើមានបទល្មើសមួយចំនួន ក៏ស្ថិតនៅក្នុងបទល្មើសព្រហ្មទណ្ឌដូចគ្នាតែមានចរិតលក្ខណៈពិសេស តែមានបទល្មើសមួយចំនួនទៀតរដ្ឋបាលព្រៃឈើមានសិទ្ធិពិន័យជាអន្តរកាលក្នុងករណីដែលជនល្មើសព្រមសារភាពនូវទោសកំហុសរបស់ខ្លួន និងព្រមបង់ប្រាក់ពិន័យទៅតាមទោសបញ្ញត្តិ។[98]

## ២.៤ ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ គឺសំដៅដល់ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញាឬតំណាងអយ្យការទៅលើស្ថានភាពណាមួយដែលពាក់ព័ន្ធបទល្មើស ចារី សហចារី ជនរងគ្រោះជាអាទិ៍ ហើយក៏បានរកឃើញថារាល់បទល្មើសទាំងអស់នោះ ប្រសិនបើធ្វើការចោទប្រកាន់វាហាក់បីដូចជាមិនបានផ្តល់ផលប្រយោជន៍អ្វីសោះដល់សង្គមជាតិ។ ប៉ុន្តែទោះបីជាអំពើដែលប្រព្រឹត្តនោះ គឺជាបទល្មើសក្តីក៏ព្រះរាជអាជ្ញាអាចធ្វើការពិចារណាថ្លឹងថ្លែងថាគួរចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយអាស្រ័យទៅលើស្ថានភាព និងកាលៈទេសៈនានានៃបទល្មើស ឬជនល្មើស។ ជាទូទៅកម្មវត្ថុនៃការចោទ ក៏ជាការទាមទារឱ្យជនល្មើសមកទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ មិនតែប៉ុណ្ណោះក៏ចាំបាច់ផងដែរសម្រាប់ការធានាដល់សិទ្ធិជនរងគ្រោះក្នុងបទល្មើសនោះ ដើម្បីទទួលបាននូវសំណងព្យសនកម្មពីអំពើល្មើសរបស់ជនល្មើសមកលើខ្លួន។ ម្យ៉ាងទៀតការចោទប្រកាន់នោះមិនអាចផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញាផងដែរ។ មូលហេតុដែលនាំឱ្យការចោទប្រកាន់របស់តំណាងអយ្យការឬព្រះរាជអាជ្ញាមិនផ្តល់ប្រយោជន៍នោះអាចបណ្តាលមកពីកត្តាមួយចំនួនដូចជា៖

### ២.៤.១ កត្តាចំណាត់ការ

សំដៅដល់ស្ថានភាពមួយ ដែលការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍ ដោយសារចំណាត់ការនៃនីតិវិធី។ ចំណាត់ការនៃនីតិវិធី អាចជាកាលៈទេសៈមួយដែលកិច្ចស៊ើបអង្កេតមិនបានផលដែលអាចមកពីមូលហេតុនៃការអូសបន្លាយពេលយូរក្នុងការស៊ើបអង្កេតជាអាទិ៍។

### ២.៤.២ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង

សំដៅដល់ស្ថានភាពដែលជនរងគ្រោះខ្លួនឯង បានបោះបង់ចោលពាក្យបណ្តឹង ឬការមិនអើពើចំពោះអំពើល្មើសមកលើខ្លួន ឬការខកខាននៅក្នុងនិតិវិធី។

[96] មាត្រា៦៥ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[97] មាត្រា៣៦ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[98] មាត្រា៩១ ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

ឧទាហរណ៍៖លោកស្រី **ច័ន្ទ** បានដាក់ពាក្យបណ្តឹងមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រោយមកក៏មានតំណាងអយ្យការមួយរូបទទួលបន្ទុកកាន់សំណុំរឿងរបស់លោកស្រី **ច័ន្ទ** បន្ទាប់មកតំណាងអយ្យការក៏បានឱ្យក្រឡាបញ្ជីរបស់គាត់បន្តនីតិវិធី ដូចជាបានចេញដីកាកោះចំនួន ២ ទៅ ៣ លើកទាំងភាគីដើមបណ្តឹងដែលលោកស្រី **ច័ន្ទ** និងជនសង្ស័យ ក្រោយពីចេញដីកាកោះរួចមក ក៏ឃើញដីកាបង្វិលមកកាន់តំណាងអយ្យការទទួលបន្ទុកសំណុំរឿងវិញ ដោយបានឃើញដីកាកោះនោះគឺភាគីដើមបណ្តឹងគឺទទួលបានការកោះពីតុលាការទៅ ប៉ុន្តែដល់ថ្ងៃកំណត់ត្រូវចូលមកឆ្លើយបំភ្លឺពុំបានឃើញភាគីជាដើមបណ្តឹងចូលមកតាមការកោះហៅចំនួន ២ ទៅ ៣ លើកនោះទ្បើយ ។ ដូចបានសេចក្តីលោកស្រី **ច័ន្ទ** ដែលជាភាគីដើមបណ្តឹងបានបោះបង់ពាក្យបណ្តឹងចោល។

### ២.៤.៣ កត្តាចារី

សំដៅដល់ស្ថានភាពមួយដែលអ្នកប្រព្រឹត្ត ឬចារី ស្ថិតក្នុងស្ថានភាពចាំបាច់ណាមួយ។ ស្ថានភាពទាំងនោះអាចជាស្ថានភាពដែលចារីមានអាកប្បកិរិយា និងទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្ត ឬអាចជាស្ថានភាពបញ្ហាបន្ទុកគ្រួសារ។

### ២.៤.៤ ព្យសនកម្ម

សំដៅដល់ស្ថានភាពដែលអំពើល្មើសនោះ បានហុចផល ដែលជាព្យសនកម្មមានលក្ខណៈតិចតួច ឬអាចជាភាពដែលព្យសនកម្មបានកើតចេញពីអំពើល្មើស ប៉ុន្តែព្យសនកម្មត្រូវបានប៉ះប៉ូវ។

### ២.៤.៥ អំពើល្មើសដែលបង្កព្យសនកម្មតិចតួច

ក្រោយពីព្រះរាជអាជ្ញាទទួលបាននូវបណ្តឹង ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីអំពើនោះ ដើម្បីសម្រេចថាចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញានោះ ត្រូវថ្លឹងថ្លែងទៅលើចរិកគ្រោះថ្នាក់ និងព្យសនកម្មរបស់អំពើនោះដែលប៉ះពាល់ទៅដល់ជនរងគ្រោះ ក៏ដូចជាសង្គមជាតិទាំងមូល។ កម្មវត្ថុនៃការចោទប្រកាន់មានគោលបំណងស្វែងរកការពិតនៃបទល្មើស និងចង្អុលបង្ហាញជនល្មើសដើម្បីយកមកផ្តន្ទាទោស។

ឧទាហរណ៍៖ លោក សុខា បានលួចផ្លែស្វាយរបស់ លោក ហេង មួយផ្លែ។ បើយើងក្រឡេកមើលក្រមព្រហ្មទណ្ឌ មាត្រា ៣៥៣ ឃើញថា សកម្មភាពលោក សុខា ត្រូវបានចាត់ទុកជាបទល្មើសលួច ព្រោះវាជាការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ។ប៉ុន្តែដោយហេតុថាអំពើនេះវាជាអំពើល្មើសមួយដែលមានព្យសនកម្មតូចតាច មិនមានផលប៉ះពាល់អ្វីធ្ងន់ធ្ងរសោះដល់សង្គម ហើយពិសេសនោះ ជនរងគ្រោះមិនទាំងអើពើលើអំពើដែលជននោះប្រព្រឹត្តបានប្រព្រឹត្តផង។

ដូចនេះការចោទប្រកាន់មិនផ្តល់ប្រយោជន៍ សំដៅដល់ការចោទប្រកាន់ដែលធ្វើឡើងនាំឱ្យខាតពេលវេលាមិនបានផ្តល់ប្រយោជន៍អ្វីដល់ជនរងគ្រោះ ឬដើមបណ្តឹង និងមិនផ្តល់ប្រយោជន៍អ្វីដល់សង្គមហើយហាក់បីមិនអាចសម្រេចនូវកម្មវត្ថុនៃការចោទប្រកាន់។ ហេតុដូច្នេះហើយវានឹងក្លាយជាកម្មវត្ថុនៃការពិចារណាលើការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី៣៖ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ៣.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ គឺស្ថិតក្នុងដំណាក់កាលអយ្យការ។ នៅក្រោយពេលដែលអយ្យការបានទទួលពាក្យបណ្តឹងបរិហារពីភាគីក្តី ឬដោយមន្ត្រីនគរបាលយុត្តិធម៌ក្តីនោះព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងដោយសម្បជញ្ញៈ និងវិជ្ជាជីវៈរបស់ខ្លួនដើម្បីធ្វើការសម្រេចថាគួរចោទប្រកាន់ពីបទល្មើស ឬគួរតម្កល់សំណុំរឿងនោះទុកឥតចាត់ការ។

ការសម្រេចនេះ គឺជាឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាដែលគោរពតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។ ក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថាគួរតែចោទប្រកាន់ នោះព្រះរាជអាជ្ញានឹងសម្រេចចោទប្រកាន់ដោយបញ្ជូនសំណុំរឿងទៅដំណាក់កាលបន្ទាប់។ ប៉ុន្តែបើព្រះរាជអាជ្ញាយល់ឃើញថាការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍សម្រាប់ស្ថាប័នអយ្យការឬសង្គមទេព្រះរាជអាជ្ញានឹងមិនធ្វើការចោទប្រកាន់ពីបទល្មើសតាមរយៈការតម្កល់រឿងទុកឥតចាត់ការ។ មុននឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវធ្វើការស្រាវជ្រាវពីបទល្មើសជាមុន។

#### ៣.១.១ ការទទួលពាក្យបណ្តឹង

យោងទៅតាមមាត្រា៦ នៃក្រមនីតិវិធីប្រហ្មទណ្ឌ បុគ្គលគ្រប់រូបដែលប្រកាសខ្លួនថាជាជនរងគ្រោះនៅក្នុងបទល្មើសជនទាំងនោះអាចដាក់ពាក្យប្តឹងបាន។ ដោយឡែកបណ្តឹងសាមញ្ញនេះ គឺគ្មានអានុភាពនាំឱ្យមានការចោទប្រកាន់ណាមួយជាបទព្រហ្មទណ្ឌឡើយ។ ការដាក់ពាក្យបណ្តឹងនេះ គឺដើម្បីប្រកាសប្រាប់ស្ថាប័នមានសមត្ថកិច្ចឱ្យផ្តើមធ្វើចំណាត់ការតាមច្បាប់។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានពាក្យបណ្តឹងនេះហើយត្រូវតែធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះ។ បន្ទាប់ពីធ្វើកំណត់ហេតុបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ចាប់ផ្តើមធ្វើការស៊ើបអង្កេតដោយខ្លួនឯង ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះទៅឱ្យព្រះរាជអាជ្ញាដើម្បីធ្វើចំណាត់ការបន្ត។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានឡើយ បើទោះបីជាមានការសម្រុះសម្រួលរវាងជនល្មើស និងជនរងគ្រោះក្តី។[99]

### ៣.១.២ ការស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែម

នៅពេលដែលទទួលបានពាក្យប្តឹងសុំតម្កល់រឿងទុកឥតចាត់ការ ឬពាក្យបរិហារដោយផ្ទាល់ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ បុគ្គលដែលមានអំណាចក្នុងការចោទប្រកាន់ ឬមិនចោទប្រកាន់ពោលគឺតំណាងអយ្យការត្រូវត្រួតពិនិត្យលើពាក្យបណ្តឹងនោះ ដើម្បីឱ្យប្រាកដថារឿងក្តីនោះមានលក្ខណៈបែបណា។ ប៉ុន្តែបើទោះបីជាយ៉ាងណាក៏ដោយការសម្រេចតម្កល់រឿងទុឥតចាត់ការនេះតំណាងអយ្យការដែលរួមមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ត្រូវតែបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមមុននឹងចេញសេចក្តីសម្រេចតម្កល់ ឬមិនតម្កល់។[100] ការស៊ើបអង្កេតបឋមគឺជាការស៊ើបដែលធ្វើឡើងមុនដំណាក់កាលនៃការជំនុំជម្រះដោយមន្ត្រីនគរបាលយុត្តិធម៌។[101] នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពើដែលអាចជាបទឧក្រិដ្ឋឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌នោះអាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯងឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ប្រសិនបើការស៊ើបអង្កេតទាក់ទងនិងបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលត្រូវរាយការណ៍ជូនភ្លាមៗទៅព្រះរាជអាជ្ញា។[102] ប្រសិនមន្ត្រីនគរបាលយុត្តិធម៌កំពុងតែធ្វើការស៊ើបអង្កេតបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលការយល់ព្រមបឋមជាលាយលក្ខណ៍អក្សរពីអ្នកកាន់កាប់ទីកន្លែងនោះជាមុនសិន។ ក្នុងករណីដែលមានការយល់ព្រមឱ្យធ្វើការឆែកឆេរឬអ្នកកាន់កាប់ទីកន្លែងអវត្តមាននោះនគរបាលយុត្តិធម៌ត្រូវទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលពាក់ព័ន្ធតាមការសុំរបស់ព្រះរាជអាជ្ញាមុននឹងធ្វើការឆែកឆេរ។[103]

### ៣.១.៣ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ

បន្ទាប់ពីបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមត្រូវបានបញ្ចប់សព្វគ្រប់ហើយនោះ។ បើតំណាងអយ្យការយល់ឃើញថារឿងក្តីត្រូវតែតម្កល់រឿងទុកឥតចាត់ការចំពោះពាក្យបណ្តឹងឬពាក្យបរិហារតំណាងអយ្យការនឹងចេញនូវដីកាមួយដែលមានឈ្មោះថា “**ដីកាតម្កល់រឿងទុកឥតចាត់ការ**”។

[99] មាត្រា៧៥ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[100] មាត្រា៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[101] មាត្រា១១១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[102] មាត្រា៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[103] មាត្រា១១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.១.៤ ការជូនដំណឹងទៅភាគីដើមបណ្តឹង

ក្រោយពេលដែលតំណាងអយ្យការចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ជំហានបន្ទាប់គឺត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត បើទោះបីជាយូរយ៉ាងណាក៏ដោយក៏មិនត្រូវឱ្យលើសពីរយៈពេល ២(ពីរ)ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបទប្បញ្ញត្តិ មាត្រា ៥០ (បញ្ជីនៃពាក្យប្តឹង)។[104]

ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ គឺជារឿងដែលចាំបាច់បំផុតរបស់ព្រះរាជអាជ្ញាក្នុងការបំពេញដើម្បីឱ្យភាគីដើមបណ្តឹងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចធ្វើការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។ ការតម្កល់រឿងទុកឥតចាត់ការគឺជានីតិវិធីមួយដែលមានលក្ខណៈស្លូតបូតរបស់អយ្យការក្នុងការមិនចោទប្រកាន់ជនល្មើសពីបទព្រហ្មទណ្ឌ។ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែងប្រកបដោយការត្រិះរិះពិចារណាឆ្លងកាត់ការស្រាវជ្រាវស៊ើបអង្កេតយ៉ាងល្អិតល្អន់ផងដែរ ហេតុដូច្នេះហើយដើម្បីធានាថាការតម្កល់រឿងទុកឥតចាត់ការប្រព្រឹត្តទៅដោយយុត្តិធម៌ត្រឹមត្រូវតាមផ្លូវច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងនៅនីតិវិធីដោះស្រាយផ្សេងៗលើចំណាត់ការប្រភេទបែបនេះ។ ដើម្បីបញ្ចៀសនៅបញ្ហាអយុត្តិធម៌កើតមានឡើងនៅក្នុងសង្គមក្នុងការពារនូវផលប្រយោជន៍របស់ជនរងគ្រោះ ក៏ដូចជាផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងឡាយផងដែរ មូលហេតុទាំងនេះក៏មិនអាចរារាំងការចោទប្រកាន់ឡើងវិញបាននោះទេ។

## ៣.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ៣.២.១ អានុភាពគ្មានអាជ្ញាអស់ជំនុំទៅលើបណ្តឹងអាជ្ញា

ចំពោះការតម្កល់រឿងទុកឥតចាត់ការ គឺពុំមានអានុភាពអាជ្ញាអស់ជំនុំនោះទេ។[105] តាមគោលការណ៍អាជ្ញាអស់ជំនុំ[106] ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរ ហើយជននោះមិនអាចត្រូវចោទប្រកាន់ម្តងទៀតទេ ចំពោះអំពើដែលបានប្រព្រឹត្តដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីមួយទៀតក៏ដោយ។ ដោយឡែកចំពោះការតម្កល់រឿងទុកឥតចាត់ការភាគីនៃជនរងគ្រោះនៅតែអាចមានសិទ្ធិប្តឹងជំទាស់ទៅកាន់ស្ថាប័នដែលទទួលបន្ទុកដោះស្រាយរឿងនេះ។

---

[104] មាត្រា៤១ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[105] មាត្រា៤១ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[106] មាត្រា១២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ៣.២.២ ផ្ដើមគិតថិរវេលាអាជ្ញាយុកាលនៃបទល្មើស

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិអំពីកិច្ចដែលត្រូវបានកាត់ផ្ដាច់រយៈពេលអាជ្ញាយុកាលនៃបទល្មើសបាន ពោលគឺនៅគ្រប់កិច្ចនៃការចោទប្រកាន់របស់អយ្យការ ឬកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ នៅពេលដែលបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗនាំឱ្យចាប់ផ្ដើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល។

ឧទាហរណ៍ដូចជាករណី៖ បទល្មើសលួច បានប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៥ តំណាងអយ្យការបានចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ដូច្នេះថិរវេលានៃបទល្មើស លួច ខាងលើត្រូវគិតរាប់សារជាថ្មី ដោយសារតែមានការផ្ដាច់ នៃអាជ្ញាយុកាលដោយកិច្ចចោទប្រកាន់របស់អយ្យការ។

### ៣.២.៣ ការរួចផុតពីការចោទប្រកាន់

ការតម្កល់រឿងទុកឥតចាត់ការអាចមានអានុភាពដល់ជនសង្ស័យឱ្យមានសេរីភាពឡើងវិញ ពោលគឺមានន័យថាជនសង្ស័យមិនត្រូវបានបញ្ជូនខ្លួនទៅកាន់មុខយុត្តាធិកាស៊ើបសួរ ឬយុត្តាធិកាជំនុំជម្រះឡើយ។ បើទោះបីជាយ៉ាងណាក៏ដោយ ការរួចផុតពីការចោទប្រកាន់នេះ គឺជាការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញាទៅលើបទល្មើសក្នុងការចោទប្រកាន់តែប៉ុណ្ណោះ។

### ៣.២.៤ ការទាមទារវត្ថុដែលរឹបអូសមកវិញ

នៅពេលដែលមានការរឹបអូសវត្ថុមកហើយ ប៉ុន្តែសំណុំរឿងត្រូវបានបិទបញ្ចប់ ដោយការចេញដីកាតម្កល់រឿងទុកឥតចាត់ការ នោះតំណាងអយ្យការអាចចេញដីកាសម្រេចឱ្យប្រគល់វត្ថុដែលរឹបអូសនោះជូនម្ចាស់ដើមវិញ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់។

## ផ្នែកទី៤៖ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

ការប្ដឹងជំទាស់នឹងការតម្កល់រឿងទុកឥតចាត់ការនេះ គឺជាយន្តការដែលសំដៅទៅលើនីតិវិធីទាំងឡាយដែលធ្វើឡើងដើម្បីឱ្យមានការចោទប្រកាន់ឡើងវិញ បន្ទាប់ពីមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ យ៉ាងណាមិញទោះបីជាព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការក៏ដោយក៏មិនមែនមានន័យថា ការសម្រេចនោះពុំមានសិទ្ធិតវ៉ា ឬមិនមានយន្តការណាមួយដើម្បីធ្វើការប្រឆាំងបានឡើយ។ ជាទូទៅមុននឹងឈានដល់ការសម្រេចមិនចោទប្រកាន់ពីបទល្មើសដោយព្រះរាជអាជ្ញាច្បាស់ណាស់ថានឹងមានការថ្លឹងថ្លែងអំពីអង្គហេតុ និងអង្គច្បាប់។ ប៉ុន្តែមិនប្រាកដថាការសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់ព្រះរាជអាជ្ញាសុទ្ធតែត្រឹមត្រូវឥតខ្ចោះនោះទេ។

ដើម្បីធានាបានភាពត្រឹមត្រូវ និងបង្ការហានិភ័យចំពោះសង្គមដែលបណ្ដាលមកពីការសម្រេចនោះជាពិសេសដើម្បីរក្សាបានប្រយោជន៍ជាគោលសម្រាប់ជនរងគ្រោះមាននីតិវិធីមួយចំនួនដែលអាចជាយន្តការប្រឆាំង

នឹងការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ យន្តការប្រឆាំងនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ រួមមាន៖

- ការសើរើសេចក្ដីសម្រេចរបស់តំណាងអយ្យការ
- បណ្ដឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- អំណាចធ្វើអធិបញ្ជាតាមនាយឋានានុក្រម និង
- ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

## ៤.១ ការសើរើកែប្រែសេចក្ដីសម្រេចរបស់តំណាងអយ្យការ

ភាពគ្មានអាជ្ញាអស់ជំនុំជាការបើកផ្លូវមួយឱ្យព្រះរាជអាជ្ញាសម្រេចការចោទប្រកាន់សារជាថ្មីលើអង្គហេតុដដែលបើក្នុងករណីព្រះរាជអាជ្ញាបានរកឃើញភាពមិនប្រក្រតី ឬភស្តុតាងថ្មីណាមួយដែលនាំឱ្យតំណាងអយ្យការអាចកំណត់បានសញ្ញាណថ្មី និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់នោះ តំណាងអយ្យការ អាចសើរើកែប្រែពីការតម្កល់រឿងទុកឥតចាត់ការមកធ្វើការចោទប្រកាន់សារជាថ្មីឡើងវិញលើកលែងតែករណីបទល្មើសនោះផុតរលត់បណ្ដឹងអាជ្ញាតែប៉ុណ្ណោះ។ ប្រសិនជាបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់ នោះតំណាងអយ្យការអាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនឡើងវិញបាន។

## ៤.២ បណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ការប្ដឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានីតិវិធីមួយដែលអនុញ្ញាតឱ្យភាគីដែលជាជនរងគ្រោះអាចធ្វើបណ្ដឹងដើម្បីប្ដឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន បើខ្លួនមិនពេញចិត្ត នឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង។ បទប្បញ្ញត្តិនៃក្រមនីតិវិធី ឆ្នាំ ២០០៧ ត្រង់មាត្រា៦ វាក្យខណ្ឌទី២ បានចែងថានៅក្នុងករណីដែលពាក្យបណ្ដឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញាជនរងគ្រោះអាចប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅតាមរបៀបដូចដែលមានចែងទុកដោយមាត្រា៤១ ការតម្កល់រឿងទុកឥតចាត់ការ។[107]

ហេតុដែលនាំឱ្យមានការប្ដឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ព្រោះថាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាអ្នកឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។ ការប្ដឹងនេះ គឺមិនមែនធ្វើឡើងដោយគ្មានគោលការណ៍ ឬលក្ខខណ្ឌនោះទេចាំបាច់ត្រូវតែមានការគោរពតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

[107] មាត្រា៦ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**៤.២.១ បុគ្គលដែលអាចដាក់ពាក្យប្តឹង**

បុគ្គលដែលអាចដាក់ពាក្យប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺសំដៅដល់ជនរងគ្រោះដែលរងព្យសនកម្មបណ្តាលមកពីអំពើល្មើសរបស់ជនល្មើស មានន័យថាជាជនដែលបានដាក់ពាក្យប្តឹងបរិហារពីបទល្មើសទៅកាន់ព្រះរាជអាជ្ញាអមសាលាដំបូង។

**៤.២.២ រយៈពេលនៃការប្តឹងតវ៉ា**

ដើម្បីងាយស្រួលក្នុងការកំណត់អំពីចិរវេលា នៃការប្តឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានកំណត់នូវសញ្ញាណមួយចំនួនដូចខាងក្រោម៖

**៤.២.២.១ ការជូនដំណឹងទៅកាន់ជនរងគ្រោះ**

កាលណាព្រះរាជអាជ្ញាដែលទទួលសំណុំរឿងបានសម្រេចតម្កល់រឿងទុកឥតចាត់ការហើយ ត្រូវជូនដំណឹងទៅអ្នកប្តឹង ឬជនរងគ្រោះពីសេចក្តីសម្រេចរបស់ខ្លួនយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល២( ពីរ ) ខែ ដោយគិតរាប់ចាប់ពីថ្ងៃដែលចុះពាក្យបណ្តឹងក្នុងបញ្ជីនៃពាក្យបណ្តឹង។

**៤.២.២.២ ការមិនបានទទួលដំណឹងពីការសម្រេចតម្កល់**

នៅក្នុងរយៈពេល០២ខែ នៃការជូនដំណឹងនេះមិនត្រូវរាប់បញ្ចូលនោះទេ បើកាលណាអ្នកប្តឹងមិនបានទទួលការជូនដំណឹង។ ការមិនបានទទួលនូវការជូនដំណឹងនេះបណ្តាលមកពីការអនុវត្តការជូនដំណឹងរបស់អាជ្ញាធរដោយសារតែមូលហេតុផ្សេងនាំឱ្យផុតរយៈពេលនៃការប្តឹងតវ៉ា។ ដូចនេះជនរងគ្រោះនៅតែអាចប្តឹងតវ៉ាបានដដែល។

**៤.២.៣ នីតិវិធីប្តឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញា**

ផ្អែកតាមមាត្រា៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបញ្ញត្តិនីតិវិធីនៃការប្តឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានរូបភាពដូចខាងក្រោម៖

**៤.២.៣.១ នីតិវិធីនៃការធ្វើបណ្តឹងតវ៉ា**

នីតិវិធីនេះមិនខុសពីនីតិវិធីបណ្តឹងព្រហ្មទណ្ឌផ្សេងទៀតប៉ុន្មាននោះទេ គឺគ្រាន់តែជនរងគ្រោះធ្វើពាក្យបណ្តឹងសាមញ្ញមួយទៅកាន់អគ្គព្រះរាជអាជ្ញាដែលពាក់ព័ន្ធប៉ុណ្ណោះ។ អង្គការអយ្យការដែលពាក់ព័ន្ធនេះគឺសំដៅដល់អយ្យការដែលជនរងគ្រោះនៃបទល្មើសបានដាក់ពាក្យប្តឹងកាលពីលើកដំបូងហើយដំណើរការនីតិវិធីដូចតាមធម្មតា។

**៤.២.៣.២ ចំណាត់ការលើពាក្យបណ្តឹងតវ៉ា**

កាលណាពាក្យបណ្តឹងរបស់ជនរងគ្រោះបានបញ្ជូនមកដល់ព្រះរាជអាជ្ញាហើយនោះព្រះរាជអាជ្ញាត្រូវបានបញ្ជូនពាក្យបណ្តឹងនោះភ្លាមទៅកាន់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចធ្វើចំណាត់ការ

ការលើពាក្យបណ្តឹងតវ៉ានោះ។ ចំណាត់ការលើពាក្យបណ្តឹងតវ៉ាដោយអគ្គព្រះរាជអាជ្ញាស្តែងចេញតាមរូបភាពចំនួនពីរដូចខាងក្រោម៖

- នៅពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនមកដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នោះអគ្គព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងពីអង្គហេតុ និងអង្គច្បាប់នៃពាក្យបណ្តឹង។ ប្រសិនបើពាក្យបណ្តឹងមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវទៅតាមពាក្យបណ្តឹងនោះអគ្គព្រះរាជអាជ្ញានឹងធ្វើអធិបញ្ញាឱ្យចោទប្រកាន់ជាលាយលក្ខណ៍អក្សរមួយទៅកាន់ព្រះរាជអាជ្ញាអមសាលាដំបូងដែលជនរងគ្រោះបានដាក់ពាក្យប្តឹង។
- ប៉ុន្តែក្នុងករណីដែលការប្តឹងនោះធ្វើឡើងដោយគ្មានមូលដ្ឋាន និងមិនមានមូលហេតុច្បាស់លាស់ត្រឹមត្រូវពិតប្រាកដទេ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងសម្រេចតម្កល់សេចក្តីសម្រេចរបស់អយ្យការអមសាលាដំបូងទុកជាបានការដដែល។ ហើយនៅក្រោយពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកជាបានការនូវការសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ខ្លួនត្រូវជូនដំណឹងពីការសម្រេចនោះ។ ដោយឡែកចិរវេលានៃការជូនដំណឹងពីសេចក្តីសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មិនមានចែងក្នុងច្បាប់ឡើយ។

ប៉ុន្តែការសម្រេចនេះមិនមានន័យថាភាគីនៃរឿងក្តីអស់ផ្លូវតវ៉ានោះទេ ដោយហេតុថានៅមាននីតិវិធីផ្សេងទៀតដែលអាចជាយន្តការប្រឆាំងនឹងការសម្រេចតម្កល់ខាងលើនេះបានដដែល ដូចការធ្វើអធិបញ្ញាតាមអំណាចឋានានុក្រមនៃអង្គការអយ្យការ និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាដើម។

## ៤.៣ អំណាចធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ

ដើម្បីធានាបាននូវសុក្រឹត្យនៃច្បាប់ និងដើម្បីធានាបាននូវគុណប្រយោជន៍ដល់សង្គមជាតិច្បាប់បានអនុញ្ញាតឱ្យមានវិធានការមួយ ដើម្បីមានអានុភាពរាំងដល់ការប្រឆាំងនឹងសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាដោយតម្កល់រឿងទុកឥតចាត់ការ។ វិធាននេះអាចបញ្ចៀសបានហានិភ័យដែលបង្កឡើងដោយការសម្រេចមិនចោទប្រកាន់ និងការរួចខ្លួនពីបទល្មើសព្រោះតែកំហុសឆ្គងរបស់ព្រះរាជអាជ្ញានៅសាលាដំបូង ដែលជាហេតុធ្វើឱ្យបាត់បង់នីតិរដ្ឋ និងសណ្តាប់ធ្នាប់សាធារណៈ។ ការធានាភាពសុក្រិត្យនៃច្បាប់នេះស្តែងឡើងតាមរយៈអំណាចធ្វើអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ។ ប៉ុន្តែឋានានុក្រមនេះគឺមិនមែនសំដៅដល់ឋានានុក្រមនៃចៅក្រមអយ្យការដែលមានចែងនៅក្នុង មាត្រា២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ នោះទេ ផ្ទុយទៅវិញគឺឋានានុក្រមនេះបានសំដៅដល់ មាត្រា២៩ នៃក្រមដដែលបានចែងពីឋានានុក្រមនៃអង្គការអយ្យការ។

ដោយអនុលោមមាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងពីឋានានុក្រមនៃអង្គការដែលមានឆន្ទានុសិទ្ធិមានអំណាចធ្វើអធិបញ្ញាបានដែលឋានានុក្រមនោះមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង
- ព្រះរាជអាជ្ញា

គួររំឭកផងដែរថាអំណាចធ្វើអធិបញ្ញាបង្គាប់ឱ្យចោទប្រកាន់តាមឋានានុក្រម នៃអង្គអយ្យការអាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់បុគ្គលដែលត្រូវបានរងការចោទប្រកាន់។ ហេតុនេះគ្រប់ការធ្វើអធិបញ្ញាចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌដែលមានជាធរមានដូចខាងក្រោម៖

### ៤.៣.១ អាជ្ញាធរដែលមានសមត្ថកិច្ចធ្វើអធិបញ្ញា

ដូចដែលយើងបានដឹងហើយថាមិនមែនគ្រប់អាជ្ញាធរទាំងអស់សុទ្ធតែមានសមត្ថកិច្ចធ្វើអធិបញ្ញានោះទេ។ ប៉ុន្តែដោយផ្អែកតាមស្មារតី មាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ យើងដឹងបានថាអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការធ្វើអធិបញ្ញាមានដូចខាងក្រោម៖

#### ៤.៣.១.១ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ដូចដែលយើងបានដឹងរួចមកហើយថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការដែលមានលំដាប់ខ្ពស់ជាងគេ ហើយក៏ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត និងពង្រឹងប្រព័ន្ធច្បាប់ដែលមានជាធរមាននៅក្នុងសង្គមជាតិទាំងមូលដែរ។ ម៉្យាងវិញទៀតក្នុងករណីដែលមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[108] ហេតុដូចនេះហើយបានជាមាត្រានេះកំណត់ពីសមត្ថកិច្ចដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មាននីតិសម្បទាអាចធ្វើអធិបញ្ញាឱ្យអង្គអយ្យការដែលនៅក្រោមអំណាចរបស់ខ្លួនធ្វើការចោទប្រកាន់ពីបទល្មើសបាន។ លើសពីនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្ដឹងបរិហារ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។[109] ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាមិនឱ្យចោទប្រកាន់បទល្មើសនោះទេ។

#### ៤.៣.១.២ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា គឺជានាយឋានានុក្រមលំដាប់ខ្ពស់បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយបើនិយាយពីតួនាទីវិញគឺបានកំណត់ដោយច្បាប់ជាធរមាន។ តួនាទីរបស់អគ្គព្រះរាជ

[108] មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[109] មាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាជ្ញាអមសាលាឧទ្ធរណ៍បានកំណត់ ដោយមាត្រា៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដោយច្បាប់បានបញ្ញត្តិថា គឺជាអ្នកឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីរបស់សាលាឧទ្ធរណ៍។[110]

បទប្បញ្ញត្តិត្រង់មាត្រានេះ បានសេចក្តីថាគ្រប់ព្រះរាជអាជ្ញាទាំងអស់ដែលជាតំណាងអយ្យការនៅអមសាលាជម្រះក្តីនីមួយៗនៅតាមបណ្តារាជធានីខេត្ត-ក្រុង គឺត្រូវស្ថិតក្រោមឋានានុក្រមនៃសមត្ថកិច្ចដែនដីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តំបន់នីមួយៗ ដូចដែលមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ទាំងបួន ពោលគឺមុន ឆ្នាំ២០១៩ សាលាឧទ្ធរណ៍មានតែមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។

ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ទាំងបួន កាលណាអគ្គព្រះរាជអាជ្ញាក្នុងសមត្ថកិច្ចដែនដីណាមួយដែលបានទទួលពាក្យប្តឹងពីព្រះរាជអាជ្ញា ឬតាមការយល់ឃើញរបស់ខ្លួននោះអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់បាន។ ដូចនេះអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។[111]

**៤.៣.១.៣ ព្រះរាជអាជ្ញា**

ដូចដែលយើងបានដឹងរួចមកហើយថា ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺតំណាងអយ្យការអមសាលាដំបូង ហើយព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិអំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន។ ព្រះរាជអាជ្ញារងចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។[112] ដូចនេះនៅពេលដែលនិយាយដល់សមត្ថកិច្ចដែលមានសិទ្ធិធ្វើអធិបញ្ញាដែលកំណត់ថាជាព្រះរាជអាជ្ញានៅត្រង់នេះ គឺសូមកុំមានការយល់ច្រឡំថាគ្រប់ព្រះរាជអាជ្ញាទាំងអស់សុទ្ធតែអាចធ្វើអធិបញ្ញាបានឱ្យសោះ ដោយហេតុថា ពាក្យថាព្រះរាជអាជ្ញានៅត្រង់នេះ គឺសំដៅដល់ព្រះរាជអាជ្ញាអមសាលាដំបូង។ ដូច្នេះនៅពេលដែលព្រះរាជអាជ្ញារងបានសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយព្រះរាជអាជ្ញាបានដឹងពីការសម្រេច ដោយខ្លួនយល់ឃើញថាការសម្រេចមិនសមស្រប ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាបាន ដោយផ្អែកតាម មាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ដោយហេតុថាមាត្រាដដែលនេះបានកំណត់ឋានានុក្រមនៃអង្គអយ្យការដែលអាចធ្វើអធិ

[110] មាត្រា៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[111] មាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[112] មាត្រា៣០ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

បញ្ជាបាន ដោយក្នុងនោះបានចែងថា ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលខ្លួនយល់ឃើញថាជាការគួរ។[113]

ថ្វីត្បិតតែច្បាប់បានផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរដែលមានសមត្ថកិច្ចធ្វើអធិបញ្ជាក៏ពិតមែន ប៉ុន្តែមិនមែនមានន័យថា ចេះតែធ្វើតាមខ្លួនយល់ឃើញ ហើយអាចធ្វើអធិបញ្ជាបានដោយមិនមានលក្ខណៈនោះទេ។ យ៉ាងហោចណាស់អាជ្ញាធរដែលមានសមត្ថកិច្ចធ្វើអធិបញ្ជាត្រូវតែគោរពនូវលក្ខខណ្ឌចំនួនពីរដូចខាងក្រោម៖

- **លក្ខខណ្ឌទម្រង់៖** ការធ្វើអធិបញ្ជាឱ្យចោទប្រកាន់មិនមែនចេះតែធ្វើទៅបានដោយមានការណែនាំត្រឹមត្រូវជាការនិយាយដោយផ្ទាល់ ដោយពុំបានធ្វើឡើងជាលាយលក្ខណ៍អក្សរបានឡើយ ព្រោះកាលណាអាចធ្វើបានដោយផ្ទាល់មាត់វាហាក់បីដូចជា ការនិយាយចោលដោយគ្មានសំអាងហេតុច្បាស់លាស់ឡើយ។ ម្យ៉ាងទៀតសោត ទោះមិនចោទប្រកាន់ ឬមិនធ្វើតាមក៏បានដោយហេតុថា គ្រាន់តែជាការពោលពាក្យដោយផ្ទាល់មិនមានលិខិតផ្លូវការតាមបែបរដ្ឋបាលណាមួយឡើយ។
- **លក្ខខណ្ឌខ្លឹមសារនៃការធ្វើអធិបញ្ជា៖** ដោយហេតុថាការធ្វើអធិបញ្ជាទៅឋានានុក្រមក្រោមឱវាទរបស់ខ្លួនដើម្បីឱ្យចោទប្រកាន់ពីបទល្មើសអាចបណ្តាលឱ្យបាត់បង់នូវសេរីភាពរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ ហេតុនេះការធ្វើអធិបញ្ជាចាំបាច់ត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់ឱ្យបានច្បាស់លាស់ចំពោះទោសកំហុសនៃជននោះ។ ការធ្វើបែបនេះបង្ការបានការចោទប្រកាន់ដោយមិនត្រឹមត្រូវ និងអាចការពារបាននូវតម្លៃនៃនីតិរដ្ឋ។

## ៤.៤ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ដោយហេតុថាមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ពីសំណាក់ព្រះរាជអាជ្ញា និងហេតុថាជនរងគ្រោះនៃអំពើពុំសុខចិត្តនឹងការសម្រេចនោះ ច្បាប់បានផ្តល់សិទ្ធិឱ្យជននោះធ្វើការទាមទារបានបន្ថែមទៀត មិនមែនក្រោយពីមានការប្រកាសសម្រេចតម្កល់ដោយព្រះរាជអាជ្ញាអមសាលាដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជាការសម្រេចដែលបិទផ្លូវតវ៉ានោះទេ។ នៅពេលដែលជនណាម្នាក់បានគិតថាខ្លួនបានទទួលរងនូវព្យសនកម្មដែលបង្កឡើងដោយជនល្មើស ជននោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមបានបើកាលណាមិនទាន់បានទទួលសំណងសមរម្យ។ ការអាចដាក់ពាក្យប្តឹងបែបនេះបានដោយអនុលោមតាម មាត្រា៥ ដោយមាត្រានេះបានចែងថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺធ្វើឡើងនៅចំពោះមុខចៅក្រមស៊ើបសួរ។[114]

---

113 មាត្រា២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

114 មាត្រា៥ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**តើអ្វីទៅជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ?**

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរគឺជានីតិវិធីមួយដែលអាចអនុញ្ញាតឱ្យជនរងគ្រោះនៃបទល្មើស ដែលរងនូវព្យសនកម្មពីអំពើបង្កឡើងដោយជនល្មើសអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរក្នុងគោលបំណងធ្វើបណ្តឹងទាមទារឱ្យចៅក្រមស៊ើបសួរបើកការស៊ើបអង្កេតលើសំណុំរឿងដែលបានតម្កល់ដោយព្រះរាជអាជ្ញា។ ជាគោលការណ៍គ្មានការស៊ើបសួរណាមួយដែលអាចធ្វើទៅបានដោយគ្មានការចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរដោយព្រះរាជអាជ្ញាឡើយកាលណាគ្មានដីកាសន្និដ្ឋានដោយព្រះរាជអាជ្ញានាំឱ្យមោឃភាព។ ប៉ុន្តែដើម្បីធានាដល់សិទ្ធិនិងដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះនោះច្បាប់បានអនុញ្ញាតឱ្យធ្វើទៅបាន។ វាមិនចម្លែកទេដែលក្រមនីតិវិធីព្រហ្មទណ្ឌបានបើកសិទ្ធិឱ្យជនរងគ្រោះអាចធ្វើបណ្តឹងទាមទារបែបនេះបានដោយហេតុថារាល់ការប្តឹងបរិហារទៅតុលាការគឺមិនមែនគ្រាន់តែចង់ឱ្យជនល្មើសជាប់ពន្ធនាគារប៉ុណ្ណោះទេ។ ផ្ទុយទៅវិញការប្តឹងនោះថែមទាំងបានទាមទារឱ្យមានសេចក្តីសម្រេចដោយតុលាការដើម្បីឱ្យជនល្មើសសងសំណងដល់ខ្លួនទៀតផង ព្រោះអំពើនៃជនល្មើសបានធ្វើឱ្យមានការខូចខាតដល់ខ្លួន។ បណ្តឹងនេះ គឺជាការទាមទារនូវសំណងសមល្មមនៃព្យសនកម្មរបស់ជនរងគ្រោះ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។

ដើម្បីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅមុខចៅក្រមស៊ើបសួរបាន លុះត្រាតែត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

### ៤.៤.១ លក្ខខណ្ឌនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

#### ៤.៤.១.១ អ្នកប្តឹងត្រូវតែជាជនរងគ្រោះនៃបទល្មើស

ជាគោលការណ៍មិនមែនគ្រប់បុគ្គលសុទ្ធតែអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបាននោះទេ មានតែជនរងគ្រោះនៃបទល្មើសប៉ុណ្ណោះដែលមានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ នេះមានន័យថាបុគ្គលគ្រប់រូបដែលបានប្រកាសថាខ្លួនជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។[115]

#### ៤.៤.១.២ ការដាក់ពាក្យប្តឹង និងកម្មវត្ថុនៃពាក្យប្តឹង

ជាការពិតណាស់ការដាក់ពាក្យប្តឹងដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ត្រូវតែដាក់ពាក្យប្តឹងទៅកាន់ចៅក្រមស៊ើបសួរ ហើយការដាក់ពាក្យបណ្តឹងនោះចាំបាច់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នៅមូលហេតុនៃការទាមទារក្នុងពាក្យប្តឹង វាមិនចម្លែកទេចំពោះការសរសេរបញ្ជាក់នៅក្នុងបណ្តឹងដោយបញ្ជាក់ថាជាការ

[115] មាត្រា១៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថាកាលណាពាក្យបណ្តឹងនោះមិនបញ្ជាក់ថាខ្លួនដាក់ពាក្យប្តឹងដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីទេ ពាក្យប្តឹងនោះគ្រាន់តែជាពាក្យប្តឹងសាមញ្ញធម្មតាមួយប៉ុណ្ណោះ។ ហើយប្រសិនបើពាក្យបណ្តឹងនោះមិនមានកម្មវត្ថុស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ គឺវាពុំមានអានុភាពដែលឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចពីការបើកការស៊ើបសួរបានឡើយ។

### ៤.៤.១.៣ អាជ្ញាធរដែលមានសមត្ថកិច្ចបើកការស៊ើបសួរ

ជាគោលការណ៍ ការសម្រេចមិនតម្កល់រឿងទុកឥតចាត់ការ ឬក៏ការសម្រេចបើកការស៊ើបសួរ គឺការផ្តោតទៅលើសមត្ថកិច្ច គឺតែងតែស្ថិតនៅមុនគេបង្អស់មុននឹងចាប់ដំណើរការ។ ដោយផ្អែកតាមច្បាប់ជាធរមានការបើកការស៊ើបសួរ គឺធ្វើឡើងដោយចៅក្រមស៊ើបសួរនៃសាលាដំបូង-ខេត្ត។ ប៉ុន្តែអ្វីដែលជាមន្ទិលនៅត្រង់ថា តើចៅក្រមស៊ើបសួរណាមួយដែលមានសមត្ថកិច្ចចំពោះពាក្យបណ្តឹងរបស់ជនរងគ្រោះ ? តាមការពិតទៅការលើកឡើងពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ គឺចង់សំដៅដល់ដែនដីដែលចៅក្រមនោះបំពេញការងារសមត្ថកិច្ចរបស់ខ្លួនចំពោះរាល់សំណុំរឿងដែលកើតមាននៅក្នុងដែនដីនោះ។

បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ត្រង់គន្លីទី៥ មាតិកាទី១ ស្តីពីចៅក្រមស៊ើបសួរបានចែងយ៉ាងច្បាស់ពីសមត្ថកិច្ចនៃដែនដីរបស់ចៅក្រមស៊ើបសួរដែលមានដូចខាងក្រោម៖

- ចៅក្រមស៊ើបសួរនាទីកន្លែងប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាប្រព្រឹត្តបទល្មើស។
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ ការបញ្ជាក់យ៉ាងច្បាស់លាស់ពីសមត្ថកិច្ចដែនដីនៃចៅក្រមស៊ើបសួរដើម្បីបង្ការក្រែងមានការជាន់ដែនសមត្ថកិច្ចគ្នា ឬមានទំនាស់សម្ថកិច្ចក្នុងការអនុវត្ត។ ក្នុងករណីដែលមានទំនាក់ទំនងរវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នាហើយទទួលបណ្តឹងទាំងអស់គ្នាអំពីរឿងក្តីតែមួយដូចគ្នាទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ ការបញ្ជាក់យ៉ាងច្បាស់លាស់ពីសមត្ថកិច្ចដែនដីនៃចៅក្រមស៊ើបសួរ ព្រោះតែបង្ការក្រែងមានការជាន់សមត្ថកិច្ចគ្នា ឬមានទំនាស់សមត្ថកិច្ចក្នុងការអនុវត្ត។[116]

### ៤.៤.១.៤ ការបង់ប្រាក់តម្កល់

ដើម្បីធានាបាននូវការបង្ការហានិភ័យផលវិបាកដែលអាចបណ្តាលមកពីបទល្មើស និងដោយផ្អែកទៅលើធនធាននៃបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុនចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ព្រមទាំងរយៈពេលដែល

[116] មាត្រា១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ត្រូវបង់ប្រាក់នេះផង។ ទាំងនេះគឺបញ្ញត្តិឡើងដោយច្បាប់ ដើម្បីការពារជាមុននូវផលវិបាកចំពោះដំណើរការនីតិវិធីនៃបណ្ដឹង។ ប៉ុន្តែប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន។[117] ហើយការសម្រេចមិនបង់ប្រាក់តម្កល់នេះ គឺត្រូវចេញដីកាជូនដំណឹងជាបន្ទាន់ទៅដើមបណ្ដឹងរដ្ឋប្បវេណី។

### ៤.៤.២ នីតិវិធីនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ច្បាប់បានចែងថាជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។[118] ការដាក់ពាក្យប្ដឹងនេះ គឺធ្វើឡើងដោយជនរងគ្រោះផ្ទាល់ដោយសារបទល្មើស ឬដោយមេធាវីតំណាងឱ្យជនរងគ្រោះ។

ការដាក់ពាក្យប្ដឹងនៅចំពោះមុខចៅក្រមស៊ើបសួរ វាមិនខុសគ្នាអ្វីពីការដាក់ពាក្យប្ដឹងដើម្បីឱ្យបណ្ដឹងអាជ្ញាមានចលនាឡើយ ដោយហេតុថាពាក្យប្ដឹងគឺ ដើម្បីសុំឱ្យមានកាស៊ើបសួរចំពោះបទល្មើសដែលត្រូវបានសម្រេចតម្កល់មិនចាត់ការដោយព្រះរាជអាជ្ញានៅសាលាដំបូង។ នៅគ្រប់ពេលដែលចៅក្រមស៊ើបសួរបានទទួលពាក្យបណ្ដឹងរបស់ជនរងគ្រោះដោយការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នោះចៅក្រមស៊ើបសួរត្រូវជូនដំណឹងបន្ទាន់មួយពីការដាក់ពាក្យប្ដឹងនោះ ទៅកាន់ព្រះរាជអាជ្ញាដែលទទួលបន្ទុកសំណុំរឿងនោះនៅដំណាក់កាលអយ្យការ និងជនត្រូវចោទ។

### ៤.៤.៣ ចំណាត់ការលើពាក្យបណ្ដឹងដើម្បីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

ជាគោលការណ៍កិច្ចស៊ើបសួរមិនអាចត្រូវបានធ្វើឡើងឡើយប្រសិនបើគ្មានដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ប៉ុន្តែប្បញ្ញត្តិនេះមិនមែនជាប្បញ្ញត្តិដាច់ខាតទេ ព្រោះចៅក្រមស៊ើបសួរនៅតែអាចបើកការស៊ើបសួរបានដដែល បើកាលណាចៅក្រមស៊ើបសួរនោះបានទទួលពាក្យប្ដឹងដើម្បីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយជនរងគ្រោះដោយសារតែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។ ការដែលចាត់ទុកថាជនរងគ្រោះដែលមានសិទ្ធិក្នុងការធ្វើបណ្ដឹងដើម្បីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះចៅក្រមស៊ើបសួរបាន លុះត្រាតែជននោះជាជនរងគ្រោះដោយផ្ទាល់ពីបទល្មើស។

នីតិវិធីក្នុងការធ្វើចំណាត់ការលើពាក្យបណ្ដឹងប្រភេទនេះអាចស្ដែងឡើងតាមរយៈរូបភាពដូចខាងក្រោម៖

- កាលណាចៅក្រមស៊ើបសួរឃើញយល់ថា ពាក្យបណ្ដឹងនោះមិនសមហេតុសមផល និងមានសំអាងហេតុតាមផ្លូវច្បាប់ដែលអាចអះអាងថាខ្លួនរងគ្រោះដោយសារតែបទល្មើសនោះ ចៅក្រមស៊ើបសួរដែលទទួល

[117] មាត្រា១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[118] មាត្រា១៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បានពាក្យប្តឹងសម្រេចថាមិនបើកការស៊ើបសួរ។ ការសម្រេចមិនបើកឡើងតាមរយៈដីកាសម្រេច ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ។

- កាលណាចៅក្រមស៊ើបសួរយល់ថា ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានសំអាងហេតុតាមផ្លូវច្បាប់គ្រប់គ្រាន់សម្រាប់បើកការស៊ើបសួរ ស្តែងឡើងតាមរយៈដីកាសម្រេចដោយក្នុងនោះត្រូវតែមានការបញ្ជាក់សំអាងហេតុ និងច្បាប់ច្បាស់លាស់ ហើយត្រូវបញ្ជូនបន្ទាន់ទៅព្រះរាជអាជ្ញា។ ក្រោយពីបានទទួលដីកាបញ្ជូនពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[119]

[119] មាត្រា១៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី៣

# គុណសម្បត្តិ និងគុណវិបត្តិ នៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

# ជំពូកទី៣

# គុណសម្បត្តិនិងគុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ផ្នែកទី១៖ គុណសម្បត្តិ នៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

យើងបានដឹងហើយថាកាលណាមានការអនុវត្តនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ គឺអាចផ្តល់ផលប្រយោជន៍ជាច្រើនដល់សង្គមជាតិដូចជា៖

### ១.១ ការទទួលបានផលប្រយោជន៍របស់ជនសង្ស័យពីការតម្កល់រឿងទុកឥតចាត់ការ

ចំពោះការតម្កល់រឿងទុកឥតចាត់ការនេះ ជនសង្ស័យទទួលបានផលប្រយោជន៍ពីការតម្កល់រឿងទុកឥតចាត់ការរួមមាន:

- ការរួចផុតពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺទទួលបាននូវភាពយុត្តិធម៌និងទទួលបានសេរីភាព។
  ឧទាហរណ៍៖ លោកស្រី **ក** បានដាក់ពាក្យបណ្តឹងប្តឹងលោកស្រី **ខ** មកកាន់តំណាងអយ្យការជាករណីឆបោក ក្រោយពីតំណាងអយ្យការលោកបានកោះហៅភាគីទាំងសងខាងមកសាកសួររួចមកឃើញថា ឯកសារ និងភស្តុតាងគឺជារឿងវិវាទកិច្ចសន្យាដោយកើតចេញពីការខ្ចីប្រាក់និងដាក់បញ្ចាំឬការចងការប្រាក់នេះជាហេតុដែលធ្វើឱ្យតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ទៅលើលោកស្រី **ខ** ដោយលោកបានតម្កល់រឿងទុកឥតចាត់ការតែម្តង។
- កាលណាព្រះរាជអាជ្ញាស៊ើបអង្កេតជុំវិញសំណុំរឿងឃើញថា គ្មានបទល្មើសណាមួយកើតឡើងនោះទេដែលជាហេតុនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ នេះជាមូលហេតុដែលនាំឱ្យបានជាប្រយោជន៍ដល់បុគ្គលដែលទទួលរងនូវការចោទប្រកាន់មិនសមហេតុផល។
  ឧទាហរណ៍៖ បុគ្គល **ក** បានចោទប្រកាន់ថា បុគ្គល **ខ** បានលួចទូរស័ព្ទដៃរបស់ខ្លួនប៉ុន្តែបុគ្គល **ក** ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់ជូនព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់បុគ្គល **ខ** នោះទេបន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការស៊ើបអង្កេតលើសំណុំរឿងរួចមកឃើញថាបុគ្គល **ក** ចេះតែចោទប្រកាន់លើបុគ្គល **ខ** ថាបានលួចទូរស័ព្ទរបស់ខ្លួននេះជាហេតុដែលធ្វើឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់សំណុំរឿងទុកឥតចាត់ការ។
- ទោះបីជាការចោទប្រកាន់ក៏ដោយការតម្កល់រឿងទុកឥតចាត់ការក៏ដោយបើប្រព្រឹត្តទៅដោយភាពស្របច្បាប់នោះប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត។
- ធ្វើឱ្យប្រជាពលរដ្ឋមានជំនឿចិត្តទៅលើការសម្រេចសេចក្តីរបស់ស្ថាប័នតុលាការស្របតាមសុច្ឆរិតភាព។

## ១.២ ការកាត់បន្ថយការកកស្ទះសំណុំរឿង

ដោយសារតែកន្លងមកមានការកកស្ទះសំណុំរឿងជាច្រើននៅដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះដោយហេតុថា ចៅក្រមអយ្យការបានថ្លឹងថ្លែងប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការជម្រះចោលចំពោះបទល្មើសតូចតាចមួយចំនួនដែលបង្កព្យសនកម្ម ក្នុងរូបភាពតិចតួចដល់សង្គមជាតិជាងចំណាយពេលលើរឿងក្ដីដែលស្មុគស្មាញមកដោះស្រាយ។ ម៉្យាងវិញទៀតការតម្កល់រឿងទុកឥតចាត់ការក៏អាចជួយសម្រាលបន្ទុកចំពោះការកកស្ទះពាក្យបណ្ដឹងទៅតុលាការដោយទុកពេលវេលា និងលទ្ធភាពតុលាការយកចិត្តទុកដាក់ទៅលើតែបទល្មើសណាដែលបង្កព្យសនកម្មធ្ងន់ធ្ងរទៅដល់សង្គមជាតិ ឬគ្រោះថ្នាក់ហានិភ័យសម្រាប់ប្រទេសជាតិទាំងមូលផងដែរ។ ការធ្វើបែបនេះនឹងនាំឱ្យដំណើររឿងក្ដីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព និងធានាបាននូវយុត្តិធម៌ដល់សង្គម។ ហើយសំណុំរឿងដែរអាចឱ្យចៅក្រមអយ្យការធ្វើការតម្កល់រឿងទុកឥតចាត់ការ ដែលបានជួយកាត់បន្ថយទៅលើការកកស្ទះសំណុំរឿងបាននោះគឺបទល្មើសបរិហារកេរ្តិ៍ជាសាធារណៈ ព្រោះបទល្មើសនេះជាបទល្មើសតូចតាចតែប៉ុណ្ណោះ ហើយអង្គហេតុនៃបទល្មើសពេលខ្លះអាចជាកូនបំណុលប្ដឹងម្ចាស់បំណុលជាដើម ដោយសារតែម្ចាស់បំណុលខឹងនឹងកូនបំណុលជំពាក់ប្រាក់ ហើយបានព្យាយាមគេចវេស ដោយបានប្លុកលេខទូរស័ព្ទឬប្លុកឆាតដែរកត្តាទាំងនេះហើយធ្វើឱ្យម្ចាស់បំណុលខឹងទើបបង្ហោះរូបភាពកូនបំណុលតែម្ដង។ ដោយសារតែកត្តាទាំងនេះហើយបានធ្វើឱ្យចៅក្រមអយ្យការលោកធ្វើការតម្កល់សំណុំរឿងនោះទុកឥតចាត់ការ។ ចំណែកឯមួយករណីទៀតពេលខ្លះបុគ្គលដែលជាអ្នកប្ដឹងបានប្ដឹងមកដោយពុំមានសាវតាររបស់ជនល្មើសគ្រប់គ្រាន់ ដោយគ្រាន់តែមានឈ្មោះតែមួយម៉ាត់ និងគ្មានអាសយដ្ឋានច្បាស់លាស់និងគ្រប់គ្រាន់ដែលធ្វើឱ្យចៅក្រមអយ្យការពិបាកធ្វើការចោទប្រកាន់ទៅកាន់ចៅក្រមស៊ើបសួរ ពីព្រោះពាក្យបណ្ដឹងគ្មានសាវតារគ្រប់គ្រាន់ ដោយហេតុថាចោទទៅអាចធ្វើឱ្យចៅក្រមស៊ើបសួរពិបាកក្នុងការស្វែងរក មូលហេតុទាំងនេះគឺអាចធ្វើឱ្យមានការកកស្ទះសំណុំរឿង។

## ១.៣ ការកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ

ប្រសិនបើចៅក្រមអយ្យការជ្រើសរើសការមិនចោទប្រកាន់នោះពុំមានឡើយ នៃការឃុំខ្លួនជាបណ្ដោះអាសន្ន ហើយអាចគ្មានការប្រកាសពិរុទ្ធភាព និងទោសផងដែរ។ ម៉្យាងវិញទៀត ការផ្ដល់លទ្ធភាពឱ្យសង្គមជាតិកសាងនូវធនធានមនុស្សដោយរួមការអប់រំ នោះក៏អាចជាកម្លាំងចលករដល់ការអភិវឌ្ឍជាតិ។ ដោយឡែកបទល្មើសទាំងអស់មិនប្រាកដថាសុទ្ធតែបំពាន ឬផ្ដល់ព្យសនកម្មខ្លាំងក្លាដល់ផលប្រយោជន៍របស់បុគ្គល និងសន្តិសុខសង្គមនោះទេ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះបទល្មើសទាំងនោះ មានន័យថាស្ថាប័នតុលាការបានផ្ដល់ឱកាសឱ្យជនទាំងនោះបានកែប្រែខ្លួនក៏ដូចជាបានលើកទឹកចិត្តឱ្យសង្គមទាំងមូលមានការរួបរួមគ្នាដើម្បីការអភិវឌ្ឍធនធានមនុស្សជាជាងដែលទុកជននោះក្នុងពន្ធនាគារដោយមិនបានផ្ដល់ផលប្រយោជន៍

និងថែមទាំងជាបន្ទុករបស់រដ្ឋក្នុងការចំណាយថវិការដ្ឋច្រើនហួសប្រមាណជាងតម្រូវការចាំបាច់ ដែលរដ្ឋមានទំនួលខុសត្រូវជាងគេ។ ហើយការធ្វើបែបនេះនឹងនាំឱ្យការចំណាយលើថវិការដ្ឋមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌ពិនិត្យឃើញថានៅក្នុងរយៈពេល ០១(មួយ)ឆ្នាំ ០១ (មួយ) ខែ នៃការអនុវត្តយុទ្ធនាការខាងលើសាលាដំបូងរាជធានីខេត្តបានចូលរួមអនុវត្តប្រកបដោយការយកចិត្តទុកដាក់ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ នូវគោលការណ៍ណែនាំដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទាំង ៣ ខាងលើ នៃដំណើរការនីតិវិធីតុលាការ។ ជាលទ្ធផលឃើញថាទាំងសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះទាំងសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មីជាច្រើនត្រូវបានតុលាការចាត់ការបានយ៉ាងឆាប់រហ័សស្របតាមនីតិវិធីច្បាប់ ហើយបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារបានមួយកម្រិតផងដែរ ដែលមានខ្លឹមសារលម្អិតដូចមានក្នុងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌។ ដោយផ្អែកលើលទ្ធផលល្អប្រសើរនៃការអនុវត្តគោលការណ៍ណែនាំក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធនាការខាងលើ និងដោយយោងតាម ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ព្រមទាំងសេចក្តីណែនាំរួមនឹងសារាចរណ៍ពាក់ព័ន្ធនានាក៏ដូចជាដើម្បីពន្លឿនចំណាត់ការនីតិវិធីនៅក្នុងសំណុំរឿង និងដើម្បីចូលរួមចំណែកដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ ពិសេសក្នុងបរិបទនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំជាថ្មីដល់សាលាដំបូងរាជធានីខេត្តឱ្យបន្តអនុវត្ត គោលការណ៍ណែនាំដែលត្រូវបានកំណត់នៅក្នុងសេចក្តីណែនាំលេខ ០១ កយ.សណន ២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០២០។ វិធីនៃការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ មានចែងនៅក្នុងមាត្រា ៤៣ និងមាត្រាពាក់ព័ន្ធបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមមាត្រា ៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នីតិវិធីនៃការចោទប្រកាន់រួមមាន ៖ (១)-ការបើកការស៊ើបសួរ(២)-ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ និង(៣)-ការបង្ហាញខ្លួនភ្លាម។ កន្លងមកក្រសួងយុត្តិធម៌បានពិនិត្យឃើញថា អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ពុំសូវបានប្រើវិធីចោទប្រកាន់តាមរយៈការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ ឬការបង្ហាញខ្លួនភ្លាមនោះទេ ក៏ប៉ុន្តែតែងប្រើវិធីចោទប្រកាន់ចំពោះបទមជ្ឈិមតាមរយៈ ការបើកការស៊ើបសួរដែលជាបច្ច័យនាំឱ្យមានការកើនឡើងជាច្រើននូវសំណុំរឿងនៅក្នុងដំណាក់កាលស៊ើបសួរ។ ដើម្បីពន្លឿនចំណាត់ការលើសំណុំរឿងជាពិសេសការកាត់បន្ថយការកកស្ទះសំណុំរឿងនៅក្នុងដំណាក់កាលស៊ើបសួរ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំលើកទឹកចិត្តឱ្យអយ្យការអមសាលាដំបូងរាជធានី-ខេត្តទាំងអស់យកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការផ្តល់អាទិភាពប្រើវិធីចោទប្រកាន់ចំពោះបទមជ្ឈិម តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការបង្ហាញខ្លួនភ្លាម ដោយផ្អែកតាមអង្គហេតុនៅក្នុងសំណុំរឿងនីមួយៗ និងផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[120]

[120] សេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌លេខ ០៣ កយ.សណន/២១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១

ឧទាហរណ៍ៈ បទល្មើសណាមួយដែលមានកម្រិតស្រាលគួរតែអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន បទល្មើសណាដែលមិនចាត់ទុកជាបទល្មើសគួរមិនចោទប្រកាន់ដូចជា អ្នកធ្វើការងារសង្គមបរិស្ថានឬសិទ្ធិមនុស្សជាដើមដែលគាត់ធ្វើការងារ ដើម្បីជួយសង្គមមិនគួរមានការចោទប្រកាន់ទេ នេះក៏ជួយកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារផងដែរ។ អ្វីដែរសំខាន់បំផុតនោះគឺរដ្ឋាភិបាលក៏ដូចជាក្រសួងយុត្តិធម៌ត្រូវធ្វើយ៉ាងមិចដើម្បីមានការផ្សព្វផ្សាយ ឬការទប់ស្កាត់កុំឱ្យមានកំណើនបទល្មើសច្រើនពេក ព្រោះវាអាចមានកំណើនបទល្មើសច្រើនពេក ព្រោះវាអាចមានកំណើននៃភាពចង្អៀតណែននៅក្នុងពន្ធនាគារផងដែរ ហើយអាចប៉ះពាល់ដល់សិទ្ធិអ្នកជាប់ឃុំទៀតផង។

## ១.៤ ការផ្តល់លទ្ធភាពដល់ជនដែលប្រព្រឹត្តកំហុសអាចកែប្រែខ្លួន និងកសាងសង្គមជាតិ

ផ្ទុយពីការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ហើយជំនួសដោយការតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើសដែលមានលក្ខណៈតិចតួច និងមិនបានធ្វើឱ្យខូចខាតដល់សង្គមមនុស្ស ឬអំពើនោះបង្កើតបានជាការគំរាមកំហែងដល់សុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរ ឬធ្វើឱ្យប៉ះពាល់ដល់សីលធម៌ និងវប្បធម៌ដ៏ល្អផូរផង់របស់សង្គមជាតិគឺជាការប្រសើរ។ការសម្រេចមិនធ្វើការចោទប្រកាន់នេះគឺជាការផ្តល់លទ្ធភាពមួយដល់ជនដែលបានប្រព្រឹត្តកំហុសអាចកែប្រែកំហុសរបស់ខ្លួននិងកសាងខ្លួនជាថ្មីហើយរស់នៅជាមួយសង្គមជាតិឡើងវិញ។ ម៉្យាងវិញទៀតនៅពេលដែលព្រះរាជអាជ្ញាសម្រេចមិនធ្វើការចោទប្រកាន់វាក៏ជាឱកាសសម្រាប់ការកសាងធនធានមនុស្សសម្រាប់សង្គម ដោយហេតុថាអំពើខ្លះបានប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៨ឆ្នាំដែលសុទ្ធសឹងតែជាទំពាំងស្នងឬស្សី។ នេះមិនមែនមានន័យថា ជាការមិនចោទប្រកាន់ទោសចំពោះអ្នកប្រព្រឹត្តផ្ទុយនឹងច្បាប់នោះទេ ប៉ុន្តែវាគឺជាការផ្តល់ឱកាសដល់អនីតិជននោះបានកែប្រែកំហុស។ ដោយផ្អែកតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺពុំបានអនុញ្ញាតឱ្យមានការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌចំពោះអនីតិជនអាយុក្រោម១៨ឆ្នាំឡើយ។ នេះក៏ដោយសារតែអនីតិជននៅមិនទាន់មានការគិតពិចារណាគ្រប់ជ្រុងជ្រោយចំពោះការវិនិច្ឆ័យតាមផ្លូវច្បាប់បាន។ ការកសាងសង្គមជាតិចាំបាច់ត្រូវតែមានការចូលរួមជាចាំបាច់ពីសំណាក់យុវជនដូចនេះការមិនចោទប្រកាន់ គឺជាឱកាសសម្រាប់កសាងសង្គមជាតិតាមរយៈយុវជននោះ នៅពេលដែលពួកគេបានទទួលការអប់រំ។

ឧទាហរណ៍៖ ក្មេងប្រុសម្នាក់មានអាយុក្រោម១៨ឆ្នាំ ហើយក្មេងនោះជាមនុស្សល្អចេះស្តាប់បង្គាប់ឪពុកម្តាយ ស្រាប់តែនៅថ្ងៃមួយក្មេងប្រុសនោះបានស្គាល់ក្រុមក្មេងទំនើងមួយក្រុមដែលមានអាយុបងគេចាប់ពី៤ទៅ៥ឆ្នាំ ក៏បានទៅចូលរួមជាបក្សពួកជាមួយក្រុមក្មេងទំនើងនោះ ហើយក្រុមក្មេងទំនើងនោះក៏បានទៅមានជម្លោះជាហិង្សាជាមួយបុគ្គលផ្សេងទៀត ពេលនោះសមត្ថកិច្ចក៏បានឃាត់ខ្លួនក្រុមក្មេងទំនើងនោះ រួមទាំងក្មេងប្រុសដែលមានអាយុក្រោម១៨ឆ្នាំនោះផងដែរ រួចក៏បានប្រគល់ក្រុមក្មេងទំនើងនោះទៅកាន់តំណាងអយ្យការនៅពេល

នោះឪពុកម្ដាយរួមទាំងអ្នកភូមិក្មេងប្រុសនោះបានទៅដល់តុលាការ ក៏បាននិយាយប្រាប់ពីតំណាងអយ្យការថា កូនរបស់គាត់ល្អណាស់មិនដែរចេះបង្កបញ្ហាជាមួយនរណាឡើយ បន្ទាប់មកតំណាងអយ្យការក៏បានសួរទៅអ្នកភូមិ អ្នកភូមិនោះបានឆ្លើយដូចទៅនឹងឪពុកម្ដាយក្មេងប្រុសនោះដែរបន្ទាប់មកតំណាងអយ្យការក៏បានឱ្យឪពុកម្ដាយនាំក្មេងប្រុសនោះទៅផ្ទះវិញដើម្បីយកទៅអប់រំនិងណែនាំបន្ថែមកុំឱ្យដើរផ្លូវខុសជាមួយនឹងក្រុមក្មេងទំនើងទាំងនោះទៀត។

## ផ្នែកទី២៖ គុណវិបត្តិ នៃការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ទន្ទឹងនឹងមានគុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញខាងលើ ក៏មានគុណវិបត្តិមួយចំនួនកើតឡើងផងដែរ ហើយការកើតឡើងនូវគុណវិបត្តិនោះយើងខ្ញុំនិងពន្យល់បកស្រាយនៅចំណុចខាងក្រោមរួមមាន៖

### ២.១ ការខូចខាតផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

ក្នុងបណ្ដឹងព្រហ្មទណ្ឌប្រជាពលរដ្ឋជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវរៀបចំធ្វើពាក្យបណ្ដឹងតាមគោលការណ៍ដែលបង្ហាញអំពីអង្គហេតុនៃបណ្ដឹងនោះឱ្យបានច្បាស់លាស់ពោល គឺត្រូវសរសេរឈ្មោះភាគីជនសង្ស័យ ភេទ អាយុ មូលហេតុនៃបណ្ដឹង និងកម្មវត្ថុនៃការទាមទារ។ ក្រោយពីទទួលបន្ទុកបើកការស៊ើបអង្កេតជាបឋមលើករណីនេះ រហូតឈានដល់ការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់លើជនសង្ស័យ ពោលបើសិនជាតុលាការរកឃើញថាមានតម្រុយសន្មត់ពិរុទ្ធភាពដូចមានចែងក្នុងបណ្ដឹងមែននោះ តុលាការសម្រេចចោទប្រកាន់រួចបញ្ជូនទៅចៅក្រមស៊ើបសួរចាត់ការបន្តតាមនីតិវិធី។ នៅដំណាក់កាលនេះជនសង្ស័យបានក្លាយជាជនត្រូវចោទ។ ប្រសិនជាតុលាការរកឃើញថាជនសង្ស័យពុំមានតម្រុយសន្មត់ពិរុទ្ធភាព នោះតុលាការនឹងសម្រេចតម្កល់បណ្ដឹងទុកឥតចាត់ការ ហើយត្រូវធ្វើលិខិតជូនដំណឹងដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី។ ប៉ុន្តែភាគីដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះការសម្រេចទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។

ឧទាហរណ៍៖ បុរស **ក** បានខ្ចីប្រាក់ពី **ខ** ចំនួន ៥,០០០$ដោយគិតការប្រាក់ក្នុង០១ខែចំនួន២០០$និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំផងដែរក្រោយពីខ្ចីបានមួយរយៈបុគ្គល **ក** ក៏បានគេចវេសក្នុងការបង់ប្រាក់ទៅឱ្យបុគ្គល **ខ** បន្ទាប់មកបុគ្គល **ខ** ក៏បានដាក់ពាក្យបណ្ដឹងទៅកាន់អយ្យការអមសាលាដំបូងពេលតំណាងអយ្យការបានទទួលសំណុំរឿងតំណាងអយ្យការបានកោះហៅភាគីដើម្បីមកសាកសួរពីដំណើររឿងក្រោយពីសាកសួររួចមកតំណាងអយ្យការបានតម្កល់សំណុំរឿងទុកឥតចាត់ការដោយសារសំណុំរឿងដែលបុគ្គល **ខ** ប្ដឹង

មកនោះគឺជាវិវាទរដ្ឋប្បវេណីប៉ុន្តែបានប្ដឹងមកជាវិវាទរឿងក្ដីព្រហ្មទណ្ឌជាករណីឆបោកដែលធ្វើឱ្យបុគ្គល ខ ខូចខាតប្រយោជន៍ទាំងពេលវេលានិងទាំងការចំណាយទៅលើសេវាមេធាវីជាដើម។

## ២.២ ទប្បធម៌អន្តរាគមន៍ពីអ្នកមានអំណាច

យើងបានដឹងហើយថាតំណាងអយ្យការ គឺជាម្ចាស់នៃបណ្ដឹងអាជ្ញាដែលច្បាប់បានកំណត់នឹងឱ្យសិទ្ធិអំណាចក្នុងការការពារផលប្រយោជន៍សាធារណៈ។ ប៉ុន្តែដោយការអនុវត្តច្បាប់មួយចំនួនយើងឃើញមានការប្រឈមពាក់ព័ន្ធនឹងការអន្តរាគមន៍របស់អ្នកមានអំណាច នៅក្នុងដំណើរការនីតិវិធីរបស់តុលាការដែលជាហេតុនាំឱ្យមានការលំបាកក្នុងការអនុវត្តច្បាប់របស់មន្ត្រីអនុវត្តច្បាប់។ បញ្ហាប្រឈមរបស់តំណាងអយ្យការនៅក្នុងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការដោយមានការអន្តរាគមន៍របស់អ្នកមានអំណាចមានដូចជាៈ ជាតុផ្សំនៃបទល្មើសគ្រប់គ្រាន់តែតំណាងអយ្យការត្រូវធ្វើការតម្កល់រឿងទុកឥតចាត់ការ តាមរយៈការចង្អុលបង្ហាញរបស់អ្នកមានអំណាចណាមួយទៅដល់ជនណាម្នាក់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនឬក្រោមការគៀបសង្កត់ណាមួយ។ ប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកមានអំណាចទាំងអស់នេះទៀតសោត គឺកើតឡើងដោយការគុំគួន និងកំហឹងឬមានបំណងចង់ធ្វើបាបជនណាម្នាក់ដែលនិយាយប៉ះពាល់ ឬធ្វើអ្វីមួយដែលនាំឱ្យខាតបង់ប្រយោជន៍ផ្ទាល់ខ្លួន។ ត្រង់ចំណុចនេះធ្វើឱ្យព្រះរាជអាជ្ញាមានផលវិបាកហើយវាខុសពីបញ្ញត្តិ នៃច្បាប់ចែងនិងជាពិសេសនោះ គឺខុសពីសតិសម្បជញ្ញៈនិងវិជ្ជាជីវៈទៀតផង។ ជាតុផ្សំនៃបទល្មើសគ្រប់គ្រាន់តែតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការដោយហេតុថាមានការអន្តរាគមន៍ពីសំណាក់អ្នកមានអំណាចដែលនាំឱ្យមានការខូចប្រយោជន៍សាធារណៈ។ ជាក់ស្ដែងនៅក្នុងសង្គមរស់នៅសព្វថ្ងៃមនុស្សភាគច្រើន គឺស្រឡាញ់នូវអំណាចបុណ្យសក្តិ និងទ្រព្យសម្បត្តិរបស់ខ្លួននៅពេលដែលមានការប្រព្រឹត្តនៅទោសកំហុសអ្វីមួយដែលខុសពីច្បាប់និយាយរួម គឺប្រព្រឹត្តនូវបទល្មើសណាមួយដែលមានចែង នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺរមែងតែប្រើប្រាស់នូវអំណាចនិងទឹកប្រាក់របស់ខ្លួនមកធ្វើការគៀបសង្កត់លើឆន្ទានុសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា។

## ២.៣ ការសម្រេចសេចក្ដីដោយមិនទាន់មានការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយ

រឿងក្ដីព្រហ្មទណ្ឌមួយចំនួនមានរឿងរ៉ាវដែលពិបាកក្នុងការស្វែងរក និងសិក្សាភស្តុតាងដែលពេលខ្លះដើមបណ្ដឹងឬជនរងគ្រោះគាត់ពិបាកនៅក្នុងការបង្ហាញនៅភស្តុតាងដើម្បីទៅបញ្ជាក់ហើយខាងស្ថាប័នតុលាការគឺមិនបានស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយឡើយ គឺសម្រេចដោយខ្វះការស្វែងរកនូវភាពយុត្តិធម៌ជូនជនរងគ្រោះគឺលោកបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងនោះតែម្ដង ប៉ុន្តែព្រះរាជអាជ្ញាត្រូវប្រើប្រាស់នូវធនធានចំណេះដឹងរបស់ខ្លួនខិតខំបំពេញការងារនៅការអនុវត្តក្នុងរឿងក្ដីព្រហ្មទណ្ឌណាមួយ ដោយត្រូវត្រួតពិនិត្យទៅលើឯកសារ ឬភស្តុតាងនានាដែលពាក់ព័ន្ធនិងសំណុំរឿងក្ដីឱ្យបានលម្អិតនិងគ្រប់ជ្រុងជ្រោយជាមុនសិនមុន

នឹងព្រះរាជអាជ្ញាធ្វើការតម្កល់សំណុំរឿងទុកឥតចាត់ការដោយមិនត្រូវចេះតែតម្កល់តាមឆន្ទានុសិទ្ធិរបស់ខ្លួនទាំងដែលសំណុំរឿងមានបទល្មើសនោះទេ។

## ២.៤ ការសម្រេចសេចក្តីដោយលម្អៀង

ស្ថានភាពរឿងក្តីមួយចំនួនត្រូវបានសម្រេចឡើងដោយតាមតែឆន្ទានុសិទ្ធិរបស់តុលាការដោយគាត់បានយកនូវសិទ្ធិអំណាចរបស់ខ្លួនធ្វើការសម្រេចសេចក្តីដោយមិនគោរពតាមគោលការណ៍ច្បាប់ និងនីតិវិធីក្នុងការតម្កល់រឿងទុកឥតចាត់ការ ដោយគាត់បានលម្អៀងទៅភាគីណាមួយដោយលោកពឹងផ្អែកតែលើការយល់ឃើញរបស់លោកដោយមិនគោរព និងពិនិត្យមើលលើអង្គច្បាប់ និងអង្គហេតុព្រមទាំងឯកសារភស្តុតាងនានាដែលជនរងគ្រោះបានដាក់មកជូនគាត់ ដើម្បីពិនិត្យនិងវិភាគទៅលើឯកសារនោះឱ្យបានច្បាស់លាស់នោះទេ បែរជាគាត់សម្រេចតម្កល់រឿងទុកឥតចាត់ការតែម្តងទាំងដែលរឿងក្តីនោះអាចនឹងមានបទល្មើសជាដើម។

ឧទាហរណ៍៖ នៅថ្ងៃមួយបុគ្គល **ក** ម្នាក់បានបង្ហាញរូបភាពរបស់បុគ្គល **ខ** ទៅលើបណ្តាញសង្គមហ្វេសបុកដោយបានសរសេរខេបសិននៅលើគណនីហ្វេសបុកនោះដោយប្រើពាក្យមិនសមរម្យមួយចំនួនដូចជា ការដាក់ទំនាយទៅលើបុគ្គល **ខ** ការជេរប្រមាថការមាក់ងាយថាបុគ្គល **ខ** លួចមាននេះនោះជាដើមហើយទាំងដែលបុគ្គល **ខ** ពុំដែលស្គាល់បុគ្គល **ក** ពីមុនមកទេចំពោះការបង្ហោះនេះបុគ្គល **ខ** មានភស្តុតាងគ្រប់គ្រាន់ដើម្បីយកមកធ្វើការប្តឹងទៅលើបុគ្គល **ក** ពីបទបរិហាកេរ្តិ៍ជាសាធារណៈនិងបទជេរប្រមាថជាសាធារណៈ។ ប៉ុន្តែនៅពេលដែលសំណុំរឿងបានមកដល់ដៃរបស់ព្រះរាជអាជ្ញាហើយបុគ្គល **ក** និងព្រះរាជអាជ្ញាជាអ្នកស្គាល់គ្នាបន្ទាប់មកព្រះរាជអាជ្ញាបានកោះហៅបុគ្គលទាំងពីនាក់នោះមកសាកសួរ ពេលសាកសួររួចមកព្រះរាជអាជ្ញាបានសម្រេចធ្វើការតម្កល់សំណុំរឿងទុកឥតចាត់ការតែម្តងទាំងដែលសំណុំរឿងនោះគឺមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ដែលអាចធ្វើឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បុគ្គល **ក** បាន។

## ២.៥ មនុស្សក្នុងសង្គមអាចមើលស្រាលច្បាប់

ការតម្កល់រឿងទុកឥតចាត់ការ ជាហេតុនាំឱ្យមានអំពើតូចៗជាច្រើនដែលបង្កដល់សន្តិសុខសង្គមដោយបុគ្គលម្នាក់ៗលែងខ្លាចការផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌឡើយ។ ដើម្បីចូលរួមអនុវត្តឱ្យបានសកម្មនិងផ្តល់កិច្ចសហការឱ្យបានពេញលេញក្នុងការអនុវត្តយុទ្ធនាការសំខាន់ៗទាំង ៣ ដែលនឹងដាក់ចេញដោយក្រសួងយុត្តិធម៌នាពេលខាងមុខដោយត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតប្រកបដោយឆន្ទៈមោះមុតស្មារតីបុរេសកម្មនិងការទទួលខុសត្រូវខ្ពស់សំដៅលើកកម្ពស់យុត្តិធម៌សង្គម និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋលើវិស័យយុត្តិធម៌របស់កម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះនៅពេលដែលព្រះរាជអាជ្ញាគាត់បានសម្រេចតម្កល់សំណុំរឿងក្តីណាមួយដោយពុំបានពិនិត្យទៅលើភស្តុតាងឱ្យបានច្បាស់លាស់ ដូចជារឿងដែលមនុស្សក្នុងសង្គមអាចពឹងពាក់ទៅលើច្បាប់ថា អាចដោះស្រាយវិវាទនោះឱ្យបានប៉ុន្តែបែរជាព្រះរាជអាជ្ញាគាត់បានប្រើប្រាស់

នូវសិទ្ធិអំណាចឬឆន្ទានុសិទ្ធិរបស់គាត់ធ្វើការតម្កល់រឿងទុកឥតចាត់ការ ដែលកត្តាទាំងនោះហើយធ្វើឱ្យមនុស្សក្នុងសង្គមគាត់អាចនិងមើលស្រាលទៅលើច្បាប់ដែលមិនអាចដោះស្រាយឱ្យពួកគាត់បាន។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយប្រធានបទខាងលើរួចមក យើងសន្និដ្ឋានបានថា ការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គឺជានីតិវិធីមួយដែលមានលក្ខណៈទន់ភ្លន់ជាងគេហើយថែមទាំងមានសារៈសំខាន់ផងដែរ។ ការតម្កល់រឿងទុកឥតចាត់ការ គឺស្ថិតនៅក្នុងដំណាក់កាលចោទប្រកាន់ដោយអង្គការអយ្យការចំពោះបទល្មើសព្រហ្មទណ្ឌ។ ហេតុនេះអង្គការអយ្យការគឺជាតួអង្គតែមួយប៉ុណ្ណោះដែលមានសិទ្ធិពេញលេញក្នុងការតម្កល់រឿងក្តីព្រហ្មទណ្ឌ។ កាលណាអយ្យការមានសិទ្ធិធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនោះ គឺមានសច្ចភាព ហើយក៏សមស្របទៅតាមបទប្បញ្ញត្តិដែលច្បាប់បានកំណត់។ យោងតាមមាត្រា៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការដោយបានចែងថា ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ បន្ទាប់ពីបានធ្វើការស្រាវជ្រាវ វិភាគវែកញែក និងធ្វើការបកស្រាយជុំវិញប្រធានបទខាងលើរួចមក សបញ្ជាក់ឱ្យឃើញថាការបង្កើតឱ្យមាននូវបទប្បញ្ញត្តិនេះឡើង គឺដើម្បីបង្ការការកកស្ទះសំណុំរឿង កាត់បន្ថយការចំណាយថវិការបស់រដ្ឋសមរម្យមួយសម្រាប់ការកសាងសង្គមជាតិ។ លើសពីនេះទៅទៀតប្រធានបទនេះ ពិតជាបានឆ្លុះបញ្ចាំងយ៉ាងលម្អិតអំពីតួនាទីនៃស្ថាប័នអយ្យការជាពិសេសគឺព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអមសាលឧទ្ធរណ៍ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់សិទ្ធិអំណាចជូន តួយ៉ាងក្រសួងយុត្តិធម៌ក៏មានវត្តមានក្នុងការធ្វើអធិបញ្ញាផងដែរ ក្នុងដំណើរការតម្កល់រឿងទុកឥតចាត់ការ។

ក្រោយពីការចេញដីកាតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានចំណុចវិជ្ជមានជាច្រើនគួរឱ្យកត់សម្គាល់ដូចជា៖ ការអនុវត្តជាក់ស្តែង គឺតំណាងអយ្យការបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីតួនាទីរបស់ខ្លួន។ ជាពិសេសមុននិងឈានទៅដល់ការចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការបានពិចារណាយ៉ាងល្អិតល្អន់ និងធ្វើការស្រាវជ្រាវយ៉ាងសកម្មតាមរយៈការកោះហៅភាគីដែលពាក់ព័ន្ធមកធ្វើការសាកសួរ និងព្យាយាមអនុវត្តតួនាទី ដើម្បីឱ្យភាគីមានជំនឿទុកចិត្តលើស្ថាប័នតុលាការ ក៏ដូចជាការចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការពិតជាបានធ្វើតាមនីតិវិធីដោយមានការកោះហៅធ្វើការសាកសួរ និងស៊ើបអង្កេត ដើម្បីបញ្ជាក់ថាមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព មិនតែប៉ុណ្ណោះរាល់ការចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ មានសំអាងហេតុ និងសំអាងច្បាប់ច្បាស់លាស់ត្រឹមត្រូវតាមការយល់ឃើញ និងឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាតាមស្មារតីច្បាប់ដែលបានកំណត់ពីមូលហេតុច្បាស់លាស់។ ហេតុនេះប្រសិនបើបទល្មើសខ្លះមិនមានច្បាប់ចែង តែបង្កនូវព្យសនកម្មធ្ងន់ធ្ងរដល់សង្គមនោះសិទ្ធិអំណាចរបស់តុលាការជាអ្នកសម្រេចលើករណីនេះ។ ដូច្នេះហើយកាលណាបើអវត្តមាននៃបទល្មើសសំដៅដល់សំណុំរឿង

ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ចំពោះសំណុំរឿងដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ សំដៅលើកំហុសរដ្ឋប្បវេណីជាដើម កង្វះធាតុផ្សំបទល្មើស និងសំណុំរឿងដែលតំណាងអយ្យការមិនអាចធ្វើចំណាត់ការបាន។

សរុបសេចក្តីមក អង្គការអយ្យការ គឺបានដើរតួនាទីយ៉ាងសំខាន់ដែលមិនអាចខ្វះបានក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌនៅស្ថាប័នតុលាការ។ ជាពិសេសនីតិវិធីក្នុងការតម្កល់រឿងទុកឥតចាត់ការនេះ បើគ្មានកិច្ចអន្តរាគមន៍ ក៏ដូចជាការចូលរួមនានាទៅតាមតួនាទីពីសំណាក់អង្គការអយ្យការ តាមការកំណត់របស់ច្បាប់នោះម្លោះហើយដំណើរការរីកចម្រើននៃវិស័យច្បាប់កម្ពុជាយើង ក៏មិនអាចដើរទៅមុខដោយរលូនបានឡើយ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះតាំងពីដើមរហូតមកដល់ចំណុចបញ្ចប់បានកត់សម្គាល់ឃើញថាអង្គការអយ្យការពិតជាតួអង្គមួយដ៏មានសារៈសំខាន់ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ យើងខ្ញុំសូមលើកយកអនុសាសន៍មួយចំនួនដូចខាងក្រោម៖

សិស្សនិស្សិតដែលសិក្សាផ្នែកច្បាប់ និងមន្ត្រីដែលអនុវត្តច្បាប់ទាំងឡាយត្រូវបន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយស្តីអំពីក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែស៊ីជម្រៅ ជាពិសេសត្រូវមានការលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យមានការសហការណ៍ និងចូលរួមឱ្យបានច្រើន ក៏ដូចជាការផ្តល់នូវការពិតចំពោះអ្វីដែលពួកគាត់បានឃើញដឹង និងព្វាក់ព័ន្ធនឹងការពិតនៃសំណុំរឿង

- ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវរាល់កិច្ចចោទប្រកាន់ និងគោរពបទប្បញ្ញត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួនក្នុងនាមជាអ្នកស្វែងរកយុត្តិធម៌។
- ត្រូវផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋស្របតាមអភិក្រមបួនរួមមាន លឿនរហ័ស ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ។
- តំណាងអយ្យការត្រូវជៀសវាងឱ្យបាននូវអគតិធម៌ទាំងបួនរួមមាន៖ ឆន្ទាគតិ (លម្អៀងព្រោះសេចក្តីស្រលាញ់) ទោសាគតិ(លម្អៀងព្រោះស្អប់) ភយាគតិ (លម្អៀងព្រោះខ្លាច) និងមោហាគតិ (លម្អៀងព្រោះល្ងង់ខ្លៅអវិជ្ជា)។
- បង្កើនធនធានព្រះរាជអាជ្ញាបន្ថែមឱ្យបានសមល្មមទៅតាមតម្រូវការរឿងក្តី ដូចដែលអ្នកបានដឹងរួចមកហើយ ព្រះរាជអាជ្ញាគឺជាតួអង្គដ៏ចាំបាច់បំផុតក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដូចនេះការបង្កើតធនធានព្រះរាជអាជ្ញាជាការចាំបាច់បំផុត។ កាលណាព្រះរាជអាជ្ញាមានចំនួនតិចពេក ធ្វើឱ្យព្រះរាជអាជ្ញាទទួលបន្ទុកសំណុំរឿងមានចំនួនច្រើនវានាំឱ្យការសម្រេចចិត្តមិនមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ហើយជួនកាលអាចមានការសម្រេចចិត្តមិនប្រក្រតី ឬមានការភ័ន្តច្រឡំណាមួយផងក៏អាចថាបានដែរ។
- ការបណ្តុះបណ្តាលព្រះរាជអាជ្ញា គឺជាការឆ្លើយតបទៅនឹងសមត្ថភាពក្នុងការវិនិច្ឆ័យក្តីរបស់ព្រះរាជអាជ្ញា។ វាមិនមានចម្លែកឡើយចំពោះការបណ្តុះបណ្តាល ព្រោះថាមិនមានអ្វីដែលមានការចាំបាច់ និងល្អប្រសើរជាងការបណ្តុះបណ្តាលឡើយ។ កាលណាព្រះរាជអាជ្ញាមានការបណ្តុះបណ្តាលបានត្រឹមត្រូវនោះរាល់ការសម្រេចសេចក្តីរបស់គាត់ ក៏មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ដូចគ្នា។ ដោយឡែកការបណ្តុះបណ្តាលនេះដែរ មិនមែនជាការបណ្តុះបណ្តាលត្រឹមតែនីតិវិធី និងផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែគួរតែពង្រឹងលើការបណ្តុះបណ្តាលផ្នែកច្បាប់នៃស្ថាប័នតុលាការឱ្យបានកាន់តែប្រសើរឡើង។

- នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការត្រូវតែកំណត់ឱ្យបានច្បាស់លាស់ជៀសវាងមានការបកស្រាយផ្ទុយពីស្មារតីច្បាប់ ហើយមូលហេតុដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ ក៏ដូចគ្នាផងដែរគួរតែមានការកំណត់ឱ្យបានច្បាស់លាស់។ ដោយសារតែមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ គួរតែអនុវត្តឱ្យសមស្របទៅនិងមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ការធ្វើអធិបញ្ញាបង្គាប់ឱ្យចោទប្រកាន់ដើម្បីធានាបានពីការហានិភ័យដែលបណ្ដាលមកពីការសម្រេចតម្កល់រឿងទុកឥតចាត់ការក៏ពិតមែន ប៉ុន្តែរាល់ការធ្វើអធិបញ្ញាទៀតសោត ក៏ត្រូវតែមានការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវទាំងអង្គហេតុ និងអង្គច្បាប់ផងដែរ ព្រោះការសម្រេចធ្វើអធិបញ្ញាឱ្យចោទប្រកាន់នាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលដែលត្រូវបានចោទប្រកាន់។
- ការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ គឺរក្សាបាននូវឯករាជ្យភាពនៃអំណាចតុលាការជៀសវាងការមិនមានទំនុកចិត្តពីប្រជាពលរដ្ឋ ឬពីមជ្ឈដ្ឋានជុំវិញដែលជាហេតុនាំឱ្យមានភាពអយុត្តិធម៌។
- ត្រូវមានការសហការពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធនានាដើម្បីជាជំនួយដល់ស្ថាប័នតុលាការក្នុងការអនុវត្តនីតិវិធីឱ្យបានឆាប់រហ័ស។ ការសហការនេះជាជំនួយដ៏សំខាន់មួយដែលអាចធ្វើឱ្យដំណើរការក្នុងរឿងក្តីបានទទួលនូវយុត្តិធម៌ និងមិនធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់គូរភាគី។

យើងសង្កេតឃើញផងដែលថា ការតម្កល់រឿងទុកឥតចាត់ការគឺពិតជាបានជះឥទ្ធិពលដល់ការរីកចម្រើនរបស់សង្គមតាមរយៈគោលការណ៍ប្រៀនប្រដៅបែបអប់រំ។មួយវិញទៀតព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការដោយស្របតាមទម្រង់ដែលណែនាំដោយក្រសួងយុត្តិធម៌និងវិធានទ្រឹស្តីពាក់ព័ន្ធពោលគឺមិនមានបទប្បញ្ញត្តិណាចែងជាក់លាក់នៅក្នុងបទដ្ឋានគតិយុត្តឡើយ។យ៉ាងណាមិញចំពោះមធ្យោបាយនៃកិច្ចចោទប្រកាន់របស់តំណាងអយ្យការវិញគឺមានបទប្បញ្ញត្តិជាក់លាក់កំណត់យ៉ាងច្បាស់និងលម្អិតហើយតំណាងអយ្យការអាចពិនិត្យថ្លឹងថ្លែងនិងពិចារណាថាតើគប្បីប្រើប្រាស់មធ្យោបាយណាមួយដើម្បីសាកសមនឹងសំណុំរឿងជាក់ស្តែង។

យើងបានមើលឃើញយ៉ាងច្បាស់ពីភាពអសកម្មមួយចំនួនតូចដែលមាននៅក្នុងគុណវិបត្តិការតម្កល់រឿងទុកឥតចាត់ការដែលទាំងអស់នេះសុទ្ធសឹងតែជាផ្នែកមួយដែលធ្វើឱ្យវិស័យយុត្តិធម៌ឬស្ថាប័នតុលាការមានការបាត់បង់នៅទំនុកចិត្តពីប្រជាពលរដ្ឋដែលគាត់បានសម្រេចចិត្តក្នុងការប្តឹងទៅកាន់តុលាការដើម្បីស្វែងរកនៅភាពយុត្តិធម៌ប៉ុន្តែត្រូវបានគាត់អស់ជំនឿនិងអស់សេចក្តីទុកចិត្តដែលទាំងអស់នេះគប្បីតុលាការគ្រប់ជាន់ថ្នាក់គប្បីមានការកែតម្រូវការអនុវត្តឡើងវិញនៅគោលការណ៍ដែលមានកំណត់ក្នុងច្បាប់ដោយមិនមានភាពលម្អៀងភាពបន្តទៅមុខទៀតនោះទេដើម្បីជាប្រយោជន៍របស់សង្គមជាតិទាំងមូល។

# ឯកសារយោង

# ឯកសារយោង

## ១). លិខិតបទដ្ឋានគតិយុត្តិជាតិ

### ក). រដ្ឋធម្មនុញ្ញ

១). រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

### ខ). សន្ធិសញ្ញាអន្តរជាតិ

១). គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិ លើកទី៧ ចាប់ពីថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា។

២). គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា ,អនុម័តដោយសមាជអង្គការសហប្រជាជាតិ លើកទី៨ នាទីក្រុងហាវ៉ាណា ប្រទេសគុយបា ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ ,ចំណុចទី១៣ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស។

### គ). ក្រម

១). ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២). ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

### ឃ). ច្បាប់

១).ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ។

២).ព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

៣).ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីឯកពន្ធភាព។

៤).ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

៥).ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។

៦).ព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ប្រកាសឱ្យប្រើ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៧).ព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ប្រកាសឱ្យប្រើ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

**ខ). បទបញ្ញា**

១). ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ស្ដីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់។

២). ព្រះរាជក្រឹត្យលេខ នស/រកត/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យដំណើរការសាលាដំបូងឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

៣). ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

៤). ព្រះរាជក្រឹត្យលេខ នរ/រកត/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។

៥).ព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។

## ២). ឯកសារជាសៀវភៅ និងអត្ថបទ

**ក). សៀវភៅមេរៀន**

១). លោក **កុយ នាម** និងលោក **ឡុង បញ្ញាវុឌ្ឍ**, អង្គការអយ្យការ (ប្រវត្តិនិងការសិក្សាប្រៀបធៀប), ភ្នំពេញ បោះពុម្ពលើកទី១, ឆ្នាំ២០០៦។

២).រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, មេរៀននីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០០៧។

**ខ). ឯកសារជាអត្ថបទ**

១). សេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌លេខៈ០៣ កយ.សណន/២១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ស្ដីពីគោលការណ៍ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលអយ្យការ,ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដើម្បីពន្លឿនចំណាត់ការនីតិវិធីក្នុងសំណុំរឿង និងដើម្បីរួមចំណែកដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ https://www.facebook.com/mojcambodia/posts/% ។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | ពាក្យបណ្ដឹងផ្ទាល់នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០២ | ដីកាកោះដើមបណ្ដឹងនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៣ | ដីកាកោះជនសង្ស័យនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៤ | កំណត់ហេតុសួរចម្លើយនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៥ | ដីកាតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៦ | លិខិតជូនដំណឹងទៅភាគីដើមបណ្ដឹងស្ដីពីការតម្កល់រឿងទុកឥតចាត់ការនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៧ | ពាក្យបណ្ដឹងឧទ្ធរណ៍នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៨ | សេចក្ដីចម្លងពាក្យបណ្ដឹងតវ៉ានៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ០៩ | បញ្ជីរាយមុខលិខិតនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១០ | សារណាបណ្ដឹងឧទ្ធរណ៍នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១១ | ដីកាកោះនៅមហាអយ្យការអមសាលាឧទ្ធរណ៍អមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១២ | កំណត់ហេតុចម្លើយនៅមហាអយ្យការអមសាលាឧទ្ធរណ៍អមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១៣ | ដីកាតម្កល់រឿងទុកឥតចាត់ការនៅមហាអយ្យការអមសាលាឧទ្ធរណ៍អមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១៤ | លិខិតជូនដំណឹងទៅភាគីដើមបណ្ដឹងស្ដីពីការតម្កល់រឿងទុកឥតចាត់ការនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១៥ | ដីកាបញ្ជូនសំណុំរឿងតម្កល់ទុកឥតចាត់ការនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១៦ | អំណាចនៃអធិបញ្ញានៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ |
| ១៧ | អំណាចនៃអធិបញ្ញារបស់ក្រសួងយុត្តិធម៌ |
| ១៨ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ១៩ | ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |

ឧបសម្ព័ន្ធទី១

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
លេខ..........
ថ្ងៃទី ០២ ខែ ០៥ ឆ្នាំ២០២៤
ម៉ោង ១០ : ៣២ នាទី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

នាងខ្ញុំឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ មុខរបរលក់ដូរ មានទីលំនៅផ្ទះ ផ្លូវ១៦ ភូមិត្រពាំងថ្លឹង៤ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ លេខទូរស័ព្ទ

**សូមគោរពចូលមក**

**ឯកឧត្តមព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

**កម្មវត្ថុ**: សំណើសុំប្តឹងឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ មុខរបរលក់ដូរ មានទីលំនៅ ផ្លូវបេតុង ភូមិចោមចៅ២ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពីបទ រំលោភលើទំនុកចិត្ត (យកប្រាក់ចំនួន២,២៣០០ដុល្លារអាមេរិក)។

យោងតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជំរាបជូន **ឯកឧត្តម** មេត្តាជ្រាបថា: នាងខ្ញុំនិងឈ្មោះ ភេទស្រី អាយុ៣៩ឆ្នាំ ជាអ្នកស្គាល់គ្នា ហើយក៏បានមកពឹងពាក់ខ្ញុំ ដោយបានអោយខ្ញុំជួយលុយគាត់ចំនួន២២៣០០ដុល្លារ(ពីរម៉ឺនពីរពាន់បីរយដុល្លារអារិក) ដើម្បីយកទៅទិញផ្ទះ នៅផ្ទះ ផ្លូវបេតុង ភូមិចោមចៅ២ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយសន្យាថា ពេលទិញផ្ទះបាន និងប្រគល់លុយអោយគ្រប់ចំនួនវិញ ដោយខ្ញុំគិតថា ជាអ្នកស្គាល់គ្នា ទើបនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ខ្ញុំប្រគល់លុយចំនួន២២៣០០ដុល្លារ (ពីរម៉ឺនពីរពាន់បីរយដុល្លារអារិក) នៅចំណុចផ្ទះលេ ផ្លូវ១៦ ភូមិត្រពាំងថ្លឹង៤ សង្កាត់ចោម ចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ អោយឈ្មោះ លុះពេលគាត់បានលុយ គ្រប់ចំនួននិងទិញផ្ទះខាងលើបាន។ ខ្ញុំក៏បានទូរស័ព្ទទៅគាត់ ដើម្បីអោយគាត់ប្រគល់លុយមកអោយខ្ញុំវិញ ពេលខ្ញុំទូរស័ព្ទម្តងៗគាត់ប្រាប់ថា ចាំថ្ងៃនេះ ថ្ងៃនោះ ដោយគាត់និយាយដោះសាររហូត ទើបខ្ញុំ មកដាក់ពាក្យបណ្តឹងនៅសាលាដំបូងរាជធានីភ្នំពេញតែម្តង។

**សំណូមពរ**: ទាមទារសំណងទាំងប្រាក់ដើមនិងជម្ងឺចិត្តចំនួន៥០០០០ដុល្លារអាមេរិក។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម** មេត្តាទទួលពាក្យរបស់នាងខ្ញុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំរោង ឆស័កព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤

**ស្នាមម្រាមមេដៃអ្នកប្តឹង**

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤

**ដីកាកោះ**

**យើង ៖ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ ៖ ភេទស្រី កើតឆ្នាំ១៩៨៩ ជាដើមបណ្តឹង
អាសយដ្ឋាន ៖ ផ្ទះលេខ ផ្លូវបេតុង ភូមិតាងៅកណ្តាល សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ ៖
ឱ្យចូលទៅកាន់ ៖ **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បន្ទប់**
**ស្ថិតនៅអគារសាលាយុត្តិធម្ម ដីឡូត៍លេខ B តំបន់អភិវឌ្ឍន៍ OCIC ផ្លូវលោកតាក្រហម ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ**
នៅថ្ងៃទី ៖ ១៨ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ៩និង ០០ នាទី ព្រឹក
ដើម្បី ៖ **ឆ្លើយបំភ្លឺតាមពាក្យបណ្តឹងរបស់ខ្លួនដែលបានប្តឹងឈ្មោះ**
ពីដំណើររឿង ៖ **រំលោភលើទំនុកចិត្ត, បទលួច , បទបរិហារបង្កាច់កេរ្តិ៍ និងបទសមគំនិតក្នុងអំពើលួច**

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤
**តំណាងអយ្យការ**

យើង..........................................................
បានប្រគល់ដីកាកោះនេះ ចំនួន ០១ច្បាប់ ឱ្យទៅ
ឈ្មោះ..........................................................
នៅថ្ងៃទី....................ខែ................ឆ្នាំ..................

**អ្នកប្រគល់** **អ្នកទទួល**

ស្កេន QR Code ដើម្បីស្វែងរកទីតាំងថ្មីនៃ «អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ»។

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤

## ដីកាកោះ

**យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

| | | |
|---|---|---|
| អញ្ជើញឈ្មោះ | ៖ | ភេទស្រី អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ជាជនសង្ស័យ |
| អាសយដ្ឋាន | ៖ | ផ្លូវលំ ភូមិសន្តិភាព១ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ |
| ឱ្យចូលទៅកាន់ | ៖ | **ស្ថិតនៅអគារសាលាយុត្តិធម្ម ដីឡូត៍លេខ** B **តំបន់អភិវឌ្ឍន៍** OCIC **ផ្លូវលោកតាក្រហម ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ** |
| នៅថ្ងៃទី | ៖ | ២៤ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង៩ និង ០០ នាទី ព្រឹក |
| ដើម្បី | ៖ | **ឆ្លើយបំភ្លឺតាមពាក្យបណ្តឹងរបស់ឈ្មោះ** |
| ពីដំណើររឿង | ៖ | **រំលោភលើទំនុកចិត្ត, បទលួច និងបទបរិហារបង្កាច់កេរ្តិ៍** |

ត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើបិនបើមាន ។

ថ្ងៃសុក្រ ១៤កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤
**តំណាងអយ្យការ**

យើង.............................................
បានប្រគល់ដីកាកោះនេះ ចំនួន ០១ច្បាប់ ឱ្យទៅ
ឈ្មោះ.............................................
នៅថ្ងៃទី...................ខែ.................ឆ្នាំ.................

**អ្នកប្រគល់** **អ្នកទទួល**

ស្កេន QR Code ដើម្បីស្វែងរកទីតាំងថ្មីនៃ «អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ»

**ឧបសម្ព័ន្ធទី៤**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ:
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤

## កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ម្ភៃបួន ខែឧសភា ថ្ងៃទីដប់ វេលាម៉ោងប្រាំបួន និងសូន្យនាទីព្រឹក នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយមានលោក ជាក្រឡាបញ្ជីអម បានសួរ និងកត់យកចម្លើយរបស់ជនសង្ស័យឈ្មោះ ដោយមានលោកមេធាវី អមដូចខាងក្រោមនេះ។

**សួរ-ឆ្លើយ:** ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទូរស័ព្ទលេខ៖ មុខរបរ: លក់ដូរ ទីកន្លែងកំណើត ស្រុកស្អាង ខេត្តកណ្តាល អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ សង្កាត់ច្បាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូនចំនួន ៤នាក់ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ ស្លាប់" ជានីតិជន ទោសពីមុន៖ គ្មាន ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសូមរក្សាអត្ថន័យនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ របស់ តំណាងដោយឈ្មោះ G ភេទប្រុស ជនជាតិចិន ដែលបានអានឱ្យខ្ញុំបាទស្តាប់ ខ្ញុំបាទសុំរក្សាទុកទាំងស្រុង ដោយគ្មានអ្វីកែប្រែឡើយ ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសុំរក្សាចម្លើយនៅនគរបាល ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ដែលបានអានឱ្យខ្ញុំបាទស្តាប់ទាំងស្រុងដោយគ្មានអ្វីកែប្រែឡើយ ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសុំបញ្ជាក់បន្ថែមថា កាលពីអំឡុងឆ្នាំ២០២០ ខ្ញុំបានរកស៊ីជាមួយនិងក្រុមហ៊ុនរយៈពេល ០៤ឆ្នាំ មកហើយ ដោយមានការបង្វិលប្រាក់និងអីវ៉ាន់ ទៅវិញទៅមករហូតនៅក្នុងការរកស៊ីនេះ លុះដល់អំឡុងខែមិថុនា ឆ្នាំ២០២៣ ក្រុមហ៊ុនបានបិទស្តុកអីវ៉ាន់ ឈប់ឱ្យខ្ញុំបាទយកទៅលក់បន្ត ពេលនោះខ្ញុំបាទបាននៅខ្វះប្រាក់ក្រុមហ៊ុនចំនួន ៥៩,៥០០$ (ប្រាំម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) បន្ទាប់មកខ្ញុំបាទបានសងប្រាក់ទៅក្រុមហ៊ុនចំនួន ៥,០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ហើយ នៅខ្វះចំនួន ៥៤,៥០០$ (ប្រាំម៉ឺនបួនពាន់ប្រាំរយដុល្លារអាមេរិក) ខ្ញុំបាទបានគិតថា ក្រុមហ៊ុននិងបើកស្តុកអីវ៉ាន់ឱ្យខ្ញុំបាទយកលក់បន្តវិញ ប៉ុន្តែពេលដែលខ្ញុំសងប្រាក់ក្រុមហ៊ុនហើយ បែរជាក្រុមហ៊ុនមិនបានបើកស្តុកឱ្យខ្ញុំបាទយកអីវ៉ាន់ទៅលក់ដើម្បីបង្វិលប្រាក់សងទៅក្រុមហ៊ុនដូចសព្វដងឡើយ ។

**សួរ-ឆ្លើយ:** ដោយពេលនោះខ្ញុំបាទក៏បានធ្វើកិច្ចសន្យាសុំសងប្រាក់ទៅក្រុមហ៊ុនក្នុង ០១ខែចំនួន ១,១៣៥$ (មួយពាន់មួយរយសាមសិបប្រាំដុល្លារអាមេរិក) ប៉ុន្តែក្រុមហ៊ុនមិនបានដាក់ស្តុកអីវ៉ាន់ឱ្យខ្ញុំបាទ

បានយកទៅលក់វិញ ខ្ញុំបាទក៏បានស្នះប្រាក់ពុំទាន់បានសងទៅក្រុមហ៊ុនវិញឡើយ ប៉ុន្តែខ្ញុំបាទពុំបានគេចវេសថាមិនព្រមសងនោះទេ មូលហេតុដោយសារខ្ញុំបាទត្រូវរ៉ាប់រងទៅលើគ្រួសារផង ដូច្នេះបានជាយឺតយ៉ាវក្នុងការសង ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសូមបញ្ជាក់បន្ថែមថា នៅពេលដែលខ្ញុំបាទរកស៊ីជាមួយក្រុមហ៊ុន គឺខ្ញុំបាទបានរកម៉ូយទៅឱ្យក្រុមហ៊ុនបានជាច្រើនក្នុងរយៈពេល ០៤ឆ្នាំនោះ បន្ទាប់ពីខ្ញុំបានរកស៊ី និង រកម៉ូយឱ្យក្រុមបានច្រើនហើយ បែរជាក្រុមហ៊ុនបានបិតស្តុកឈប់ឱ្យអីវ៉ាន់ខ្ញុំបាទយកលក់បន្ត ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសូមបញ្ជាក់ពីដើមហេតុបន្តិចមកថា កន្លងមកខ្ញុំបាទបានរកស៊ីជាមួយក្រុមហ៊ុនដោយពេលខ្លះ ខ្ញុំបាទបានយកអីវ៉ាន់ពីក្រុមហ៊ុនទៅលក់ មានពេលខ្លះបានបង្វិលប្រាក់មកក្រុមហ៊ុនមិនទាន់ក៏ខ្វះបន្តិចបន្តួច ដែលសរុប០៤ឆ្នាំមកនេះខ្ញុំបាទនៅខ្វះក្រុមហ៊ុនចំនួន ៥៩,៥០០$ (ប្រាំម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) មិនមែនខ្ញុំបាទជំពាក់ក្រុមហ៊ុននៅខែមិថុនា ឆ្នាំ២០២៣ ម្តងចំនួន ៥៩,៥០០$ (ប្រាំម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) នោះទេ ។

**សួរ-ឆ្លើយ:** មូលហេតុខ្ញុំបាទនៅខ្វះប្រាក់ក្រុមហ៊ុនខ្លះ ដោយសារពេលខ្ញុំបាទយកអីវ៉ាន់ទៅលក់មានអតិថិជនខ្លះគាត់មិនបានសងប្រាក់មកខ្ញុំបាទវិញ ។

**សួរ-ឆ្លើយ:** ខ្ញុំបាទសូមសំណូមពរ សុំសងប្រាក់ទៅក្រុមហ៊ុនក្នុងមួយខែចំនួន ៣០០$ (បីរយដុល្លារអាមេរិក) និងសុំឱ្យលោក **តំណាងអយ្យការ** មេត្តាតម្កល់រឿងនេះទុកឥតចាតការ ។

ឈប់សួរ បានអានឱ្យស្តាប់ សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង។

**អ្នកឆ្លើយ** **មេធាវី** **ក្រឡាបញ្ជី** **តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖
ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤
លេខ៖....

## ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ រ ភេទប្រុស កើតឆ្នាំ១៩៥៥ ជនជាតិខ្មែរ ដែលបានវាយត្រាចូលអយ្យការអមសាលាដំបូងរាជធានីភ្នំពេញលេខ ៖ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា ៖**

១. អវត្តមានបទល្មើស
- ☐ ១.១. អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់
- ☑ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត
- ☐ ៣.១. ការដកពាក្យបណ្តឹង
- ☐ ៣.២. ការលើកលែងទោសជាទូទៅ
- ☐ ៣.៣. មរណភាពជនល្មើស
- ☐ ៣.៤. ផុតអាជ្ញាយុកាល
- ☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- ☐ ៣.៦. អាជ្ញាអស់ជំនុំ
- ☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ
- ☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល
- ☐ ៣.៩. អភ័យឯកសិទ្ធិ
- ☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤. ការចោទប្រកាន់មិនផ្ដល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ៤.២.ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]

☐ ៤.៣. ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤.៤. ការខកខានរបស់ដើមបណ្ដឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ទានកម្ម[4]

☐ ៥.៣. អធិបញ្ញាផ្ដល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬនៃវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត**

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧. ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨. ជំនួយការអប់រំ**

☐ ៨.១. ការផ្ដល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ឃើញថា ៖**

កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានទទួលចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ ដែលខ្លឹមសារក្នុងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៥៥ ជនជាតិខ្មែរ បានប្ដឹងឈ្មោះ ភេទស្រី កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ ពីបទ ឆបោក ដោយបានអះអាងក្នុងពាក្យបណ្ដឹង

---

[1] ផ្លូវជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ដើមបណ្ដឹងឈប់ប្ដឹង

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[4] ករណីខែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមាន ឱ្យឈប់ប្រព្រឹត្ត

ថា ៖ កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ឈ្មោះ បានលក់រថយន្តចំនួន ០១គ្រឿង មកឱ្យខ្លួន ដែលមានម៉ាក LEXUS RX៣00 ពណ៌ខ្មៅ ផលិតឆ្នាំ២000 ពាក់ស្លាកលេខ ក្នុងតម្លៃ ១0,000USD (មួយម៉ឺនដុល្លារអាមេរិក) តាមរយៈលិខិតលក់រថយន្តចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ហើយនៅថ្ងៃនោះខ្លួនបានកក់ប្រាក់ថ្លៃទិញរថយន្តទៅឱ្យឈ្មោះ ចំនួន ៥,000USD (ប្រាំពាន់ដុល្លារអាមេរិក) ។ បន្ទាប់ពីបានព្រមព្រៀងក្នុងការទិញលក់រថយន្តខាងលើ និងទទួលប្រាក់កក់ពីខ្លួនរួចមក ឈ្មោះ បានប្រើឧបាយកលទុច្ចរិត ឆបោកខ្លួនថា រូបគេយករថយន្តខាងលើទៅរៀបចំឱ្យរូបខ្លួនឱ្យបានស្អាត ទើបយករថយន្តនោះមកប្រគល់ឱ្យខ្លួន តែខ្លួនរង់ចាំឈ្មោះ យូពេក ខ្លួនក៏ទំនាក់ទំនងទៅឈ្មោះនេះដើម្បីសួរនាំ ប៉ុន្តែទំនាក់ទំនងមិនបាននោះទេ ទើបខ្លួនដឹងថាចាញ់បោកឈ្មោះ ។

## បានឃើញ

- **ពាក្យបណ្តឹង** ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ
- **លិខិតលក់រថយន្ត** ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៩ រវាងឈ្មោះ និងឈ្មោះ ។
- លិខិតឯកសារផ្សេងៗ ដែលមានក្នុងសំណុំរឿង ។

## យល់ឃើញថា៖

- ក្រោយពីបានពិនិត្យសំណុំរឿង និងឯកសារផ្សេងៗរួចមកឃើញថា៖ ករណីខាងលើកើតចេញពីកិច្ចសន្យាទិញលក់រថយន្ត រវាងឈ្មោះ ជាអ្នកលក់ និងឈ្មោះ ជាអ្នកទិញ ដែលជារឿងរដ្ឋប្បវេណីសុទ្ធសាធ ដូច្នេះគប្បីតម្កល់រឿងទុកឥតចាត់ការតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- **ធាតុផ្សំបទល្មើសពុំគ្រប់គ្រាន់** ពីបទ ឆបោក លើឈ្មោះ ភេទស្រី កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ ។

## ហេតុដូច្នេះសម្រេច

តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៈថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកឥតចាត់ការ ចាប់ពីថ្ងៃនេះតទៅ ។

ថ្ងៃច័ន្ទ..៩..រោច....... ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០២៤

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខ:

## ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង ៖ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

-បានឃើញ៖ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា :

១ . អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ជាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្ដឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☑ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្រុះសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្រុះសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការទទួលខុសត្រូវ

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ដើមបណ្ដឹងឈប់ប្ដឹង

៤.៤. ☐ ការខកខានរបស់ដើមបណ្តឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[3]

៤.៨. ☐ ព្យសនកម្ម ឬ ការខាតតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការផ្សះផ្សាលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[4]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសណើររបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរលើកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួយការចោទប្រកាន់

**ការសង្ខេបផ្សេងៗឃើញថា៖**

កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង១៧ និង៥៥នាទី ត្រង់ចំណុចមុខ លើផ្លូវជាតិលេខ៦ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មានករណីគ្រោះថ្នាក់ចរាចរណ៍ មួយកើតឡើងរវាងម៉ូតូម៉ាក SUZUKI VIVA ពណ៌ខ្មៅ ពាក់ស្លាកលេខ បើកបរដោយឈ្មោះ ភេទប្រុស អាយុ៥៦ឆ្នាំ បានធ្វើដំណើរចេញពី ទិសដៅពីលិចទៅកើត លុះដល់ចំណុចកើតហេតុខាងលើ បានបើកឆ្លងផ្លូវជាតិលេខ៦កងល្បឿនលឿន ដោយមិនបានស៊ីញ៉ូប្រាប់ជាសញ្ញាសម្គាល់ ក៏បុកជាមួយរថយន្តមួយគ្រឿងដែលធ្វេដណេរតាមបណ្តាលផ្លូវជាតិលេខ៦ ទិសដៅពីត្បូងទៅជើង ម៉ាកLEXUS RX300 ពណ៌ទឹកមាន ពាក់ស្លាកលេខ បើកបរដោយឈ្មោះ ភេទប្រុសអាយុ ៣២ឆ្នាំ បណ្តាលឱ្យឈ្មោះ ស្លាប់បាត់បង់ជីវិតតែម្តង ។

**បានឃើញ ៖**

-បានឃើញ: កំណត់ហេតុស្លាប់ចម្លើយរបស់ឈ្មោះ ភេទប្រុសអាយុ ៣២ឆ្នាំ បានឆ្លើយ

---

[3] *សកម្មភាពរបស់ជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ*

[4] *ករណីចែងដោយច្បាប់*

[5] *ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានអោយឈប់ប្រព្រឹត្ត*

[6] *ករណីចែងដោយច្បាប់*

ថា៖ ខ្ញុំបាទសូមជម្រាបថាកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ប្រព្រឹត្តនៅចំណុ

លើផ្លូវជាតិលេខ៦ ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មុនពេលកើតហេតុខ្ញុំបាទបានបើកឡានតាមបណ្ដោយផ្លូវជាតិលេខ៦ ទិសដៅពីត្បូងទៅជើងលុះមកដល់ចំណុចកើតហេតុខាងលើ ក៏មានម៉ូតូម៉ាក SUZUKI VIVA ពណ៌ខ្មៅ បើកបរដោយមនុស្សប្រុសម្នាក់ បានជិះបត់ឆ្លងផ្លូវក្នុងល្បឿនលឿន ដោយមិនបានស៊ីញ៉ូប្រាប់ជាសញ្ញាសម្គាល់ ធ្វើឱ្យខ្ញុំបាទមិនបានដឹងថាគាត់ឆ្លងផ្លូវ ពេលនោះខ្ញុំបាទបាន ព្យាយាមបើកឡានគេចដើម្បីកុំឱ្យបុកត្រូវម៉ូតូរបស់គាត់ តែពេលនោះអ្នកបើកម៉ូតូបានជ្រុលចង្កូតមកបុកឡានរបស់ខ្ញុំបាទពីចំហៀងខាងឆ្វេង រួចក៏ដួលទៅលើផ្លូវតែម្ដង ភ្លាមនោះខ្ញុំបាទបានឈប់ឡានដើម្បីចុះមកជួយមើលគាត់ និងជួយគេហៅឡានពេទ្យមកដឹកគាត់ទៅព្យាបាលនៅមន្ទីរពេទ្យផងដែរ ។

-បានឃើញ៖ បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ៖ របាយការណ៍បញ្ជូនលេខ: ៤៧៩ ល.ស ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២

-បានឃើញ៖ ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ ។

**យល់ឃើញថា៖**

-ក្រោយពីបានពិនិត្យសំណុំរឿង និងឯកសារនានារួចមក ឃើញថា៖ ករណីគ្រោះថ្នាក់ចរាចរណ៍នៅចំណុចស្ថានីយ៍ប្រេ លើផ្លូវជាតិលេខ៦ ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ គឺដោយសារតែគឺម៉ូតូម៉ាក SUZUKI VIVA ពណ៌ខ្មៅ បើកបរដោយឈ្មោះ បានជិះបត់ឆ្លងផ្លូវក្នុងល្បឿនលឿន ដោយមិនបានស៊ីញ៉ូប្រាប់ជាសញ្ញាសម្គាល់ ក៏បានជ្រុលចង្កូតមកបុកឡានបុកជាមួយម៉ាកLEXUS RX300 ពណ៌ទឹកមាស ពាក់ស្លាកលេខ 4 បើកបរដោយឈ្មោះ

បណ្ដាលឱ្យបាត់បង់ជីវិតដោយខ្លួនឯង និងតាមការសន្និដ្ឋានរបស់នគរបាលចរាចរណ៍ផ្លូវគោកបានសន្និដ្ឋានថាមូលហេតុបណ្ដាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍គឺ អ្នកបើកម៉ូតូបើកឆ្លងផ្លូវកាត់មុខមិនគោរពសិទ្ធិអាទិភាពយានផ្លូវត្រង់ ។

-តាមរបាការណ៍របស់នគរបាលចរាចរណ៍ផ្លូវគោកបានបញ្ជាក់កំហុសកើតឡើងដោយឈ្មោះ បើកបរធ្វេសប្រហែសបត់ដោយមិនបានស៊ីញ៉ូប្រាប់ជាសញ្ញាសម្គាល់។

- ម៉្យាងទៀតជនរងគ្រោះបានដកពាក្យបណ្ដឹងឈប់ប្ដឹងឈ្មោះ ។ ចាប់ពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ផងដែល ។

-គប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ: ុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ ទុកឥតចាត់ការតាមមាត្រា ៤១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**ហេតុដូច្នេះសម្រេច៖**

-តម្កល់ទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញតទៅ ។

ថ្ងៃ ព្រហស្បតិ៍ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០២៣

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៚ ✤ ៚

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

លេខ.....

# ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង** **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-**បានឃើញ៖** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា :**

១ . អវត្តមានបទល្មើស

១.១. ☑ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្ដឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្រុះសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្រុះសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្ដល់ប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

៤.២. ☐ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]

៤.៣. ☐ ស្ថានភាពបណ្ដាលសស្ថាតើដែលបន្ថយនូវការទទួលខុសត្រូវ

៤.៤. ☐ ការខកខានរបស់ដើមបណ្ដឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[3]

៤.៨. ☐ ព្យសនកម្ម ឬ ការខាតបង់តិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[4]

៥.៣. ☐ អធិបញ្ញាផ្ដល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសណើររបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការលើកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១ ☐ ការផ្ដល់ជំនួយការអប់រំជំនួយការចោទប្រកាន

**ការសង្កេតផ្សេងៗ** : តាមពាក្យបណ្ដឹងចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ របស់ឈ្មោះ [redacted] ភេទស្រី អាយុ ២៧ឆ្នាំ បានប្ដឹងចោទប្រកាន់ទៅលើឈ្មោះ [redacted] ភេទស្រី អាយុ ២៥ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៣៧ឆ្នាំ ពីបទៈ ឆបោក និងរំលោភលើទំនុកចិត្ត ។

**ដោយបានរៀបរាប់ថា៖** កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] បានមកបញ្ចុះបញ្ចូលឈ្មោះ [redacted] ក្នុងគោលបំណងដើម្បីទិញតូបនៅផ្សារសាន់ហាន [redacted] ទីតាំងនៅភូមិបាក់ខ្ទុក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយបង្ហាញ (កិច្ចសន្យាលក់តូប ចុះថ្ងៃទី១០ ខែ០៥ ឆ្នាំ២០២១) ថាខ្លួនជាម្ចាស់តូបដើម្បីឱ្យឈ្មោះ [redacted] ទុកចិត្ត និងទិញតូបខាងលើនេះពីគាត់ ក្រោយពីបានទទួលការល្បួងលោក ឈ្មោះ [redacted] ក៏ទុកចិត្តហើយសម្រេចចិត្តទិញតូបខាងលើក្នុងតំលៃ

---

[2] ដើមបណ្ដឹងឈប់ប្ដឹង

[3] សកម្មភាពរបស់ជនល្មើសបានបញ្ឈប់បទល្មើស និងស្ដារស្ថានភាពឡើងវិញ

[4] ករណីថែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានអោយឈប់ប្រព្រឹត្ត

[6] ករណីថែងដោយច្បាប់

$៥០០០(ប្រាំពាន់ដុល្លារអាមេរិក) នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ហើយធ្វើការទូទាត់ប្រាក់ផ្តាច់នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ ក្រោយពីបានទិញតូបខាងលើរួចមកឈ្មោះ និងឈ្មោះ បានលួងលោមឈ្មោះ ដោយប្រើល្បិចឱ្យឈ្មោះ (ត្រូវជាម្ដាយមីងរបស់ឈ្មោះ ) ធ្វើជាជួលតូបខាងលើពីឈ្មោះ ក្នុងតំលៃមួយខែ $១៥០(មួយរយហាសិបដុល្លារអាមេរិក) ប៉ុន្តែការជួលតូបខាងលើនេះឈ្មោះ និងឈ្មោះ មិនបានបង់មកឱ្យឈ្មោះ នោះទេដោយបន្តប្រើល្បិចធ្វើជាលេងតុងទីនជាមួយឈ្មោះ ដើម្បីកាត់កងជាមួយថ្លៃជួលតូបខាងលើ ក្រោយពីលេងបានមួយរយៈមកតុងទីនដល់ពេលត្រូវកើបលុយយក ស្រាប់តែឈ្មោះ និងឈ្មោះ មិនមានប្រាក់ឱ្យឈ្មោះ ទៅវិញ រហូតមកដល់ពេលថ្មីៗនេះ ស្រាប់តែម្ចាស់ផ្សារសាន់ហាន បានមកប្រាប់ឈ្មោះ ថាតូបនៅផ្សារសាន់ហានរបស់ឈ្មោះនេះ គឺជាកម្មសិទ្ធិរបស់ម្ចាស់ផ្សារទេ មិនអាចលក់ដូរបានទេ ក្រោយពីដឹងដំណឹងនេះហើយឈ្មោះ ក៏បានទៅសួរនាំឈ្មោះ ឈ្មោះ តែឈ្មោះទាំងពីរនេះបានគេចវេស មិនព្រមមកដោះស្រាយជាមួយឈ្មោះ ឡើយ ។

**ឃ្លានឃើញ៖**

**-បានឃើញ ៖** កំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ ភេទស្រី អាយុ ២៧ឆ្នាំ បានឆ្លើយបំភ្លឺថា ៖ ខ្លួនសូមធ្វើការរក្សានូវខ្លឹមសារពាក្យបណ្តឹងចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ របស់ខ្លួន ទុកជាបានការទាំងស្រុង និងគ្មានអ្វីកែប្រែនោះឡើយ កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ បានមកបញ្ចុះបញ្ចូលខ្លួន ក្នុងគោលបំណងដើម្បីឱ្យខ្លួនទិញតូបផ្សារសាន់ហាន់ ទីតាំងនៅភូមិបាក់ទូក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយបង្ហាញ (កិច្ចសន្យាលក់តូប) ថាខ្លួនជាម្ចាស់តូប ដើម្បីអោយខ្លួនជឿជាក់ទិញ ក្រោយមកទៀតខ្លួនក៏សម្រេចចិត្តទិញតូបខាងលើក្នុងតម្លៃ $៥០០០(ប្រាំពាន់ដុល្លារអាមេរិក) ហើយក៏បានទូទាត់ប្រាក់ផ្ដាច់នៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៣ បន្ទាប់ពីខ្លួនបានទិញរួច ខ្លួនត្រូវបានឈ្មោះ និងឈ្មោះ មកលួងលោមខ្លួន ដោយប្រើល្បិចឱ្យឈ្មោះ (ត្រូវជាមីងគាត់) ធ្វើជាជួលតូបពីខ្លួនក្នុងតម្លៃ $១៥០(មួយរយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ ដោយចាប់ផ្ដើមជួលពីថ្ងៃបង់ផ្ដាច់នោះតែម្ដង ប៉ុន្តែការជួលតូបនោះគាត់បង់បានតែ ០១ខែដំបូងប៉ុណ្ណោះ តែគាត់បែរជាប្រើល្បិចធ្វើជាលេងតុងទីនជាមួយខ្លួន ដើម្បីកាត់កងថ្លៃជួលតូប ក្រោយពីលេងបានមួយរយៈមកដល់ពេលត្រូវកើបលុយ ស្រាប់តែពួកគាត់មិនបានឱ្យប្រាក់មកខ្លួននោះទេ បន្ទាប់មកទៀតស្រាប់តែម្ចាស់ផ្សារសាន់ហាន់បានមកប្រាប់ខ្លួនថាតូបនេះជាកម្មសិទ្ធិរបស់ម្ចាស់ផ្សារទេ ហើយខ្លួនក៏បានទៅសួរឈ្មោះ និងឈ្មោះ ប៉ុន្តែបែរជាពួកគាត់គេចវេស មិនព្រមដោះស្រាយជាមួយខ្លួនទេ ។

**-បានឃើញ ៖** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ។

**-បានឃើញ ៖** ពាក្យបណ្តឹងរបស់ឈ្មោះ ភេទស្រី អាយុ ២៧ឆ្នាំ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ ។

**-បានឃើញ ៖** កិច្ចសន្យាលក់តូប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ។

**-បានឃើញ ៖** កិច្ចសន្យាលក់តូប ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ។

**-បានឃើញ ៖** កិច្ចសន្យាលក់តូបផ្ដាច់ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ ។

**-បានឃើញ ៖** កិច្ចសន្យាជួលតូប ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ។

**-បានឃើញ ៖** ដីកាកោះលើឈ្មោះ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ ៖** ដីកាកោះលើ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ ៖** ដីកាកោះលើឈ្មោះ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ ៖** ដីកាកោះលើកទី២ លើឈ្មោះ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ ៖** ដីកាកោះលើកទី២ លើឈ្មោះ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ ៖** ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ ។

**<u>យល់ឃើញថា៖</u>**[២]

-ជនសង្ស័យឈ្មោះ ក៏មានកិច្ចសន្យាទិញលក់តូប ហើយលក់តូបមកឱ្យដើមបណ្តឹងក៏មានកិច្ចសន្យាទិញលក់ និងផ្អែកតាមចម្លើយរបស់ដើមបណ្តឹងថា ម្ចាស់ផ្សារក៏ជាម្ចាស់កម្មសិទ្ធិនៃតូបនោះ ។

-ក្រោយពីធ្វើការស៊ើបអង្កេតបឋមចប់សព្វគ្រប់ លើសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ បានឃើញថា ៖ អង្គហេតុខាងលើជាវិវាទរដ្ឋប្បវេណី ទាក់ទងនឹងកម្មសិទ្ធិលើតូបផ្សារ ហេតុដូចនេះ គប្បីប្រគល់ជូនតុលាការរដ្ឋប្បវេណីជាអ្នកមានសមត្ថកិច្ចក្នុងការកំណត់ពីអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនៃតូបនេះ ។

-ករណីវិវាទនេះឈ្មោះ បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ និងឈ្មោះ **ពីបទ ឆបោក និងរំលោភលើទំនុកចិត្ត** ។

-គប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ទុកឥតចាត់ការ តាមមាត្រា **៤១** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**<u>ហេតុដូច្នេះសម្រេច៖</u>**[៣]

-តម្កល់ទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញតទៅ ។

-បង្គាប់ឱ្យក្រឡាបញ្ជីជូនដំណឹងដល់ភាគីដើមបណ្តឹង ដើម្បីបើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤
លេខ៖ .

# <u>លិខិតជូនដំណឹង</u>

**យើង តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេ**

- ជម្រាបមកលោកស្រីឈ្មោះ ភេទស្រី អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅផ្ទះលេខ៣៥ ផ្លូវលេខ៦៥៦ ភូមិ១២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
- ត្បិតពាក្យបណ្ដឹងចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ ដែលបានប្ដឹងលើឈ្មោះ ភេទស្រី អាយុ ៣៧ឆ្នាំ ពីបទ: **រំលោភលើទំនុកចិត្ត** នោះយើងបានសម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤ ទុកឥតចាត់ការតាមដីកាសម្រេចលេខ៖ ចុះថ្ងៃទី .25.....ខែ.07....ឆ្នាំ២០២៤ រួចហើយ ។

ថ្ងៃ...ព្រហស្បតិ៍...៥ រោច ខែ[illegible]ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី..២៥..ខែកក្កដា ឆ្នាំ២០២៤
**ជ. ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី៧**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
លេខ ១០៤៦៣២
ម៉ោង ១១:០០ នាទី

## ពាក្យបណ្តឹងឧទ្ធរណ៍

នាងខ្ញុំឈ្មោះ អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ១៦ ភូមិសែនសុខ៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ

**សូមគោរពជូន**

**ឯកឧត្តមព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

*សូមមានជ្រាប។*

**កម្មវត្ថុ:** សុំប្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងឥតចាត់ការលេខ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យោង:**
- សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
- លិខិតជូនដំណឹងលេខ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាប ជូន **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាជ្រាបថា: នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ តាមដីកាតម្កល់រឿងឥតចាត់ការលេខ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ នោះ នាងខ្ញុំមិនអាចទទួលយកសេចក្តីសម្រេចនេះបានទេ ព្រោះធ្វើឲ្យនាងខ្ញុំបាត់បង់នូវផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ និងអាចបន្តធ្វើប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមព្រះរាជអាជ្ញា** មេត្តាបញ្ជូនសំណុំរឿងរបស់នាងខ្ញុំខាងលើទៅសាលាឧទ្ធរណ៍ ទៅតាមនីតិវិធីច្បាប់ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមព្រះរាជអាជ្ញា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

**ស្នាមមេដៃស្តាំ**

**ឧបសម្ព័ន្ធទី៨**

14/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ : . . . . . . . . . ចុះថ្ងៃទី ១៣
ខែ...កក្កដា.... ឆ្នាំ២០២៤
សំណុំរឿងព្រហ្មទណ្ឌ
លេខ : . . . . . . . . . ចុះថ្ងៃទី ១១
ខែ...កុម្ភៈ........ ឆ្នាំ២០២៤

## <u>សេចក្ដីបង្គាប់ឆ្លើយឆ្លង</u>

ឆ្នាំ [illegible] ខែ ...កក្កដា......... ថ្ងៃទី ......[illegible]................. វេលាម៉ោង ...[illegible].......

យើង .... ..................... ក្រឡាបញ្ជី អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញឈ្មោះ : ......[illegible]..............................................

........................................................................................................................ ។

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្ដឹង ឧទ្ធរណ៍ និងដីកាតម្កល់រឿងទុកឥតចាត់ការលេខ . ចុះថ្ងៃទី ...០៤............... ខែ ...[illegible]........ ឆ្នាំ ២០២៤......... ត្រង់ចំណុច : [illegible]......................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................ ។

ឈ្មោះនេះទទួលថា នឹងធ្វើពាក្យបណ្ដឹងបន្ថែមឱ្យទាន់វេលា ។

ក្រែងពុំប្រាកដ យើងបានសូត្រ សេចក្ដីនេះអោយឈ្មោះ ......[illegible]

...[illegible]......................... ស្ដាប់ហើយឱ្យចុះហត្ថលេខា ឬ ផ្តិតម្រាមដៃ ជាមួយយើង ។

អ្នកប្ដឹង — ( [illegible] )

ក្រឡាបញ្ជី — [illegible]

...........................................................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១៨.. ខែ កក្កដា ឆ្នាំ ២០២៤.

ក្រឡាបញ្ជី

បានឃើញ
ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០២៤
តំណាងអយ្យការ

ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

## បញ្ជីរាយលិខិត

សំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២៤

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ | រាយមុខលិខិត ឬ វត្ថុ | ចំនួន | សេចក្ដីផ្សេង ៗ |
|---|---|---|---|---|
| 1 | 29.01.24 | ពាក្យបណ្ដឹង | 29 ស | |
| 2 | 05.2.24 | ដីកាកោះ | 23 ស | |
| 3 | 06.2.24 | ពាក្យស្នើសុំការពារក្ដី [illegible] | 03 ស | |
| 4 | 07.2.24 | កំណត់ហេតុសួរចម្លើយ | 01 ស | |
| 5 | 27.2.24 | ពាក្យ [illegible] | 08 ស | |
| 6 | 18.3.24 | ពាក្យសុំពន្យារពេល | 02 ស | |
| 7 | 25.3.24 | ពាក្យសុំពន្យារពេល | 02 ស | |
| 8 | 05.4.24 | កំណត់ហេតុសួរចម្លើយ | 03 ស | |
| 9 | 05.4.24 | កំណត់ហេតុសួរចម្លើយ | 01 ស | |
| 10 | 20.5.24 | ពាក្យ [illegible] | 29 ស | |
| 11 | 04.6.24 | ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ | 06 ស | |
| 12 | 04.6.24 | [illegible] | 01 ស | |
| 13 | 01.7.24 | ពាក្យបណ្ដឹងឧទ្ធរណ៍ | 02 ស | |
| 14 | 19.7.24 | [illegible] | 01 ស | |

**ឧបសម្ព័ន្ធទី១០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

លេខ៖..

**អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

**<u>សូមគោរពជូន</u>**

**ឯកឧត្តមអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

**កម្មវត្ថុ ៖**

-សំណើសុំបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យោង ៖**

- សេចក្ដីចម្លងបណ្ដឹងតវ៉ាលេ ៈថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ។

-ពាក្យបណ្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ របស់ឈ្មោះ ភេទប្រុស អាយុ ៥៩ឆ្នាំ ។

-លិខិតជូនដំណឹងលេខ៖ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាតម្កល់រឿងទុកឥតចាត់ការលេខ៖ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

សេចក្ដីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ តំណាងអយ្យការ សូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា៖ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានទទួលចាត់ការទៅលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានដើមបណ្ដឹងឈ្មោះ ភេទប្រុស អាយុ ៥៩ឆ្នាំ បានប្ដឹងទៅលើឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ក្រោយពីការស៊ើបអង្កេតបឋមរួចមកឃើញថាក្នុងរឿងនេះមិនមានបទល្មើសព្រហ្មទណ្ឌ ដូចការប្ដឹងចោទប្រកាន់របស់ដើមបណ្ដឹងនោះឡើយ ទើបតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ៖ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ និងបានជូនដំណឹងទៅដើមបណ្ដឹងអំពីការតម្កល់នេះតាមរយៈលិខិតជូនដំណឹងលេខ៖ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ បន្ទាប់មកនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ទើបដើមបណ្ដឹងខាងលើបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម** មេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃព្រហស្បតិ៍ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ... ខែកក្កដា ឆ្នាំ២០២៤

**ព្រះរាជអាជ្ញារង**

**<u>បានឃើញ និង ឯកភាព</u>**

**ឯកឧត្តមព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង**

**រាជធានីភ្នំពេញ**

ថ្ងៃព្រហស្បតិ៍ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ... ខែកក្កដា ឆ្នាំ២០២៤

**ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

# ដីកាកោះ

**យើង អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

បង្គាប់មកឈ្មោះ : ភេទប្រុស អាយុ ៣៩ឆ្នាំ ជាដើមបណ្ដឹង ។

ទីលំនៅសព្វថ្ងៃ : ភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

ឱ្យចូលមកកាន់: **មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

កាលបរិច្ឆេទ : នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤, វេលាម៉ោង ០៨ និង ៣០នាទីព្រឹក

ដើម្បី : ឆ្លើយបំភ្លឺ ។

ពីដំណើររឿង : បណ្ដឹងឧទ្ធរណ៍របស់លោក ។

ពីបទ : រំលោភលើទំនុកចិត្ត ។

សាម៉ីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤
**អគ្គព្រះរាជអាជ្ញារង**

យើង........................................................................
បានប្រគល់ដីកាកោះនេះអោយឈ្មោះ ................................
ទីលំនៅសព្វថ្ងៃនៅ.............................ឃុំ.សង្កាត់...............
ស្រុក.ខណ្ឌ...........................ខេត្ត.រាជធានី.........................
នៅថ្ងៃទី...............ខែ....................ឆ្នាំ២០២៤ ហើយប្រាប់ថា
អោយប្រគល់ដីកាកោះនេះដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅដល់តុលាការ។

អ្នកទទួល អ្នកប្រគល់
ហត្ថលេខា ឬផ្ដិតម្រាមមេដៃ

ផ្លូវលោកតាក្រហមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី១២

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងព្រហ្មទណ្ឌតម្កល់ទុកឥតចាត់ការ**

**លេខ ចុះថ្ងៃទី ១៧-០៦-២០២៤**

## កំណត់ហេតុស្តាប់យកចម្លើយ

ឆ្នាំពីរពាន់ម្ភៃបួន ខែកក្កដា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោង ប្រាំបួន និងសាមសិបនាទី

យើង ជាអគ្គព្រះរាជអាជ្ញារង អមសាលាឧទ្ធរណ៍ភ្នំពេញ ដោយមាន កញ្ញា ជាក្រឡាបញ្ជីអមផង បានស្តាប់យកចម្លើយរបស់ឈ្មោះ ជាដើមបណ្តឹង ដូចខាងក្រោម៖

សួរ-ឆ្លើយ៖ ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល មុខរបរ លក់គ្រឿងសំណង់ ប្រពន្ធឈ្មោះ មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (ស្លាប់) ទោសពីមុន គ្មាន ។

សួរ-ឆ្លើយ៖ ខ្ញុំបាទសូមរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ និងចម្លើយដែលខ្ញុំបាទបានឆ្លើយនៅអយ្យការអមសាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ទុកនៅដដែល ។

សួរ-ឆ្លើយ៖ ខ្ញុំបាទសុំទាមទារឲ្យឈ្មោះ សងថ្លៃគ្រឿងសំណង់ដែលបានជំពាក់រូបខ្ញុំចំនួន ១០,១៧៣ (មួយម៉ឺនមួយរយចិតសិបបី) ដុល្លារអាមេរិកវិញ និងសុំទាមទារសំណងខាតពេលវេលា ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។

បញ្ឈប់កំណត់ហេតុស្តាប់ចម្លើយនេះនូវវេលាម៉ោងដប់ព្រឹក នាថ្ងៃខែឆ្នាំដដែល ហើយបានអានកំណត់ហេតុនេះសាជាថ្មីឱ្យសាម៉ីខ្លួនស្តាប់ថាត្រឹមត្រូវហើយ សុខចិត្តផ្តិតមេដៃស្តាំជាមួយយើង ។

**ដើមបណ្តឹង** **ក្រឡាបញ្ជី** **អគ្គព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី១៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

## សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បានឃើញ សំណុំរឿង "តម្កល់រឿងទុកឥតចាត់ការ" ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ លេខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ ។

បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់ដើមបណ្តឹងឈ្មោះ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់គ្រឿងសំណង់ មានទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ របស់ឈ្មោះ ជាដើមបណ្តឹង ប្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងទុកឥតចាត់ការខាងលើ ។

បានឃើញ លិខិតចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ។

**អង្គហេតុសង្ខេប៖**

កាលពីអំឡុងឆ្នាំ២០១៨ ឈ្មោះ បានទិញគ្រឿងសំណង់ ពីឈ្មោះ និង ប្រពន្ធឈ្មោះ ជាម្ចាស់ដេប៉ូលក់គ្រឿងសំណង់យីហោ ដែលមានទីតាំងស្ថិតនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល មានដូចជា ដែក ស៊ីម៉ងត៍ ថ្ម ខ្សាច់ ឥដ្ឋការ៉ូ ថ្នាំពណ៌ រាល់ពេលដែលឈ្មោះ កម្ម៉ង់ទិញឥវ៉ាន់ឈ្មោះ តែងតែចេញវិក័យបត្រឱ្យ ០១សន្លឹក និងរក្សាទុកខ្លួនឯង ០១សន្លឹក ហើយឈ្មោះនេះតែងតែសុំទូទាត់វិក័យបត្រចាស់ សុំជំពាក់វិក័យបត្រថ្មីរហូត និងឱ្យបុគ្គលិកដឹកតាមរថយន្ត ឬរ៉ឺម៉ក ទៅឱ្យដល់ការដ្ឋានរបស់ឈ្មោះ ជាបន្តបន្ទាប់ រហូតដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ ឈ្មោះ ក៏ឈប់មកទិញគ្រឿងសំណង់ ហើយក៏មិនសងប្រាក់ដែលជំពាក់ឈ្មោ ចំនួន ១០,១៧៣ (មួយម៉ឺនមួយរយចិតសិបី) ដុល្លារអាមេរិក ។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ឈ្មោះ ក៏បានដាក់ពាក្យបណ្ដឹងចូលសាលាសង្កាត់កំពង់សំណាញ់ ក្រោយមកអាជ្ញាធរបានអញ្ជើញឈ្មោះ ចូលមកដោះស្រាយប៉ុន្តែនៅតែមិនឯកភាពគ្នាឡើយ។ ទើបនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ឈ្មោះ ក៏បានមកដាក់ពាក្យបណ្ដឹងចូលស្នងការដ្ឋាននគរបាលខេត្តកណ្ដាល ក្រោយទទួលពាក្យបណ្ដឹងសមត្ថកិច្ចបានកោះហៅឈ្មោះ ហើយឈ្មោះនេះបានឆ្លើយបំភ្លឺជូនសមត្ថកិច្ចថា កាលពីអំឡុងឆ្នាំ២០១៨ ខ្លួនពិតជាបានទិញគ្រឿងសំណង់ពីដេប៉ូយីហោ ដែលមានម្ចាស់ឈ្មោះ ជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០២១ សរុបទឹកប្រាក់ចំនួន ១០,១៧៣ (មួយម៉ឺនមួយរយចិនសិបបី) ដុល្លារអាមេរិក ហើយមិនទាន់បានសងប្រាក់នោះមែន។

## I- លទ្ធផលការស៊ើបអង្កេត និងឯកសារនានា

-បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ របស់ឈ្មោះ និងឈ្មោះ បានប្ដឹងលើឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ ពីបទ៖ រំលោភទំនុកចិត្ត ។

-បានឃើញ វិក័បត្រទូទាត់ថ្លៃសំណង់ ច្បាប់ដើម និងថតចម្លង (ចំនួន៦៤សន្លឹក) ។

-បានឃើញ ឯកសារនានាមានក្នុងសំណុំរឿងស្រាប់ ។

<u>ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌</u>

បានឃើញ កំណត់ហេតុស្ដាប់ការបំភ្លឺរបស់ឈ្មោះ ជាដើមបណ្ដឹង បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០១៨ ឈ្មោះ អ្នកម៉ៅការសំណង់ បានមកទិញគ្រឿងសំណង់ពីដេប៉ូរបស់ខ្លួនឈ្មោះ ដែលមានទីតាំងនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានដូចជា ដែក ស៊ីម៉ង់ត៍ ថ្ម ខ្សាច់ ឥដ្ឋការ៉ូ ថ្នាំពណ៌ ជាបន្តបន្ទាប់ ហើយរាល់ពេលទិញលក់ខ្លួនតែងតែចេញវិក័យបត្រឱ្យទៅឈ្មោះ ០១សន្លឹក និងទុកនៅដេប៉ូខ្លួន ០១សន្លឹក ពេលគាត់មកកម្ម៉ង់ទិញតែងតែសុំខ្លួនទូទាត់វិក័យបត្រថ្មី ហើយសុំជំពាក់វិក័យបត្រចាស់រហូត សរុបទឹកប្រាក់ ១០.១៧៣ (មួយម៉ឺនមួយរយចិតសិបបី ) ដុល្លារ។ រាល់ពេលដែលឈ្មោះ កម្ម៉ង់ទិញគ្រឿងសំណង់ពីដេប៉ូបុគ្គលិករបស់ខ្លួនតែងតែដឹកឱ្យគាត់ដល់ការដ្ឋាន។ ចាប់តាំងពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ មកឈ្មោះ ឈប់មកទិញគ្រឿងសំណង់ពីដេប៉ូរបស់ខ្លួន ហើយក៏មិនសងប្រាក់ដែលនៅជំពាក់មកខ្លួនឡើយ ដោយគេចវេសរហូតមកសព្វថ្ងៃនេះ។

បានឃើញ កំណត់ហេតុស្ដាប់ការបំភ្លឺរបស់ឈ្មោះ ជាសាក្សី បានឆ្លើយថា៖ ខ្លួនធ្វើការនៅដេប៉ូលក់គ្រឿងសំណង់ ជាង១០ឆ្នាំមកហើយ ដែលមានថៅកែឈ្មោះ និងប្រពន្ធឈ្មោះ នៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានតួនាទីជាអ្នកដឹកឥវ៉ាន់។ នៅអំឡុងឆ្នាំ២០១៨ ថៅកែបានឱ្យខ្លួនដឹកដែក ស៊ីម៉ង់ត៍ ឥដ្ឋ ខ្សាច់ ថ្ម ទៅឱ្យឈ្មោះ ន ជាអ្នកម៉ៅការសំណង់ ទៅឱ្យតាមការដ្ឋានរបស់គាត់ដឹកតាមរថយន្ត ហើយពេលខ្លះដឹកតាមរ៉ឺម៉កម៉ូតូជាបន្តបន្ទាប់ រហូតមកដល់អំឡុងឆ្នាំ២០២១ ទូទៅអីវ៉ាន់គឺអតិថិជនទូទាត់ផ្ទាល់ជាមួយថៅកែ ខ្លួនមានតួនាទីដឹកឥវ៉ាន់តែប៉ុណ្ណោះ។

បានឃើញ កំណត់ហេតុស្ដាប់ការបំភ្លឺរបស់ឈ្មោះ ជាសាក្សី បានឆ្លើយថា៖ នៅឆ្នាំ២០១៦ ខ្លួនបានចូលធ្វើការនៅដេប៉ូលក់គ្រឿងសំណង់ មានតួនាទីជាអ្នកដឹកឥវ៉ាន់។ នៅអំឡុងឆ្នាំ២០១៨ ថៅកែបានឱ្យខ្លួនដឹក ដែក ស៊ីម៉ង់ត៍ ឥដ្ឋ ខ្សាច់ ថ្ម ទៅឱ្យឈ្មោះ ជាអ្នកម៉ៅការសំណង់ ទៅការដ្ឋានរបស់គាត់ដឹកតាមរថយន្ត ហើយពេលខ្លះដឹកតាមរ៉ឺម៉កម៉ូតូជាបន្តបន្ទាប់ រហូតអំឡុងឆ្នាំ២០២១ ហើយសម្រាប់ការទូទាត់ប្រាក់គឺអតិថិជនត្រូវទូទាត់ជាមួយថៅកែខ្លួន ខ្លួនដឹងតែដឹកឥវ៉ាន់ប៉ុណ្ណោះ។

បានឃើញ កំណត់ហេតុស្តាប់ការបំភ្លឺរបស់ឈ្មោះ ជាជនសង្ស័យ បានឆ្លើយថា៖ កន្លងមក ខ្លួនបានទិញគ្រឿងសំណង់ពីដេប៉ូឈ្មោះ និងប្ដីឈ្មោះ ដូចជា ដែក ថ្ម ខ្សាច់ ស៊ីម៉ង់ត៍ ឥដ្ឋការ៉ូ និងសម្ភារៈផ្សេងៗទៀត ដើម្បីសាងសង់ផ្ទះ។ អំឡុងឆ្នាំ២០១៨ ខ្លួនកម្ម៉ង់ទិញគ្រឿងសំណង់ជាបន្តបន្ទាប់ ទិញគ្រឿងសំណង់ថ្មីសុំគាត់ខ្ចីទាត់ក៏យកបត្រចាស់ រហូតមកដល់អំឡុងឆ្នាំ២០២១ ដោយសារតែពេលនោះមាន វិបត្តិកូវីត១៩ សេដ្ឋកិច្ចធ្លាក់ចុះរកស៊ីមិនសូវបាន ទើបខ្លួនមិនបានខ្ចីទាត់ប្រាក់ដែលខ្វះទៅឱ្យគាត់បន្ត។ នៅថ្ងៃ ទី២៥ ខែធ្នូ ឆ្នាំ២០២៣ ឈ្មោះ បានប្ដឹងខ្លួនទៅសាលាសង្កាត់កំពង់សំណាញ់ ដើម្បីសម្រុះសម្រួល គ្នាម្ដងរួចហើយ ថ្ងៃនោះដែរខ្លួនទទួលស្គាល់ប្រាក់ជំពាក់ឈ្មោះ សរុបចំនួន ១០.១៧៣ (មួយម៉ឺន មួយរយចិតសិបបី) ដុល្លារអាមេរិក ខ្លួនសុំសងគាត់ជាដំណាក់កាល រយៈពេល០២ឆ្នាំ។

<u>ដំណាក់កាលអយ្យការសាលាដំបូង</u>

បានឃើញ កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ជាដើមបណ្ដឹង បានឆ្លើយថា៖ ខ្លួនសូមរក្សាពាក្យបណ្ដឹង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ និងចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាល យុត្តិធម៌ ទុកជាបានការដដែល និងសូមបញ្ជាក់បន្ថែមថា កាលពីអំឡុងឆ្នាំ២០១៨ ឈ្មោះ បានយកគ្រឿងសំណង់ពីខាងដេប៉ូរបស់ខ្លួនមានដូចជា ដែក ស៊ីម៉ង់ត៍ ថ្ម ខ្សាច់ ឥដ្ឋការ៉ូ ថ្នាំពណ៌ ជាបន្តបន្ទាប់ រហូតដល់ថ្ងៃទីមិនចាំឆ្នាំ២០២២ គាត់បានជំពាក់គ្រឿងសំណង់នៅដេប៉ូខ្លួនចំនួន ១០.១៧៣ (មួយម៉ឺនមួយរយ ចិតសិបបី)ដុល្លារអាមេរិក រួចក៏ឈប់ទិញពីខាងដេប៉ូខ្លួនតែម្ដង។ ខ្លួនធ្លាប់ជួបឈ្មោះ ចំនួន ០២ដង គឺនៅខាងសង្កាត់កំពង់សំណាញ់ និងនៅសមត្ថកិច្ចប៉ុន្តែមិនត្រូវគ្នាទេ ដោយឈ្មោះ សុំសងចំនួន ០២ឆ្នាំ ប៉ុន្តែខ្លួនមិនអាចទទួលយកបាន ដោយគាត់មិនបានកំណត់ថាឱ្យប៉ុន្មានក្នុងមួយខែនោះទេ ពេលនោះ ខ្លួនទាមទារត្រឹមចំនួន ០៥ខែ តែគាត់មិនព្រម។ រហូតដល់សព្វថ្ងៃទីឈ្មោះ នៅមិនទាន់បានខ្ចីទាត់ ប្រាក់ឱ្យខ្លួនវិញទេ។ ខ្លួនសូមសំណូមពរតំណាងអយ្យការជួយរកយុត្តិធម៌ឱ្យខ្លួនផង និងផ្ដន្ទាទោសជនល្មើស តាមច្បាប់ ហើយសុំទាមទារថ្លៃគ្រឿងសំណង់ចំនួន ១០.១៧៣ (មួយម៉ឺនមួយរយចិតសិបបី) ដុល្លារអាមេរិក វិញ និងថ្លៃខាតពេលវេលាចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។

បានឃើញ កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ ជាសាក្សី បានឆ្លើយថា៖ ខ្លួនសូមរក្សាចម្លើយ ដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ ទុកជាបានការដដែល។ ខ្លួនសូមបញ្ជាក់បន្ថែមថា កន្លងមកខ្លួនពិតជាធ្លាប់បានដឹក ដែក ឥដ្ឋ ស៊ីម៉ង់ត៍ ខ្សាច់ ជូនកាលតាមឡាន ជូនកាល តាមម៉ូតូ យកទៅឱ្យឈ្មោះ នៅឯការដ្ឋានរបស់គាត់ជាច្រើនកន្លែង ពីដេប៉ូឈ្មោះ ពិតមែន ប៉ុន្តែរឿងលុយកាក់ខ្លួនមិនដឹងថាចំនួនប៉ុន្មានទេ ដឹងត្រឹមតែថាឈ្មោះ នៅជំពាក់ប្រាក់ ថៅកែរបស់ខ្លួន។

បានឃើញ កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ ជាសាក្សី បានឆ្លើយថា៖ ខ្លួនសូមរក្សាចម្លើយ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល។ កន្លងមកឈ្មោះ ពិតជាធ្លាប់បានមកទិញ ដែក ស៊ីម៉ង់ត៍ ឥដ្ឋ ខ្សាច់ ពីដេប៉ូឈ្មោះ ជាច្រើនដង ពេលនោះ ខ្លួនជាអ្នកដឹកយកទៅឱ្យដល់ការដ្ឋានរបស់គាត់នៅក្បែរបន្ទាយសម្ដេចក្រុងតាខ្មៅ។ រឿងប្រាក់ដែលឈ្មោះ មិនទាន់បានខ្ចីទាត់ឱ្យថៅកែខ្លួនមិនដឹងចំនួនប៉ុន្មានទេ ដឹងត្រឹមតែថាមិនទាន់គ្រប់ចំនួន។

-បានឃើញ កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ ជាជនសង្ស័យ បានឆ្លើយថា៖ ខ្លួនសូមរក្សា

ចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤ ទុកជាបានការដដែល។ ខ្លួនស្គាល់ និងរកស៊ីជាមួយឈ្មោះ ត្រូវជាប្រពន្ធឈ្មោះ តាំងពីឆ្នាំ២០១០មកម្ល៉េះ ។ ចំពោះសម្ភារៈសំណង់ដែលខ្លួនទិញពីដេប៉ូឈ្មោះ នោះមានដូចជា ដែក ការ៉ូ ស៊ីម៉ង់ត៍ ជាច្រើនលើក សរុបជាទឹកប្រាក់ចំនួន ១០.១៧៣ (មួយម៉ឺនមួយរយចិតសិបបី) ដុល្លារមែន ដោយពេលទិញមិនទាន់គិតលុយភ្លាមៗនោះទេ គឺគាត់សរសេរតែវិក័យបត្រថ្លៃសំណង់សិន ទាល់តែខ្លួនមានលុយទើបទូទាត់ម្តង។ ចំពោះប្រាក់ដែលខ្លួនជំពាក់ឈ្មោះ នោះគឺខ្លួនសុំសងនៅខែឧសភា ឆ្នាំ២០២៥ ទើបមានលទ្ធភាពព្រោះបច្ចុប្បន្នខ្លួនក៏ជំពាក់គេដែរ ហើយការងារក៏មិនមានទៀត។ ខ្លួនសុំសំណូមពរតំណាងអយ្យការជួយពន្យាពេលឱ្យខ្លួនសងលុយឈ្មោះ ផង។

ដំណាក់កាលអយ្យការសាលាឧទ្ធរណ៍

បានឃើញ កំណត់ហេតុស្តាប់យកចម្លើយរបស់ឈ្មោះ ជាដើមបណ្តឹង បានឆ្លើយថា៖ ខ្លួនសូមរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ និងចម្លើយដែលខ្លួនបានឆ្លើយនៅអយ្យការអមសាលាដំបូងខេត្តកណ្តាល ទុកនៅដដែល។ ខ្លួនសូមទាមទារឱ្យឈ្មោះ សងថ្លៃគ្រឿងសំណង់ដែលបានជំពាក់រូបខ្លួនចំនួន ១០.១៧៣ (មួយម៉ឺនមួយរយចិតសិបបី) ដុល្លារអាមេរិក វិញ និងសុំទាមទារសំណងខាតពេលវេលា ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។

## II- គំណាងមហាអយ្យការសាលាឧទ្ធរណ៍

១- ផ្អែកតាមចម្លើយរបស់ដើមបណ្តឹង ចម្លើយរបស់សាក្សី ចម្លើយរបស់ជនសង្ស័យ ឯកសារវិក័យបត្រថ្លៃទូទាត់សំណង់ និងរបាយការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ឃើញថា ឈ្មោះ បានទទួលស្គាល់នូវប្រាក់ដែលខ្លួនជំពាក់ថ្លៃសំណង់ដើមបណ្តឹងឈ្មោះ ចំនួន ១០.១៧៣ (មួយម៉ឺនមួយរយចិតសិបបី) ដុល្លារអាមេរិក ប្រាកដមែន និងមានចេតនាសងប្រាក់នោះឱ្យទៅដើមបណ្តឹងវិញ ដោយពុំមានគេចវេសនោះឡើយ។ អង្គហេតុខាងលើនេះ គឺជាវិវាទដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា (សងប្រាក់) ដែលជាសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណី។

២-យល់ឃើញថា សំអាងហេតុនៃការយល់ឃើញ ក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល មានលក្ខណៈត្រឹមត្រូវ សមស្របតាមហេតុការណ៍ដែលមានក្នុងអង្គហេតុ និងភស្តុតាងនានា។ គប្បីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

## ដូច្នេះសម្រេច

តម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែ

ថ្ងៃ.សុក្រ.៤.កើត......ខែ.ស្រាពណ៍.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី.២៣...ខែ.សីហា...ឆ្នាំ២០២៤

**អគ្គព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធទី១៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

លេខ..

# ដីកាបញ្ជូន

## ផ្ញើជូន: អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

| រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|
| -បញ្ជូនសំណុំរឿងតម្កល់ទុកឥតចាត់ការលេខ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ | ០១រឿង | ដើម្បីចាត់ការជាសមត្ថកិច្ច ។ |
| សរុប | ០១រឿង | |

ថ្ងៃ.អង្គារ.២រោច............ ខែ.អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី.៣១... ខែ..តុលា.... ឆ្នាំ២០២៣

**ត.ប. អគ្គព្រះរាជអាជ្ញា**

**អគ្គព្រះរាជអាជ្ញារង**

ឧបសម្ព័ន្ធទី១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

លេខ

## សេចក្តីសម្រេចបញ្ជាឱ្យចោទប្រកាន់

-បានឃើញ មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ ភេទប្រុស អាយុ ៥៤ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្តឹងចោទប្រកាន់លើឈ្មោះ ភេទស្រី អាយុ ៦១ ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានស្នាក់នៅផ្ទះលេខ៣៨ ផ្លូវលេខ ៦០៦ ភូមិ៩ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពីបទ “លួច និងក្លែងឯកសារកាន់កាប់ដី” ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សេចក្តីចម្លងពាក្យបណ្តឹងតវ៉ាលេខ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានប្តឹងតវ៉ាប្រឆាំងនឹងដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿង តម្កល់រឿងទុកឥតចាត់ការ ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍លេខ ០២៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ។

### អង្គហេតុ

នៅអំឡុងឆ្នាំ២០០៥ ឈ្មោះ បានទិញដីមួយកន្លែងមានទំហំ ១០.៤៤៥ ម$^2$ ស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលបានទទួលស្គាល់ដោយអាជ្ញាធរឃុំអំពិល លេខ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។ លុះដល់ខែធ្នូ ឆ្នាំដដែល ឈ្មោះ បានទិញដីមួយកន្លែងទៀត ដោយទិញចូលហ៊ុនគ្នាជាមួយឈ្មោះ ក្នុងចំណែកស្មើគ្នា មានទំហំ ៥៣៨៦ ម$^2$ ជាតរាក

កម្មសិទ្ធិ ដែលបានបញ្ជាក់ទទួលស្គាល់ដោយលោកមេឃុំអំពិល ដែលមានលេខ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៥ ។ ចំពោះឯកសារដីទាំងពីរខាងលើ និងឯកសារផ្សេងៗរួមទាំងសញ្ញាប័ត្របញ្ចប់សាកលវិទ្យាល័យ គឺឈ្មោះ ជាអ្នករក្សាទុកនៅក្នុងបន្ទប់ ស្ថិតនៅក្នុងបរិវេណផ្ទះរបស់ឈ្មោះ ។

ដោយឈ្មោះ មើលឃើញថាមុខរបររបស់ឈ្មោះ កំពុងជួបបញ្ហា បារម្ភនឹងការសងប្រាក់ឱ្យខ្លួនវិញ គួបផ្សំនឹងឈ្មោះ មិនស្ទូវនៅផ្ទះផងនោះ ឈ្មោះ បានលួចយកឯកសារកាន់កាប់ដីទាំងពីរខាងលើទៅរក្សាទុក មិនត្រឹមតែប៉ុណ្ណោះឈ្មោះ បានសរសេរឈ្មោះខ្លួន ( និងផ្តិតមេដៃបន្ថែមលើឯកសារកាន់កាប់ដី ទំហំ ១០.៤៤៥ ម² ដែលជាដីកម្មសិទ្ធិរបស់ឈ្មោះ ) ។(ឯកលេខ០៦ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១)

## លទ្ធផលការស៊ើបអង្កេត និង ឯកសារនានា

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ជនសង្ស័យឈ្មោះ បានឆ្លើយនៅមុខតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ ខ្លួនសូមបដិសេធចំពោះការប្តឹងចោទរបស់ឈ្មោះ ចោលទាំងស្រុង ព្រោះពុំមែនជាការពិតទេ ។ ចំពោះដីដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទំហំ ១០.៤៤៥ (មួយម៉ឺនបួនរយសែសិបប្រាំ) ម៉ែត្រការ៉េ (លិខិតផ្ទេរសិទ្ធិ កាន់កាប់ដី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥) និងដីដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទំហំ ៥.៣៨៦ (ប្រាំពាន់បីរយប៉ែតសិបប្រាំមួយ) ម៉ែត្រការ៉េ (លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥) គឺខ្លួន និងដើមបណ្តឹងឈ្មោះ ទិញដោយចូលប្រាក់គ្នាម្នាក់ពាក់កណ្តាល ។ ឈ្មោះ បានជំពាក់ប្រាក់ខ្លួន សរុបចំនួន ៩៩,០០០ (ប្រាំបួនម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដែលចំនួនទឹកប្រាក់នេះ គិតទាំងការលួចទៅខ្ចីពីកូនស្រីនាងខ្ញុំចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក, ការខ្ចីផ្ទាល់មាត់ និងការខ្ចី ដែលមានជាលិខិតស្នាម ដែលប្រាក់ខ្ចីនេះ គឺនាងខ្ញុំបានទៅខ្ចីបន្ត ពីគេយកមកឱ្យឈ្មោះ រហូតមកដល់ ពេលនេះមិនទាន់បានសងខ្លួនមួយកាក់មួយសេននោះទេ ។

ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៥ ខ្លួនជាអ្នករក្សាទុកតាំងពីដំបូង គឺឈ្មោះ ដែលជាសាក្សីក្នុងរឿងទិញដីទាំងពីរកន្លែងកាន់មកប្រគល់ឱ្យខ្លួនជាមួយនិងឈ្មោះ ដល់ផ្ទះ ។ (ឯកសារ៥/៤, ឯកសារ៥/៣, ឯកសារ៥/២, ឯកសារ៥/១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៥)

ចំពោះលិខិតផ្ទេរសិទ្ធកាន់កាប់ដី ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ គឺខ្លួន និងឈ្មោះ ទិញរួមគ្នាហើយការផ្តិតមេដៃគឺ ផ្តិតក្នុងពេលតែមួយ រួមទាំងឈ្មោះ ផងដែរ ចំណែកឈ្មោះ ឈ្មោះ

ិងឈ្មោះ បានផ្តិតមេដៃរួចហើយ ប៉ុន្តែខ្លួនមិនដឹងថាឈ្មោះ នេះនៅទីណាពិតប្រាកដនោះទេ ដឹងតែគាត់រស់នៅខេត្តសៀមរាប ។ (ឯកសារ ៥/៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥)

ចំពោះពាក្យផ្ទេរសិទ្ធិ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ គឺឈ្មោះ ជាអ្នកសរសេរ ដោយផ្ទាល់ដៃ និងបានផ្តិតមេដៃ នៅលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥ នៅក្នុងហាងកាហ្វេមួយកន្លែងនៅជិតផ្ទះរបស់ខ្លួន ហើយមានម្ចាស់ហាងឈ្មោះ ជាអ្នកបានដឹង និងឃើញផ្ទាល់ភ្នែក ថាជាការព្រមព្រៀងគ្នា មិនមែនជាការបង្ខិតបង្ខំ មិនតែប៉ុណ្ណោះ ម្ចាស់ហាងក៏បានទៅជួយធ្វើជាសាក្សីបំភ្លឺសាលាដំបូងខេត្តសៀមរាប ឲ្យខ្លួនទៀតផង ។ (ឯកសារ ៥/២ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥)

ចំពោះដីទាំងពីរកន្លែងនេះ ត្រូវបានសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមរដ្ឋប្បវេណីលេខ ៣៧ ឃ/៣៧៣ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រគល់មកឲ្យខ្លួនកាន់កាប់ទាំងពីរកន្លែង ប៉ុន្តែសាលក្រមនេះត្រូវបានឈ្មោះ ប្តឹងឧទ្ធរណ៍ហើយ មកដល់ពេលនេះមិនទាន់មានដីកាកោះហៅពីខាងសាលាឧទ្ធរណ៍កោះហៅខ្លួនចូលបំភ្លឺនៅឡើយទេ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់សាក្សីឈ្មោះ បានឆ្លើយនៅមុខតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ ខ្លួនបានស្បថរួចរាល់ហើយ ។ ខ្លួនមិនមែន ជាសាច់ញាតិរបស់គូភាគីក្នុងរឿងក្តីនេះទេ ។ ខ្លួនសូមឆ្លើយតែការពិតដែលខ្លួនបានដឹង បានឮ និងបានឃើញផ្ទាល់ភ្នែក ។ (ឯកសារលេខ១០ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២)

នៅថ្ងៃខែមិនចាំ ក្នុងឆ្នាំ២០១៥ ខ្លួនឃើញឈ្មោះ និងឈ្មោះ បានមកហាងលក់កាហ្វេរបស់ខ្លួន យីហោ ដែលមានទីតាំងស្ថិតនៅភូមិទួលសំពៅ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ ពេលនោះខ្ញុំបានឃើញឈ្មោះ សរសេរពាក្យផ្ទេរសិទ្ធិ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដោយផ្ទាល់ដៃ បន្ទាប់មកអ្នកទាំងពីរបានផ្តិតមេដៃនៅលើលិខិតខាងលើដោយគ្មានការបង្ខិតបង្ខំ ហើយខ្លួនក៏ពុំឃើញថាឈ្មោះ បានបង្ហាញសកម្មភាព ឬទឹកមុខមិនពេញចិត្ត ឬត្រូវបានគេបង្ខិតបង្ខំនោះទេ ហើយឈ្មោះ ក៏មិនបាននិយាយស្តី ឬធ្វើសកម្មភាពណាដែលក្នុងន័យគាបសង្កត់ បង្ខិតបង្ខំ ឬគំរាមកំហែង និងបញ្ជាឲ្យឈ្មោះ សរសេរនោះទេ ។

ចំពោះអត្ថន័យនៅក្នុងពាក្យផ្ទេរសិទ្ធិ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដែលលោកតំណាងអយ្យការបានឱ្យខ្លួនអានដោយខ្លួនឯងនោះ គឺពិតជាពាក្យពេចន៍ដែលឈ្មោះ បានសរសេរមែន គ្មាន ការកែប្រែនោះទេ ព្រោះនៅថ្ងៃដែលឈ្មោះ សរសេរនោះ ខ្លួនក៏បានអានដែរ។ ខ្លួនដឹងតែប៉ុណ្ណឹង ក្រៅពីនេះខ្លួនមិនដឹងទេ ។ -

-បានឃើញ កំណត់ហេតុសួរយកចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយនៅចំពោះមុខតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថា៖ ខ្លួនសុំបញ្ជាក់ថា ឈ្មោះ ។ ជាបងស្រីបង្កើតរបស់ខ្លួន ។ កាលពីអំឡុងឆ្នាំ២០០៥ ខ្លួនបានទិញដីមួយកន្លែងតែម្នាក់ឯង មានទំហំចំនួន ១០.៩៤៥ ម$^{2}$ ក្នុងតម្លៃ ១ ម៉ឺនដុល្លារ ២ កាក់ ក្នុងមួយម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដោយឱ្យឈ្មោះ ជាអ្នកទទួលជួយទិញឱ្យ ។ ក្រោយមកក្នុងខែធ្នូ ឆ្នាំ២០០៥ ខ្លួនបានទិញដីមួយកន្លែងទៀតដែលមានទីតាំងជាប់គ្នាជាមួយឈ្មោះ ក្នុងទំហំសរុប ៥.៣៨៦ ម$^{2}$ ក្នុងតម្លៃ ១ ដុល្លារ ២ កាក់ ដោយមានឈ្មោះ ជាអ្នកជួយទិញឱ្យដដែល ហើយមានចំណែកស្មើគ្នាជាមួយឈ្មោះ ។ ពេលខ្លួនបានទិញដីទាំងពីរកន្លែងហើយ ខ្លួនជាអ្នករក្សាទុកឯកសារទាំងអស់ ។ ប្រហែលឆ្នាំ២០១៣ ខ្លួនដឹងថាបងស្រីខ្លួនឈ្មោះ បានយកប្លង់ដីពីបន្ទប់ខ្លួនយកទៅទុក តែដោយសារខ្លួនគិតថាជាបងប្អូននិងគ្នាទើបមិនសួរដេញដោល ។

ដើមឆ្នាំ២០១៥ ខ្លួនបានជួបបញ្ហាប្រាក់កាក់ ទើបខ្លួនចង់លក់ដីមួយកន្លែងដែលជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់ តែបងស្រីខ្លួនឈ្មោះ មិនប្រគល់ប្លង់ដីឱ្យខ្លួនទេ ។ ខ្លួនក៏មិនចង់មានបញ្ហាជាមួយនឹងបងស្រីក៏ខ្លួនឈប់និយាយរឿងលក់ដីទៅ ។

ចុងឆ្នាំ២០១៩ បងស្រីខ្លួនឈ្មោះ បានយកប្លង់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់ឯង និងប្លង់ដីដែលមានកម្មសិទ្ធិរួម ទៅលួចសុំចុះបញ្ជីដាក់ឈ្មោះ តែម្នាក់ឯង តែអាជ្ញាធរឃុំ និងស្រុក មិនបានផ្តល់ជូនឡើយ ដោយសារតែតាមការពិនិត្យទៅលើឯកសារមានភាពមិនប្រក្រតី ដោយសារតែបងស្រីឈ្មោះ លួចបំពេញឈ្មោះគាត់បន្ថែមទៀតទៅលើឯកសារទិញលក់ដីដែលជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់ឯង ។

មេភូមិឈ្មោះ បានធ្វើលិខិតបញ្ជាក់លេខ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២២ ថាដីទំហំប្រមាណ ១០.៩៤៥ ម$^{2}$ ដែលជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់គត់ដែលទិញពីប្តីឈ្មោះ និងប្រពន្ធឈ្មោះ មិនមានចំណែកឈ្មោះ ក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ទិញលក់ឡើយ ដូច្នេះដីដែលទិញមានចំណែកឈ្មោះ តែម្នាក់គត់ ។ ខ្លួនសុំឱ្យឈ្មោះ យកឯកសារច្បាប់ដើមនៃដីដែលមានទំហំ ១០.៩៤៥ ម$^{2}$ ដែលជាកម្មសិទ្ធិរបស់ខ្លួនតែម្នាក់គត់ មកបង្ហាញតុលាការ និងសុំធ្វើកោសល្យវិច័យ បញ្ជាក់ភាពត្រឹមត្រូវថាមានកន្លែងបន្លំឬទេ បើសិនជាឈ្មោះ ពិតជាក្លែងបន្លំមែនសុំឱ្យចាត់ការទៅតាមផ្លូវច្បាប់ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ជនសង្ស័យឈ្មោះ បានឆ្លើយនៅចំពោះមុខមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថា៖ ខ្លួនសុំរក្សាកំណត់ហេតុសួរចម្លើយចុះថ្ងៃទី២១ ខែមេសា ឆ្នាំ

២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងស្រុង ។ ឈ្មោះ និង ខ្លួន ត្រូវជាបងប្អូននឹងគ្នា ។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ លើកទី១ ខ្លួនបានទិញដីទំហំ ១០.៤៤៥ ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដោយខ្លួនទិញដីតាមការណែនាំរបស់ឈ្មោះ ខ្លួននិងឈ្មោះ បានទិញដីរួមគ្នា ហើយបានដាក់ឈ្មោះរួមគ្នារវាងខ្លួន និងឈ្មោះ ។ ឈ្មោះ បានប្រាប់ខ្លួនថា ដីនៅម្ដុំនោះនឹងទទួលបានចំណេញនៅថ្ងៃក្រោយ ។ លុះដល់ខែធ្នូ ឆ្នាំ ២០០៥ ឈ្មោះ បានណែនាំឱ្យខ្លួនទិញដីទំហំ ... ម៉ែត្រការ៉េ ជាលើកទី២ ស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ខ្លួននិងឈ្មោះ បានទិញដីជាមួយគ្នា ហើយបានដាក់ឈ្មោះរួមគ្នារវាងខ្លួននិងឈ្មោះ ។ ខ្លួននិងឈ្មោះ លើកទី២នេះ គឺស្ថិតនៅជាប់ដីដែលបានទិញលើកទី១ ។ អ្នកសរសេរអក្សរបងស្រី លើពាក្យស្នើសុំកាន់កាប់ដី ពណ៌ទឹកប៊ិច គឺជាអក្សររបស់ឈ្មោះ មិនមែនជាអក្សរខ្លួនជាអ្នកសរសេរនោះទេ ។ ឈ្មោះរបស់ខ្លួនត្រូវបានសរសេរមុនពេលយកទៅឱ្យមេភូមិ និងមេឃុំ ចុះហត្ថលេខា ។ ខ្លួនពុំបានដឹងរឿងអ្វីទេ ពីព្រោះខ្លួនចាំតែផ្ដិតមេដៃដើម្បីទុកឱ្យមេភូមិ និងមេឃុំ ចុះហត្ថលេខា ។ ម្យ៉ាងទៀតចំពោះលិខិតផ្ទេរសិទ្ធិទិញដីខ្លួនពុំបានពិនិត្យឱ្យបានច្បាស់លាស់ទេ ។

ចំពោះអក្សរដែលសរសេរក្រោយខ្នងពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ជាអក្សររបស់ឈ្មោះ ។ ឈ្មោះ ជាអ្នកស្គាល់ឈ្មោះ ទើបពឹងពាក់ឱ្យជួយរៀបចំឯកសារទិញលក់ដីឱ្យ ។

ចំពោះដីនៅភូមិត្រពាំងរុន ឃុំសំរោង ស្រុកប្រាសាទបាគង ខេត្តសៀមរាបទាំង ០២ កន្លែងនេះ ឈ្មោះ ជាអ្នករៀបចំឯកសារឱ្យខ្លួន និងឈ្មោះ ។ ខ្លួនទើបតែស្គាល់ឈ្មោះ នៅថ្ងៃផ្ដិតមេដៃលើលិខិតកាន់កាប់ដីប៉ុណ្ណោះ ។

ចំពោះការបំពេញលើទម្រង់លិខិតកាន់កាប់ដី និងពាក្យសុំកាន់កាប់ដី ខ្លួនពុំបានដឹងថានរណាជាអ្នកសរសេរនោះទេ គឺគេបានសរសេររួចរាល់មកហើយបានយកមកឱ្យខ្លួនផ្ដិតមេដៃ ។ លិខិតផ្ទេរសិទ្ធិកាន់កាប់ដី និងពាក្យសុំកាន់កាប់ដី ខ្លួនមិនមែនជាអ្នកសរសេរលើលិខិតទាំងពីរនេះទេ ។ ចំពោះឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ខ្លួនជាអ្នករៀបចំទុកឯកសារដោយផ្ទាល់ ។

ឈ្មោះ បានជំពាក់ប្រាក់ខ្លួន សរុបចំនួន ៩៩,០០០ (ប្រាំបួនមុនប្រាំបួនពាន់) ដុល្លារអាមេរិក គិតទាំងប្រាក់ដែលឈ្មោះ បានខ្ចីពីកូនស្រីរបស់ខ្លួនចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ។ ការខ្ចីផ្ទាល់មាត់ និងការខ្ចីដែលមានលិខិតស្នាមដែលប្រាក់ខ្ចីនេះ គឺខ្លួនបានទៅខ្ចីបន្តពីគេយកមកឱ្យឈ្មោះ រហូតមកដល់ពេលនេះឈ្មោះ ពុំបានសងប្រាក់ត្រឡប់មកខ្លួនវិញនោះទេ ។

ក្នុងអំឡុងឆ្នាំ២០០៦ ឈ្មោះ បាននាំខ្លួនទៅទិញមួយកន្លែងទៀត ស្ថិតនៅភូមិស្ពានសង្រ្គាម ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប៉ុន្តែមកដល់ពេលនេះខ្លួនពុំស្គាល់ដីនោះស្ថិតនៅត្រង់ណានោះទេ ខ្លួនគ្រាន់តែកាន់កាប់លិខិតកាន់កាប់ដីតែប៉ុណ្ណោះ ។

-បានឃើញ កំណត់ហេតុចម្លើយរបស់សាក្សីឈ្មោះ ឆ្លើយនៅចំពោះមុខតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថា៖ ខ្លួនបានស្បថរួចរាល់ហើយ ។ ខ្លួនមិនមែនជាសាច់ញាតិរបស់គូភាគីក្នុងរឿងក្តីនេះទេ ។ ខ្លួនសូមឆ្លើយតែការពិត ដែលខ្លួនបានដឹង បានឮ និងបានឃើញផ្ទាល់ភ្នែក ។ ខ្លួនបានរាប់អានគ្នាជាមួយឈ្មោះ នៅពេលដែលគាត់មកលេងខេត្តសៀមរាបក្នុងឆ្នាំ២០០៥ ។ ខ្លួនក៏បានណែនាំ និងជួយទិញដីចំនួនពីរកន្លែងឲ្យគាត់រួមមាន៖ ដីមួយកន្លែងមានទំហំ ១០.៤៤៥ ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងរុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានលិខិតបញ្ជាក់ទទួលស្គាល់លេខ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ របស់មេឃុំអំពិលដែលមានឈ្មោះ ជាម្ចាស់កម្មសិទ្ធិ ។ លុះរំលងមួយខែ ខ្លួនបានជួយទិញដីមួយកន្លែងទៀតទំហំ ៥.៣៨៦ ម៉ែត្រការ៉េ ដែលជាការទិញរួមគ្នារវាង និងបងស្រីរបស់គាត់ឈ្មោះ ដែលខាងត្បូងជាប់នឹងដីរបស់ឈ្មោះ ហើយក៏មានលិខិតបញ្ជាក់លេខ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៥ របស់ឃុំអំពិលដែរ ។ ខ្លួនសូមធានាអះអាងថា ចំពោះដីដែលមានទំហំ ១០.៤៤៥ ម៉ែត្រការ៉េ គឺជាដីដែលខ្លួនបានទិញឲ្យឈ្មោះ តែម្នាក់ឯងគត់ ពុំមានចំណែកបងស្រីឈ្មោះ នៅក្នុងនោះទេ ។ ខ្លួនសូមបញ្ជាក់ថា ពាក្យស្នើសុំកាន់កាប់ដីលេខ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ លើទំហំដីប្រមាណ ១០.៤៤៥ ម៉ែត្រការ៉េ គឺមានការសរសេរបន្ថែមពាក្យបង ពិតប្រាកដមែន ។

-បានឃើញ កំណត់ហេតុចម្លើយរបស់សាក្សីឈ្មោះ ឆ្លើយនៅចំពោះមុខតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញថា៖ ខ្លួនបានស្បថរួចរាល់ហើយ ។ ខ្លួនសូមឆ្លើយតែការពិត ដែលខ្លួនបានដឹង បានឮ និងបានឃើញផ្ទាល់ភ្នែក ។ ខ្លួនបានដឹងឈ្មោះ និងឈ្មោះ បានទិញដីជាមួយគ្នាចំនួនកន្លះហិកតា ។ ឈ្មោះ ធ្លាប់ប្រាប់ខ្លួនថា គាត់បានយកប្លង់ដីមករក្សាទុក ដោយគាត់បានយកពីបន្ទប់របស់ឈ្មោះ ។ អំឡុងពេលដែលឈ្មោះ បានយកប្លង់ដីមកទុកនេះ ឈ្មោះ និងឈ្មោះ រស់នៅផ្ទះជាមួយគ្នា ។ ខ្លួនបានដឹងថាឈ្មោះ បានជំពាក់ប្រាក់របស់ឈ្មោះ ចំនួន ១៨,០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ដោយលើកទី០១ ឈ្មោះ បានខ្ចីប្រាក់ពីឈ្មោះ ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។ លើកទី០២ ឈ្មោះ មិនបានខ្ចីប្រាក់ពីឈ្មោះ នោះទេ ប៉ុន្តែឈ្មោះ យល់ព្រមទទួលសងប្រាក់ជំនួសមិត្តភកិ

ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ទៅឲ្យឈ្មោះ ។ទី០៣ ឈ្មោះ បានខ្ចី ប្រាក់ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ពីឈ្មោះ ។

ឈ្មោះ បានប្រាប់ខ្លួនឲ្យបានដឹងថាឈ្មោះ បានយកប្លង់ដីមកសរសេរឈ្មោះរបស់គាត់បន្ថែមនៅលើប្លង់ដីរបស់ឈ្មោះ ពិតប្រាកដមែន ប៉ុន្តែមិនបានដឹងថាជាអក្សររបស់ឈ្មោះ ឬជាអក្សររបស់នរណាគេនោះទេ ។ ចំពោះការសរសេរឈ្មោះរបស់ឈ្មោះ បងស្រី នៅលើប្លង់ដីរបស់ឈ្មោះ គឺដើម្បីទូទាត់ប្រាក់ដែលឈ្មោះ បានជំពាក់ឈ្មោះ ។

-បានឃើញ ឯកសារពាក់ព័ន្ធនានានៅក្នុងសំណុំរឿងទាំងមូល មានដូចជា៖

១.របាយការណ៍កោសល្យវិច័យលេខ: ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋាននគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ ។

២.យោងតាមពាក្យបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៣.ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៣៨០ ឃអព ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះ ភេទប្រុស អាយុ៣៨ ឆ្នាំ សញ្ជាតិខ្មែរ និងបងស្រីឈ្មោះ មានទីលំនៅផ្ទះលេខ ៦១ $E_0$ ផ្លូវ២៤០ សង្កាត់ជយជន: ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤.សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប។

៥.កំណត់ធ្វើសច្ចាប្រណិធានរបស់ឈ្មោះ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦.លិខិតជូនដំណឹងលេខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៧.ពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៨.សេចក្តីប្តឹងសុំតវ៉ា របស់ឈ្មោះ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេ

៩.លិខិតបញ្ជូនលេខ | ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានី

ភ្នំពេញ។

១០.ដីកាបញ្ជូនលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានី

ភ្នំពេញ។

## យល់ឃើញថា

១- ផ្អែកលើអង្គហេតុ តំណាងមហាអយ្យការពិនិត្យឃើញថា ភាគីជនសង្ស័យឈ្មោះ ពិតជា

នយកឯកសារពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី និងឯកសារផ្សេងៗទៀតរបស់ភាគីដើមបណ្តឹងឈ្មោះ -

ទៅរក្សាទុក និងបានសរសេរបន្ថែមត្រង់ចំណុច | នៅក្នុងពាក្យសុំកាន់កាប់ប្រើប្រាស់

ដីធ្លី ពិតប្រាកដមែន ។ (ឯកសាររបាយការណ៍កោសល្យវិច័យលេខ ០៣៧/២៣ ចល.អក/បវ)

២- យោងតាមសេចក្តីចម្លងរបាយការណ៍កោសល្យវិច័យលេខ: ០៣៧/២៣ ចល.របក/បវ ចុះថ្ងៃទី០៧

ខែសីហា ឆ្នាំ២០២៣ របស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃក្រសួងមហាផ្ទៃ បានធ្វើសេចក្តី

សន្និដានស្នាមអក្សរសរសេរដៃត្រង់ចំណុចពាក្យ "និងបងស្រី នៅលើឯកសារពាក្យស្នើសុំកាន់កាប់

ប្រើប្រាស់ដីធ្លី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣៣៣ ឃអព ចុះថ្ងៃទី១៣ ខែតុ... ឆ្នាំ២០០៥ របស់ឈ្មោះ

ឲ្យសញ្ញាសម្គាល់ E1 និង E2 ជាមួយគំរូស្នាមអក្សរសរសេរដៃនៅលើឯកសារឲ្យសញ្ញាសម្គាល់

S1.S2 និង S3 គឺដូចគ្នាតែមួយសរសេរដោយបុគ្គលតែមួយ ។ *<u>ចំពោះឯកសារដែលមានសញ្ញាសម្គាល់ S1.S2</u>*

*<u>និង S3 គឺជាអក្សររបស់ឈ្មោះ ហើយឈ្មោះ ជាប្តីរបស់ជនសង្ស័យឈ្មោះ</u>*

ការណ៍នេះស្តែងឲ្យឃើញពីចេតនាជននេះ មានគោលបំណងទុច្ចរិតក្នុងការសរសេរឈ្មោះ | ដើម្បីក្លែងបន្លំ

ធ្វើ ម្ចាស់សិទ្ធិលើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់ដើមបណ្តឹងឈ្មោះ ។

៣- ចេតនាទុច្ចរិតបង្ហាញឲ្យឃើញពីការក្លែងបន្លំលើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ដោយសរសេរ

ឈ្មោះ ហើយអះអាងថានាខ្លួនជាសហកម្មសិទ្ធិលើដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ជាចេតនាក្លែង

បន្លំពិតប្រាកដ ក្នុងគោលដៅធ្វើជាភស្តុតាងនៃសិទ្ធិ ដើម្បីធ្វើការតតាំងជាមួយដើមបណ្តឹងរដ្ឋប្បវេណី

និងបានប្រើប្រាស់លិខិតនេះគ្រប់ដំណាក់កាលនីតិវិធីតុលាការ ដែលនៅក្នុងន័យនេះបញ្ជាក់បានថាជាសហកម្មសិទ្ធ

លើដីភោគ: ទំហំ១០,៩៤៥ម² ។ អំពើនិងសកម្មភាពនេះ បំពាននឹងមាត្រា ៦២៦ ផ្តន្ទាទោសតាមមាត្រា ៦២៧

និងមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ ។

៤- ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សម្រេចមកនេះ មិនទាន់មានលក្ខណៈត្រឹមត្រូវនៅឡើយ គួរសម្រេច

ចោទប្រកាន់ជនសង្ស័យឈ្មោះ និងឈ្មោះ ឡើងវិញតាមច្បាប់ ។

<u>ហេតុដូច្នេះសម្រេច</u>

១- បដិសេធចោលដីកាតម្កល់រឿងទុកឥតចាត់ការលេខ ( ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់។

២- ចេញអធិបញ្ញាដល់ ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ឱ្យធ្វើការចោទប្រកាន់លើឈ្មោះ និងឈ្មោះ (មានសាវតាជាតិដូចខាងលើ) ពីបទ៖ **ការក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង** បទល្មើសព្រហ្មទណ្ឌមានចែងតាមបញ្ញត្តិមាត្រា៦២៦ ផ្តន្ទាទោសតាមមាត្រា ៦២៧ និងមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ ។

៣- បង្វិលសំណុំរឿងទុកឥតចាត់ការលេ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃ.អង្គារ.៣រោច..........ខែ...អស្សុជ..... ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី...៣១.......ខែ..តុលា............ឆ្នាំ២០២៣

**ត.ប. អគ្គព្រះរាជអាជ្ញា**

**អគ្គព្រះរាជអាជ្ញារង**

ឧបសម្ព័ន្ធទី១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

លេខ.
សំណុំរឿងតម្កល់ទុកឥតចាត់ការលេខ
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

## លិខិតជូនដំណឹង

## យើង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

## ជម្រាបមក

-ឈ្មោះ ភេទប្រុស អាយុ៣៩ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

អំពីបណ្តឹងឧទ្ធរណ៍របស់លោក ប្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ___ ផកមចក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្តាល ពីដំណើររឿង: រំលោភលើទំនុកចិត្ត នោះ យើងបានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តកណ្តាលខាងលើ ទុកជាបានការដដែល ដោយសេចក្តី នេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ តាមសេចក្តីសម្រេចរបស់យើងលេខ... ... សត.ប្រក.០២៤ ចុះថ្ងៃទី..២៣....ខែ.សីហា ឆ្នាំ២០២៤ ។

ហេតុនេះ សូមលោក ជ្រាប។

ថ្ងៃ.សុក្រ...៤រោច...... ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.២៣.ខែ.សីហា.. ឆ្នាំ២០២៤

ត.ប អគ្គព្រះរាជអាជ្ញា
អគ្គព្រះរាជអាជ្ញារង

យើង...............................មុខងារ.....................បាន
ប្រគល់លិខិតជូនដំណឹងនេះឱ្យឈ្មោះ ......................................
ទីលំនៅសព្វថ្ងៃនៅ............................ឃុំ.សង្កាត់....................
ស្រុក.ខណ្ឌ.................................ខេត្ត.រាជធានី.....................
នៅថ្ងៃទី................ខែ.............ឆ្នាំ២០២៤ រួចហើយ។

អ្នកទទួល អ្នកប្រគល់

**ឧបសម្ព័ន្ធទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣

លេខ :

**ជម្រាបមក**

**ឯកឧត្តម ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ ការធ្វើអធិបញ្ញាដើម្បីអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់លើសំណុំរឿងព្រហ្មទណ្ឌរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធនឹងករណី**ឆបោក** និងករណី**មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ដែលមានជនសង្ស័យឈ្មោះ

**យោង** ៖ មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមព្រះរាជអាជ្ញា** ជ្រាបថា ផ្អែកតាមអង្គហេតុដែលទទួលបាន, ឈ្មោះ ភេទស្រី អាយុ ៣៨ឆ្នាំ បានចេញមូលប្បទានបត្រមួយចំនួន រួមមាន មូលប្បទានបត្រលេខ ចុះថ្ងៃទី ២២-០៤-២០២៣ មានទឹកប្រាក់ចំនួន ៦៥ ៨១៥ ដុល្លារអាម៉េរិក និងមូលប្បទានបត្រលេខ ចុះថ្ងៃទី ២៤-០៤-២០២៣ មានទឹកប្រាក់ចំនួន ៥២ ៦០០ ដុល្លារអាម៉េរិក និងមូលប្បទានបត្រលេខ ចុះថ្ងៃទី ១៣-០៨-២០២៣ មានទឹកប្រាក់ចំនួន ១១៥ ៥០០ ដុល្លារអាម៉េរិក ដើម្បីទូទាត់សងប្រាក់ទៅឈ្មោះ ឈ្មោះ និងឈ្មោះ 1 នៅពេលដល់ថ្ងៃកំណត់បើកប្រាក់ ឈ្មោះ ឈ្មោះ និងឈ្មោះ បានយកមូលប្បទានបត្រនោះ ទៅបើកប្រាក់នៅធនាគារ ប៉ុន្តែខាងធនាគារបានបញ្ជាក់ថាមូលប្បទានបត្រខាងលើមិនមានសាច់ប្រាក់នៅក្នុងគណនីនោះទេ។ ចំពោះករណីនេះ ឈ្មោះ ឈ្មោះ ឈ្មោះ បានដាក់ពាក្យប្តឹងទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួចហើយ ដែលមានសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៣១ ចុះថ្ងៃទី ១៥-០៦-២០២៣, សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ២៣-០៨-២០២៣ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៩៤ ចុះថ្ងៃទី ០៣-០៩-២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

យោងតាមមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌សូមចេញអធិបញ្ញាឱ្យ **ឯកឧត្តមព្រះរាជអាជ្ញា** ចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ចំពោះករណីខាងលើ ដោយអនុវត្តស្របតាមនីតិវិធីជាធរមាន ដើម្បីធានាថា ផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះនៅក្នុងករណីនេះ ត្រូវបានការពារដោយត្រឹមត្រូវ។

សូម **ឯកឧត្តមព្រះរាជអាជ្ញា** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

ឧបសម្ព័ន្ធទី១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤
លេខ......

# សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**យើង** **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍លេខ ១០៤ រ.ប.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់[1] ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា មានតម្រុយសន្មតបានថា៖**

នាមត្រកូល-នាម ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ ។ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជានីតិជន។ **(ក្រៅឃុំ)**

**បានប្រព្រឹត្តដូចតទៅ[2]** ៖ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅចំណុចរាជធានីភ្នំពេញ មានករណី៖ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តឡើងដោយជនសង្ស័យឈ្មោះ ដោយកាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៩ ជនសង្ស័យឈ្មោះ បានមកនិយាយលួងលោមឱ្យជនរងគ្រោះឈ្មោះ ផ្តល់ប្រាក់ឱ្យចំនួន ៤៥,០០០$ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដើម្បីយកទៅទិញគ្រឿងចក្រ ដោយអះអាងថានឹងប្រគល់ប្រាក់ឱ្យជនរងគ្រោះវិញក្នុងរយៈពេល ០៦ខែ បន្ទាប់មកជនរងគ្រោះក៏ប្រគល់ប្រាក់ឱ្យជនសង្ស័យចំនួន ៤៥,០០០$ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) លុះដល់ថ្ងៃកំណត់ប្រគល់ប្រាក់សងជនរងគ្រោះ, ជនសង្ស័យឈ្មោះ បានចេញមូលប្បទានប័ត្រចំនួន ០១សន្លឹក លេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ធនាគារអេស៊ីលីដា ភីអិលស៊ី នូវទឹកប្រាក់ចំនួន ៤៥,០០០$ (បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ដើម្បីទូទាត់សងប្រាក់ឱ្យជនរងគ្រោះ បន្ទាប់មកជនរងគ្រោះបានយកមូលប្បទានប័ត្រខាងលើទៅបើកប្រាក់នៅធនាគារ ស្រាប់តែខាងធនាគារបានបញ្ជាក់ថាមូលប្បទានប័ត្រនេះ ពុំមានសាច់ប្រាក់ទេ ផ្អែកតាមមូលប្បទានប័ត្របញ្ជូនត្រឡប់ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ក្រោយមកជនរងគ្រោះបានទាក់ទងទៅជនសង្ស័យឈ្មោះ ដើម្បីសួរនាំ ប៉ុន្តែឈ្មោះនេះបានគេចវេសរហូតមកដល់បច្ចុប្បន្ន ។

អំពើខាងលើគឺជាបទល្មើស ៖ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ មាត្រា៤៤ និងមាត្រា១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

<u>**ហេតុដូច្នេះសម្រេច ៖**</u>

**-បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ**

☐ ដាក់ឱ្យស្ថិតក្រោមការពិនិត្យលើ[3] ៖

នាមត្រកូល-នាម ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ។ **(ក្រៅឃុំ)**

-ពីបទ៖ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

បានឃើញ មាត្រា៤៤ និងមាត្រា១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[4] ៖.................................................។

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះខាងលើ[5] ៖

ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី៖

-ធានារក្សាជនត្រូវចោទទុកឱ្យតុលាការចាត់ការតាមនីតិវិធី ។

ថ្ងៃ.ចន្ទ.......៩ រោច.........ខែ អាសាឍ.ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី.២៩...ខែ កក្កដា ឆ្នាំ២០២៤

**តំណាងអយ្យការ**

---

[3] ឈ្មោះជនត្រូវចោទ

[4] កាតព្វកិច្ចណាមួយដែលបានចែងក្នុងមាត្រា២២៣

ឧបសម្ព័ន្ធទី១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

លេខ...

**ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់[1]**

**យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ របាយការណ៍សំយោគ លេខៈ ០៤១/២៤ របក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់ និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌ លេខៈ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ៤៦, ៤៩ ,២៩១ ,២៩៥ , និង ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ ២០០៧ ។

**<u>បន្ទាប់ពីបានពិនិត្យសំណុំរឿងចប់បានសព្វគ្រប់ ឃើញថា៖[2]</u>**

.នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ មុខរបរៈ អ្នកសារព័ត៌មាន ទីកន្លែងកំណើតនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិកោះចិន ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូនចំនួន០២នាក់ ជានីតិជន ទោសពីមុនៈ គ្មាន ។ (ក្រៅឃុំ)

<u>បានប្រព្រឹត្តដូចតទៅ</u> ៖

កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៩ និង២៩នាទីយប់ ស្ថិតនៅរាជធានីភ្នំពេញ មានករណីៈ បរិហារកេរ្តិ៍ជាសាធារណៈ បង្កឡើងដោយជនត្រូវចោទឈ្មោះ ភេទប្រុស ទៅលើជនរងគ្រោះឈ្មោះ ភេទប្រុស ។ មុនពេលកើតហេតុជនរងគ្រោះកំពុងប្រចាំការនៅនាយកដ្ឋានមណ្ឌលព័ត៌មាននៃក្រសួងព័ត៌មាន ស្រាប់តែមានមន្ត្រីមួយរូបនៅក្នុងនាយកដ្ឋានបានផ្ញើសារសំឡេងតាមបណ្តាញទំនាក់ទំនង ក្រោមរបស់ជនត្រូវចោទឈ្មោះ ដែលជាអ្នកសារព័ត៌មានសានព្រហ្ម បានបរិហារកេរ្តិ៍មកលើជនរងគ្រោះដែលមានខ្លឹមសារថា ៖ *នេះល្បីខ្លាំងណាស់ ហ្នឹង! អ្នកសារព័ត៌មានហ្នឹងខាងអីគេបានល្បីខ្លាំងម្លេះ អត់យល់ទេ! មើលបងប្អូនជួយប្រាប់បន្តិចមើលពីណាគេ ឯកឧត្តមណា ?? ប៉ើងឥឡូវ "កាងល្បែងស៊ីសង ហ្នឹង" "ជួយប្រាប់បន្តិចមើល ឯកឧត្តមខាងណាកាងល្បែងស៊ីសងគ្រប់កន្លែង"* ។ បន្ទាប់ពីបានស្តាប់សារសំឡេងខាងលើរួច ស្រាប់តែមានមិត្តភ័ក្តិជាច្រើននាក់ បានទូរស័ព្ទមកសួរនាំជនរងគ្រោះនូវព័ត៌មានខាងលើ ។

[1] [illegible]

[2] [illegible]

[illegible]

<u>បានឃើញ</u>៖[៣]

-បានឃើញរបាយការណ៍សំយោគ លេខៈ ០៤១/២៤ របក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់អគ្គ ។

-ចម្លើយរបស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ នៅនាយកដ្ឋានព័ត៌មានវិទ្យា ថា៖ បច្ចុប្បន្ន ខ្ញុំមានគណនីតេឡេក្រាមឈ្មោះ ភ្ជាប់ដោយលេខទូរស័ព្ទ ដែលមាន Profile Picture រូបខ្ញុំពាក់អាវពណ៌ស ប្រើប្រាស់សម្រាប់ ទំនាក់ទំនងការងារ ក្រុមគ្រួសារ និងមិត្តភ័ក្តិ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៩និង២៩នាទីយប់ ពេលខ្ញុំបាទកំពុងប្រចាំការនៅនាយកដ្ឋានមណ្ឌលព័ត៌មាន ក្រសួងព័ត៌មាន ស្រាប់តែមានមន្ត្រី ០១រូបនៅក្នុងនាយកដ្ឋាន បានផ្ញើសារសម្លេងតាមបណ្តាញទំនាក់ទំនងតេឡេក្រាមរបស់ឈ្មោះ ភេទប្រុស អាយុ៤៣ឆ្នាំ ឈ្មោះហៅ

មានទីលំនៅនៅភូមិ ព្រែកក្តាម១ ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ប្រើប្រាស់ទូរស័ព្ទលេខ មុខរបរៈ អ្នកសារព័ត៌មាន ដោយបានបរិហារកេរ្តិ៍ ជេរប្រមាថ មករូបខ្ញុំបាទ ដែលមានខ្លឹមសារថា :ល្បីខ្លាំងណាស់ ហ្នឹង។ អ្នកសារព័ត៌មាន ហ្នឹងខាងអីគេបានល្បីខ្លាំងម្លេះ អត់យល់ទេ។ មើលបងប្អូនជួយប្រាប់បន្តិច ពីណាគេ ឯកឧត្តមណា រ៉ៃប៉ុងឥឡូវ-"កាងល្បែងស៊ីសង ហ្នឹង" "ជួយប្រាប់បន្តិច មើល ហ្នឹង ឯកឧត្តម ខាងណា កាងល្បែងស៊ីសងគ្រប់កន្លែង" ។ បន្ទាប់ពីបាន ស្តាប់សារសម្លេងខាងលើរួច ស្រាប់តែមានមិត្តភ័ក្តិជាច្រើននាក់ បានទូរស័ព្ទមកសួរនាំខ្ញុំបាទ នូវព័ត៌មានខាងលើ ហើយទង្វើដែលឈ្មោះ បានប្រព្រឹត្ត ធ្វើឱ្យសាធារណជនមាន ការកាន់ច្រឡំមកលើខ្ញុំបាទ និងបណ្តាលឱ្យប៉ះពាល់អាប់ឱនកិត្តិយសរបស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ ។

-ចម្លើយរបស់ជនត្រូវ ៤៣ឆ្នាំ នៅនាយកដ្ឋានព័ត៌មានវិទ្យា ថា៖ ខ្ញុំបាទមានគណនីហ្វេសប៊ុកចំនួន០៣គណនីគេហទំព័រចំនួន០១និងគណនីតេឡេក្រាមចំនួន០២សម្រាប់ប្រើប្រាស់ក្នុងអាជីពជាអ្នកសារព័ត៌មានដូចខាងក្រោម៖

១-គណនីហ្វេសប៊ុកឈ្មោះ...កស្លាប់ការពារត្រកូលហ៊ុនស្មោះត្រង់មានតំណភ្ជាប់
https://m.facebook.com/story.php?story_fbid=pfbid09g6podASMez6tUyL PUfeqNgA2sAYRVS4jcnm72zXqgqZdfGotXub8W d=100073866727403&sfnsn=mo

២-គណនីហ្វេសប៊ុកឈ្មោះ មានតំណភ្ជាប់
https://m.facebook.com/story.php?story_fbid=pfbid0zPFv1g3NBrGKoyGonEETM8hBXZ6SjFx6hiCyv5b6L 7XL4XSBa7Ct9sRho4tjCEv7l&id= 100075870763767&sfnsn=mo។

៣-គណនីហ្វេសប៊ុកឈ្មោះ ប់មានតំណភ្ជាប់
/m.facebook.com/story.php?story_fbid=pfbid0ST46DC6bCZ2Qnb6uoZhmmYhTMnubPbRRYwdcGRtkdgtpG7UsnHiubdfbQuqJZf9Jl&id=100075695419010&sfnsn =mo

៤-គេហទំព័រឈ្មោះ _345 មានតំណភ្ជាប់

៥-គណនីតេឡេក្រាមឈ្មោះ ភ្ជាប់ជាមួយលេខទូរស័ព្ទ

៦-គណនីតេឡេក្រាមឈ្មោះមនុស្សមានចិត្តមេត្តាធម៌ ភ្ជាប់ជាមួយលេខទូរស័ព្ទ ៥១០៧។ រូបខ្ញុំចាប់ផ្តើមអាជីពជាអ្នកសារព័ត៌មានតាំងពីឆ្នាំ២០១៧ ជាមួយ ជាចាងហ្វាង់សារព័ត៌មាន ដែលមានទីតាំងនៅសង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ រហូតមកដល់បច្ចុប្បន្ន។ បានជាសមត្ថកិច្ចកោះហៅរូបខ្ញុំមកសាកសួរនៅនាយកដ្ឋានព័ត៌មានវិទ្យា ដោយសារតែ រូបខ្ញុំបាទបាន

[៣] [illegible]
[៤] [illegible]
[៥] [illegible]

បរិហារកេរ្តិ៍ និងជេរប្រមាថចំពោះឯកឧត្តម តាមបណ្តាញ ទំនាក់ទំនងសង្គមតេឡេក្រាម។កាលថ្ងៃទី៣០ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ២១និង២០នាទី ខ្ញុំបាទបានទៅទីតាំងមួយកន្លែងមានយីហោសប្បាយរីករាយ ស្ថិតនៅក្រោយស្ពានខូតអូស្ត្រាលី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមួយអ្នកសារព័ត៌មានជាច្រើន ទៀត ដើម្បីទៅធ្វើការផ្សាយបន្តផ្ទាល់(live)អំពីល្បែងស៊ីសងនៅខាងក្នុង ប៉ុន្តែរូបខ្ញុំមិន ទាន់បាន (live)ទេ ស្រាប់តែមានអ្នកបកប្រែចិនម្នាក់ឈ្មោះ បានខលទូរស័ព្ទទំនាក់ ទំនងមកខ្ញុំតាមលេខ ដោយនិយាយថា«បើសិនអ្នកសារ ព័ត៌មានណាហ៊ាន(live) នៅទីតាំងសប្បាយរីករាយ ពន្លឺព្រះអាទិត្យ និងត្រូវដកអាជ្ញា ប័ណ្ណ» ក្រោយមកខ្ញុំក៏ស៊ើបដឹងថាទីតាំងនេះពាក់ព័ន្ធជាមួយមន្ត្រីនៅក្រសួងព័ត៌មាន ម្នាក់នៅពីក្រោយគឺឈ្មោះ ។ ថ្ងៃទី៣១ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៨និង៣០នាទី ខ្ញុំបាទបានចូលរួមផឹកស៊ីនៅផ្ទះមិត្តភក្រ្តិជាអ្នកសារព័ត៌មានដូចគ្នាមុំ ស្ទឹងមានជ័យហើយក៏រំលឹកនូវហេតុការណ៍កាលពីយប់មិញ នៅទីតាំងសប្បាយរីករាយ ពន្លឺព្រះអាទិត្យ ពេលនោះខ្ញុំក៏ចាប់ផ្តើមមានកំហឹងនិងដោយសាររូបខ្ញុំស្រវឹងផង ខ្ញុំក៏ បានឆាតជាសំលេងតាមគណនីតេឡេក្រាមឈ្មោះ ភ្ជាប់ជាមួយ លេខទូរស័ព្ទ ៧និងគណនីតេឡេក្រាមឈ្មោះ មេ ជាមួយលេខទូរស័ព្ទ ទៅឈ្មោះ តាម លេខ ដែលជាអ្នកខលទូរស័ព្ទមកខ្ញុំកាលពីយប់មិញដោយនិយាយ ជេរប្រមាថចំពោះឯកឧត្តម មានខ្លឹមសារថា«តើខ្លាំងប៉ុណ្ណា ឯកឧត្តមអាចម៍ក្អែហ្នឹង ដើរកោងល្បែងស៊ីសងហ្នា ល្បីខ្លាំងណាស់ហ្នា វ៉ៃ ប៉ើងលូវហ្នា »។ លុះដល់ថ្ងៃទី០១ខែមិថុនាឆ្នាំ២០២២ វេលាម៉ោងប្រហែល១៨និង២០នាទី ដោយខ្ញុំបាននឹកឃើញពីកំហុសរបស់ខ្ញុំកាលពីម្សិលមិញ ខ្ញុំបានធ្វើវីដេអូមួយដើម្បី សុំទោសឯកឧត្តម ប្រធ្វើតាមគណនីតេឡេក្រាមឈ្មោះ ភ្ជាប់ជាមួយលេខទូរស័ព្ទ + និងគណនីតេឡេក្រាមឈ្មោះ មេត្តាធម៌ ភ្ជាប់ជាមួយលេខទូរស័ព្ទ ទៅ ឈ្មោះ តាមតេឡេក្រាមលេខ ដែលជាអ្នកបកប្រែចិនវិញ។ នៅថ្ងៃទី២២ខែមិថុនាឆ្នាំ២០២២វេលាម៉ោងប្រហែល១៧និង១០នាទីខ្ញុំ បាទបានធ្វើការផ្សាយបន្តផ្ទាល់(live) តាមគេហទំព័រឈ្មោះ មានតំណភ្ជាប់ https://fb.watch/dUSLh Twdui/ ដើម្បីសុំទោសចំពោះឯកឧត្តម បន្ថែមទៀត ។ រយៈកាលកន្លងមកខ្ញុំបាទធ្លាប់ប្រើប្រាស់គ្រឿងញៀនប្រភេទម៉ាទឹកកក បានមកពីមិត្តឈ្មោះ អាយុប្រហែល៣៨ឆ្នាំ មុខរបររកស៊ី(យកត្រីស្រែមកលក់នៅភ្នំពេញ) មានទី លំនៅខេត្តកំពង់ចាម ហើយបានជួបគ្នាដោយចៃដន្យ ក្រោយពីផឹកស៊ីក្នុងហាងរួចក៏នាំ គ្នាទៅជក់គ្រឿងញៀននៅផ្ទះសំណាក់មុំបឹងកក់។ ប្រើប្រាស់ចុងក្រោយនៅថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២២។

-ឯកសារពាក់ព័ន្ធនានាក្នុងសំណុំរឿង ។

## យល់ឃើញថា[២]៖

-ផ្អែកតាមចម្លើយរបស់ជនត្រូវចោទ និងភស្តុតាងនានា មានភាពស៊ីចង្វាក់គ្នាដែលអាចបញ្ជាក់បានថា ជនត្រូវចោទឈ្មោះ ភេទប្រុស ពិតជាបានប្រព្រឹត្តអំពើ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ប្រាកដមែន ។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

១ [illegible]

២ [illegible]

[illegible]

-ក្នុងពេលប្រព្រឹត្តបទល្មើសជនត្រូវចោទឈ្មោះ ភេទប្រុស ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវទទួលខុសត្រូវតាមកំណត់ច្បាប់ ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ភេទប្រុស ពីបទ ៖ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-បទល្មើសខាងលើនេះ គឺជាប្រភេទបទលហុ ហើយសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ។

<u>**ហេតុដូច្នេះសម្រេច**</u>[៥]

១-ចោទប្រកាន់លើ៖

.នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ មុខរបរ៖ អ្នកសារព័ត៌មាន ទីកន្លែងកំណើតនៅ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិកោះចិន ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ ម្តាយឈ្មោះ រ) ប្រពន្ធឈ្មោះ មានកូនចំនួន០២នាក់ ជានីតិជន ទោសពីមុន៖ គ្មាន ។ (ក្រៅឃុំ)

ពីបទ ៖ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

២-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ និងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ ព្រមទាំងឯកសារទាក់ទិនក្នុងសំណុំរឿង ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

**ចៅក្រមស៊ើបសួរ**

៣ [illegible]

៤ [illegible]

៥ [illegible]